# ក

## មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៧-៥-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៨២ ស្តីពីការតែងតាំងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ រីតាវគ្គ** ជាទីប្រឹក្សាសម្តេចក្រុមព្រះ**នរោត្តម រណឫទ្ធិ**ព្រះប្រធានរដ្ឋសភាមានឋានៈស្មើ **រដ្ឋលេខាធិការ** ២០៤២

២៧-៥-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៨៣ ស្តីពីការតែងតាំងឯកឧត្តម **ម៉ុន គឹមហេង** ជាឧបការីសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភាមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ២០៤៣

៣០-៥-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៥០៣/១៨៧ ស្តីពីការកែសម្រួលថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីជូនឯកឧត្តម **ឡុង វិសាលោ** ពីឧត្តមមន្ត្រីថ្នាក់លេខ **៤** ទៅជាឧត្តមមន្ត្រីថ្នាក់លេខ **១** ២០៤៤

០៣-៦-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៦០៣/១៨៩ ស្តីពីការតែងតាំងឯកឧត្តម **ស្រីយ សារត** ជាទីប្រឹក្សា ផ្ទាល់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ២០៤៦

០៣-៦-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៦០៣/១៩០ ស្តីពីការតែងតាំងឯកឧត្តម **ចៅ គៀង** ជាទីប្រឹក្សា ឯកឧត្តម **ញឹក ប៊ុនឆៃ** អនុប្រធានទី ២ នៃព្រឹទ្ធសភា មានឋានៈស្មើ **អគ្គនាយក** ជំនួសឯកឧត្តម **ម៉ុង ឃិន** ២០៤៧

០៦-៦-២០០៣ -ព្រះរាជក្រឹត្យនស/រកត/០៦០៣/១៩២ស្តីពីការតែងតាំងឯកឧត្តមបណ្ឌិតរដ្ឋ **តិច សំណាង** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការ ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា មាន ឋានៈស្មើ**អនុរដ្ឋលេខាធិការ** ២០៤៨

០៩-៦-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៦០៣/១៩៣ ស្តីពីការតែងតាំងលោក **ជុន ស៊ីថេង** ជា **ឧកញ៉ា** ២០៤៩


## II-ក្រុមប្រឹក្សាធម្មនុញ្ញ


០៤-៦-២០០៣ -សេចក្តីជូនដំណឹងលេខ ០១១/២០០៣ កបធ.សជណ ស្តីពីការប្តឹងបដិសេធសេចក្តីសំរេច លេខ ០៥.៣២៤/០៣ គ.ជ.ប ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ២០៥០

០៦-៦-២០០៣ -សេចក្តីជូនដំណឹងលេខ ០១២/២០០៣ កបធ.សជណ.ច ស្តីពីបណ្តឹងតវ៉ាចំពោះសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៥.៧៩៦/០៣ គ.ជ.ប ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៣ ២០៥១

០៩-៦-២០០៣ -សេចក្តីជូនដំណឹងលេខ ០១៣/០៣ កបធ.សជណ ស្តីពីបណ្តឹងតវ៉ាលើសេចក្តីប្រកាសបដិសេធការចុះបញ្ជី គណបក្ស កសាងជាតិ ឈរឈ្មោះបោះឆ្នោត ២០៥២

# ខ

## III.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


| | | |
|---|---|---|
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៤៤ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ២០៥៣ |
| ១០-៦-២០០៣ | -អនុក្រឹត្យ លេខ ៤៥ អនក្រ.បក ស្តីពីការកែសំរួលផ្លាកសញ្ញារូបហនុមាន សញ្ញាកងឯកភាព ឆ័ត្រយោង ឯកសណ្ឋានការងារលេខ ៤ មួកបេរេ ការស្លៀកពាក់ឯកសណ្ឋានការងារ លេខ ៤ និងសញ្ញាអគ្គបញ្ជាការកងទ័ពជើងគោក ជើងទឹក ជើងអាកាស និងរូបសញ្ញាក្រសួងការពារជាតិ | ២០៥៥ |
| ១២-៦-២០០៣ | -អនុក្រឹត្យ លេខ ៤៦ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការ ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | ២០៧១ |
| ១២-៦-២០០៣ | -អនុក្រឹត្យ លេខ ៤៧ អនក្រ.បក ស្តីពីអនាម័យនៃម្ហូបអាហារសំរាប់មនុស្ស | ២០៧៧ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៤៨ អនក្រ.បក ស្តីពីការបើកស្ថានអគ្គកុងស៊ុលកម្ពុជា នៅបរទេស | ២១១១ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១១២ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥១៥អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១១៣ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១១៤ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥១៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១១៦ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥១៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១១៨ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥១៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១២០ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥២០ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ | ២១២១ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥២១ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២១២២ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥២២ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ | ២១២៩ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥២៣ អនក្រ.តត ស្តីពីការបន្ថែមក្របខ័ណ្ឌនគរបាលជាតិ | ២១៣០ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥២៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២១៣១ |
| ០៩-៦-២០០៣ | -អនុក្រឹត្យ លេខ ៥២៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ២១៣២ |
| ១០-៦-២០០៣ | -អនុក្រឹត្យ លេខ ៥២៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២១៣៣ |
| ១០-៦-២០០៣ | -អនុក្រឹត្យ លេខ ៥២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៣៥ |
| ១០-៦-២០០៣ | -អនុក្រឹត្យ លេខ ៥២៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៣៦ |
| ១០-៦-២០០៣ | -អនុក្រឹត្យ លេខ ៥២៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២១៣៧ |

# គ


| | | |
|---|---|---|
| ១២-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៣០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២១៣៩ |
| ១២-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៣១ អនក្រ.តត ស្តីពីការជូនមេដាយស្ត្រីវឌ្ឍនា | ២១៤០ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៤២ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៣៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៤៣ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៣៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ២១៤៤ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៣៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ២១៤៥ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៣៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៤៦ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៣៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ២១៤៨ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៣៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៤៩ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៣៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៥០ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៤០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៥១ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៥២ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៤២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៥៣ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៥៤ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៤៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២១៥៥ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៤៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ២១៥៦ |
| ១៣-៦-២០០៣ | -អនុក្រឹត្យ លេខ ៥៤៦អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២១៥៧ |


## ២_សេចក្តីសំរេច


| | | |
|---|---|---|
| ១០-៦-២០០៣ | -សេចក្តីសំរេចលេខ ៤៦ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់រៀបចំការអភិវឌ្ឍតំបន់តាថាវ និងប្រាសាទព្រះវិហារ នៃខេត្តព្រះវិហារ | ២១៥៨ |
| ១១-៦-២០០៣ | -សេចក្តីសំរេចលេខ ៤៧ សសរ ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង ស្រុកសៀមរាប នៃខេត្តសៀមរាប និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបង | ២១៦១ |


## ៣_សារាចរណែនាំ


| | | |
|---|---|---|
| ០៩-៦-២០០៣ | -សារាចរណែនាំលេខ ០៨ សរណន ស្តីពីការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្ម សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** ក្នុងព្រះជន្ម ៦៧ យាងចូល ៦៨ ព្រះវស្សា | ២១៦៨ |

# ឃ

## IV~ការងារបណ្ដាក្រសួង

### ១~ធនាគារជាតិ នៃ កម្ពុជា


១១-៦-២០០៣ -ប្រកាសលេខ ធ ៨-០៨. ០៩៤ ប្រក ស្ដីពីរចនាសម្ព័ន្ធនាយកដ្ឋានគ្រប់គ្រងការប្ដូរប្រាក់ និងមុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ ២១៧១


### ២~ទីស្ដីការក្រសួងមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា


១០-៦-២០០៣ -ប្រកាសលេខ ៤៩១ អយក.ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ **វត្តត្រស់** មកជាសាលាបឋមសិក្សាពេញលក្ខណៈ ២១៧១

១០-៦-២០០៣ -ប្រកាសលេខ ៤៩២ អយក.ប្រក ស្ដីពីការបើកសាលាបឋមសិក្សា **កំពង់ខ្លោរ** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ស្វាយចេក** ២១៧៩

១០-៦-២០០៣ -ប្រកាសលេខ ៤៩៣ អយក.ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ **វត្តជ្វង** មកជាសាលាបឋមសិក្សាពេញលក្ខណៈ ២១៨០

១០-៦-២០០៣ -ប្រកាសលេខ ៤៩៤ អយក.ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ **ត្រពាំងរុន** មកជាសាលាបឋមសិក្សាពេញលក្ខណៈ ២១៨១

១០-៦-២០០៣ -ប្រកាសលេខ ៤៩៥ អយក.ប្រក ស្ដីពីការបើកសាលាបឋមសិក្សា **ប្រទាំញ** ជាឧបសម្ព័ន្ធរបស់សាលា បឋមសិក្សា **២ ធ្នូ** ២១៨២

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៨៤

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ រីតារង្ស** ជាទីប្រឹក្សាផ្ទាល់ សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា មានឋានៈស្មើនឹង **រដ្ឋលេខាធិការ** ។

**មាត្រា២** : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០០៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

ការស.០៣.០៥.១៩៣ លេខៈ ១៥៦ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារ៉ាត់ សាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៨៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **ប៊ុន គឹមហេង** ជាឧបការីរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា មានឋានៈស្មើនឹង **អនុរដ្ឋលេខាធិការ** ។

**មាត្រា២** : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០០៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខៈ ១៥៧ ច ល

ចារឈ-០៣-០៥-១៩៤

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៣/១៨៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

## ត្រាស់បង្គាប់

មាត្រា ១ .–

ត្រូវបានកែសម្រួលថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ជូនឯកឧត្តម **ឡុង ទិសារលោ** ពីឧត្តមមន្ត្រីថ្នាក់លេខ ៤ ទៅជាឧត្តមមន្ត្រីថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ .–

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .–

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .–

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង.រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣រល.០៣.០៥.១៩៨

លេខៈ ១៥៩ ច ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៣/១៨៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **ស្រីយ សាត** ជាទីប្រឹក្សាផ្ទាល់ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា ទទួលបន្ទុក ផ្នែកទំនាក់ទំនងជាមួយសហគមន៍ខ្មែរ-អូស្ត្រាលី មានឋានៈស្មើនឹង **រដ្ឋលេខាធិការ** ។

**មាត្រា២** : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែ មិថុនា ឆ្នាំ ២០០៣
ឆ្លងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

លេខ: ១៥៥៤ ចល

៣រល.០៣.០៦.២០០

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណារី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៦០៣/ ១៩០

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើររបស់ស្តេចក្រុមឃុន ស៊ីសុវត្ថិ ជីវន្តមុនីរក្ស ប្រធានព្រឹទ្ធសភា ស្តីទី

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ចៅ គៀង** ជាទីប្រឹក្សាឯកឧត្តម **ញឹក ប៊ុនឆៃ** អនុប្រធានទី ២ នៃ ព្រឹទ្ធសភា មានឋានៈស្មើ **អគ្គនាយក** ជំនួសឯកឧត្តម **ម៉ឹង ហ៊ន** ដែលបានលាឈប់ពីពីមុខតំណែង ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០០៣

ឡាយព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

លេខ: ១៥៧៦ ល

**ជា ស៊ីម**

ចរល.០៣.០៦.២០១.

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារ៉ី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៣/១៩២

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តមបណ្ឌិតរដ្ឋ **តិច សំណាង** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣*

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

លេខៈ ៦៧០ ច ល

**ជា ស៊ីម**

៣រល.០៣.០៦.២០០៣

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខឹ តាន់**

# ព្រះរាជក្រឹត្យ

នស / រកត / ០៦០៣/១៩៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា)

## តែងតាំង

លោក ជួន ស៊ីវ៉េង

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ មិថុនា ឆ្នាំ ២០០៣
ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ: ១៧១ ចល

៣៤ល.០៣.០៦.២០៤

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
[signature]
ណារ៉ុង តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៣

**លេខ : 011/2003 កបធ.សជា**

# ជំរាបមក

**លោក ទី ធីឡា**

អាស័យដ្ឋានផ្ទះលេខ ៥៤៧ ក្រុមទី ៤ ភូមិដីណាក់ធំ

សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

**កម្មវត្ថុ :** ប្តឹងបដិសេធសេចក្តីសម្រេចលេខ ០៥.៣២៤/០៣ គ.ជ.ប ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**យោង :** លិខិតរបស់លោក លេខ ពិសេស គ.ក.ខ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៣

តបតាមលិខិតរបស់លោកដូចមានក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសជំរាបលោកថា ក្រុម-ប្រឹក្សាធម្មនុញ្ញពុំអាចទទួលពាក្យបណ្តឹងរបស់លោកយកមកពិនិត្យពិភាក្សាបានទេ ដោយករណីដែលលោកបានលើកឡើង មិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

ក្រុមប្រឹក្សាធម្មនុញ្ញទទួលពិនិត្យបានតែករណីដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធមិនព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា៤២ ថ្មីនៃព្រះរាជក្រម នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

រឿងជម្លោះរវាងលោក និង ឈ្មោះ **ទី ឈិន** ជារឿងក្តីរដ្ឋប្បវេណី ដែលស្ថិតនៅក្នុងសមត្ថកិច្ចតុលាការតែប៉ុណ្ណោះ ។

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ 012/2003 កបធ.

រាជធានីភ្នំពេញ, ថ្ងៃទី 06 ខែ មិថុនា ឆ្នាំ 2003

**ជំរាបមក**

**លោក លឹវ អាន ប្រធានគណបក្សចំរើននិយមខ្មែរ**

**កម្មវត្ថុ** : អំពីបណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៥.៧៩៦/០៣ គ.ជ.ប ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៣

**យោង** : លិខិតរបស់លោក លេខ ១០៤/០៣ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៣

តបតាមលិខិតរបស់លោកដូចមានក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយសជំរាបលោកថា ក្រុម-ប្រឹក្សាធម្មនុញ្ញ ពុំអាចអនុគ្រោះតាមសំណូមពររបស់លោកបានទេ ពីព្រោះការដែលមិនបានបំពេញបន្ថែមល័ក្ខខ័ណ្ឌទាំងពីរចំណុច គឺចំណុចទី៤ និង ចំណុចទី១០ នៃមាត្រា ៣៧ ថ្មីនោះ ឱ្យទាន់ក្នុងរយៈពេលកំណត់ដោយច្បាប់ត្រូវចាត់ទុកថា គណបក្សលោកបានបោះបង់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដូចមានចែងក្នុងវាក្យខ័ណ្ឌចុងក្រោយនៃ មាត្រា ៤០ថ្មី នៃព្រះរាជក្រម នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រហើយ ។

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ
ប្រធាន

ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ 013/03 កបធ. ...

រាជធានីភ្នំពេញ, ថ្ងៃទី ...ខែ...ឆ្នាំ ...

**ជំរាបមក**

**លោក ឡេង សេង ប្រធានគណបក្សកសាងជាតិ**

**កម្មវត្ថុ** : អំពីបណ្តឹងតវ៉ាលើសេចក្តីប្រកាសបដិសេធការចុះបញ្ជីគណបក្សកសាងជាតិ ឈរឈ្មោះបោះឆ្នោត

**យោង** - សេចក្តីសំរេចរបស់គ.ជ.ប លេខ ០៥.៧៩៧/០៣ គ.ជ.ប ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៣

- ពាក្យបណ្តឹងលេខ ០២៩/០៣ គកជ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៣ របស់គណបក្សកសាងជាតិ

តបតាមលិខិតរបស់លោកដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសជំរាបលោកថា ក្រុមប្រឹក្សាធម្មនុញ្ញ ពុំអាចអនុគ្រោះតាមសំណូមពររបស់លោកបានទេ ពីព្រោះការដែលមិនបានបំពេញបន្ថែមល័ក្ខខ័ណ្ឌទី១០ នៃមាត្រា៣៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនោះ ឱ្យទាន់ក្នុងរយៈពេលកំណត់ដោយច្បាប់ ត្រូវចាត់ទុកថាគណបក្សលោកបានបោះបង់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដូចមានចែងក្នុងវាក្យខ័ណ្ឌចុងក្រោយនៃ មាត្រា ៤០ថ្មី នៃព្រះរាជក្រម នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រហើយ ។

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ
ប្រធាន

ប៊ិន ឈិន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ,ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១. ចុះថ្ងៃទី ៣០ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រិត្យ លេខ ១៣១ អនក្រ.បក.ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.០០០ លានរៀល ( មួយពាន់លានរៀលគត់ ) ពីជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយពិសេសរបស់រាជរដ្ឋាភិបាល ដើម្បីជួសជុលទព្វសំភារៈបច្ចេកទេសសំរាប់ឆ្នាំ ២០០៣ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**រដ្ឋមន្ត្រីស្តីទី**

**អ៊ុក រ៉ាប៊ុន**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកែសម្រួល

## ផ្លាកសញ្ញារូបហនុមាន សញ្ញាកងឯកភាពធំត្រួយោធ ឯកសណ្ឋានការងារលេខ៤ មួកបោនណេ ការស្លៀកពាក់ឯកសណ្ឋានការងារលេខ៤ និងសញ្ញាអគ្គបញ្ជាការ កងទ័ពជើងគោក ជើងទឹក ជើងអាកាស និង រូបសញ្ញាក្រសួងការពារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ ន.ស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ន.ស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីវិសោធនកម្ម អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ ត្រង់មាត្រា ១-២-៣ និង ៨ ពាក់ព័ន្ធនឹងឯកសណ្ឋានកងទ័ពជើងគោក កងនាវាចរ កងអាកាសចរ ឯកសណ្ឋានត្រៃទ័ព និងកងកិត្តិយស
- បានឃើញអនុក្រឹត្យលេខ ៨៦អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០១ ស្តីពីការកែសំរួល បង្កើតផ្លាកសញ្ញាមួយចំនួន បំពេញបន្ថែមលើមាត្រា ៦ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សំរេច

**មាត្រា ១.**_

ផ្លាកសញ្ញារូបហនុមាន សញ្ញាកងឯកភាពឆ័ត្រយោង ឯកសណ្ឋានការងារ(លេខ៤) មួកបេរេទណេ សញ្ញាអគ្គបញ្ជាការ កងទ័ពជើងគោក កងទ័ពជើងទឹក កងទ័ពជើងអាកាស និងសញ្ញាក្រសួងការពារជាតិ ត្រូវបានកែសម្រួលដូចតទៅ ÷

១. **ផ្លាកសញ្ញារូបហនុមាន** ធ្វើរាងមេដៃ ពាក់បន្ទោងនៅខ្សែរហោប៉ៅអាវស្តាំ ផ្លាកសញ្ញាធ្វើអំពីលោហធាតុ ផ្នែកខាងលើ មានមកុដពណ៌មាស មានកាំរស្មីប្រាំពីរ សង្ខាងមានរំយោលម្ខាងបីពណ៌មាស (តំណាងឱ្យទង់ជាតិ) ផ្នែកកណ្តាល ពណ៌ទឹកប៊ិច លើផ្ទៃកណ្តាលមានរូបហនុមានកាន់ព្រះខ័ន្ធ កំពុងសំដែងឫទ្ធិ ពណ៌ស្វាទុំ នៅផ្នែកខាងក្រោមមាន ជើងពានរាងដូចស្នែងក្របី ផ្ទៃពណ៌ក្រហម រឹមជុំវិញ ពណ៌មាស នៅលើផ្ទៃនោះសរសេរអក្សរកាត់ថា (ខ.ន.ម ) ពណ៌មាស ។ រូបភាពនៃរូបសញ្ញាហនុមានថ្មីមានដូចក្នុងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

**ខ្នាត :** - កំពស់រូបភាព ៦០ម.ម ទទឹង ៤៥ម.ម
- កំពស់មកុដ ២៧ម.ម បាតក្រោមមកុដ ៣៤ម.ម
- ផ្ទៃពណ៌ខៀវកណ្តាល កំពស់ ៣២ម.ម ទទឹង ៣០ម.ម ហនុមាន កំពស់ ២៤ម.ម ទទឹង ២៤ម.ម
- រំយោលសង្ខាង ប្រវែងទី១ : ១៦ម.ម ទី២ : ១៤ម.ម ទី៣ : ១២ម.ម
- ជើងពានផ្នែកខាងក្រោមមានរាងដូចស្នែងក្របី បណ្តោយប្រវែង ៣៤ម.ម ទទឹង ៦ម.ម អក្សរកំពស់ ៤ម.ម
- សញ្ញាដាក់លើស្បែកសំរាប់ពាក់នឹងខ្សែរហោប៉ៅអាវស្តាំ ប្រវែងស្បែកពីលើមកក្រោម ១០០ម.ម

២. សញ្ញាកងឯកភាពឆ័ត្រយោងមាន ៦ប្រភេទ ៖

១. ផ្លាកសញ្ញាជំនាញឆ័ត្រយោងស្តាទិក (Static line)

សញ្ញានេះផលិតអំពីលោហធាតុ សំរាប់យោធិន ដែលបានឆ្លងកាត់វគ្គហ្វឹកហ្វឺនឆ័ត្រយោង ចប់ជាស្ថាពរ ពាក់នៅលើហោប៉ៅអាវស្តាំ ។ សញ្ញានេះសំរាប់ដាក់លើសញ្ញាបត្រឆ័ត្រយោង ។

២. ផ្លាកសញ្ញាជំនាញឆ័ត្រយោងយោធាចារ្យ (Jump Master) ៖

រូបសញ្ញានេះផលិតអំពីលោហធាតុ សំរាប់យោធាចារ្យឆ័ត្រយោង ពាក់នៅលើហោប៉ៅអាវស្តាំ ។ សញ្ញានេះសំរាប់ដាក់លើសញ្ញាបត្រឆ័ត្រយោងយោធាចារ្យ ។

៣. ផ្លាកសញ្ញាជំនាញឆ័ត្រយោងបញ្ហា (Tree Fall) ៖

រូបសញ្ញានេះផលិតអំពីលោហធាតុ សំរាប់យោធិន និងយោធាចារ្យឆ័ត្រយោង ដែលបានឆ្លងកាត់វគ្គហ្វឹកហ្វឺនឆ័ត្រយោងបញ្ហា ចប់ជាស្ថាពរ ពាក់នៅលើហោប៉ៅអាវខាងស្តាំ ។ សញ្ញានេះសំរាប់ដាក់នៅលើសញ្ញាបត្រឆ័ត្រយោងបញ្ហា ។

៤. ផ្លាកសញ្ញាកុម្មង់ដូ (Commando) ៖

រូបសញ្ញានេះផលិតអំពីលោហធាតុ សំរាប់យោធិន ដែលបានឆ្លងកាត់វគ្គហ្វឹកហ្វឺនកុម្មង់ដូ ចប់ជាស្ថាពរ ពាក់នៅលើហោប៉ៅអាវស្តាំ ។ សញ្ញានេះសំរាប់ដាក់នៅលើសញ្ញាបត្រកុម្មង់ដូ ។

៥. ផ្លាកសញ្ញាកងទ័ពពិសេសឆ័ត្រយោង ៖

រូបសញ្ញានេះផលិតអំពីក្រណាត់ប៉ាក់ជាអក្សរ (កងទ័ពពិសេស) ប៉ាក់ពណ៌ក្រហម និងអក្សរ (ឆ័ត្រយោង) ប៉ាក់ពណ៌លឿង សំរាប់ប្រើលើឯកសណ្ឋានលេខ ២-៣-៤ ។ ចំពោះឯកសណ្ឋានលេខ ៥ អក្សរ (កងទ័ពពិសេស) ប៉ាក់ពណ៌ខ្មៅ និងអក្សរ (ឆ័ត្រយោង) ប៉ាក់ពណ៌ខ្សៀវ ។ ផ្លាកសញ្ញានេះសំរាប់ពាក់នៅដើមដៃខាងស្តាំ នៅពីលើសញ្ញាកងយោធពលខេមរភូមិន្ទ ។

៦. ផ្លាកសញ្ញាជំនាញឯកទេសមុជទឹក (Scuba-diving) ៖

រូបសញ្ញានេះផលិតអំពីលោហធាតុ សំរាប់យោធិន ដែលបានឆ្លងកាត់វគ្គហ្វឹកហ្វឺនទ័ពពិសេសក្នុងផ្ទៃទឹក ចប់ជាស្ថាពរ ពាក់នៅលើហោប៉ៅអាវខាងស្តាំ ។ សញ្ញានេះសំរាប់ដាក់នៅលើសញ្ញាបត្រទ័ពពិសេស ក្នុងផ្ទៃទឹក ។

ចំពោះរូបភាព និងខ្នាតនៃផ្លាកសញ្ញា ទ័ពពិសេសឆ័ត្រយោងទាំង ៦ប្រភេទនេះ មានរូបភាព និងខ្នាត ដូចមានក្នុងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

៣. ឯកសណ្ឋានការងារ (លេខ៥) ៖ គំរូឯកសណ្ឋាននេះមានពីរសំរាប់គឺ ÷

១. ឯកសណ្ឋានការងារដៃខ្លី ៖

- ឯកសណ្ឋានការងារដៃខ្លី អាវពណ៌ត្រែអ៊ីកាត់ស្រុងដាក់ក្នុងខោ ហើយខោពណ៌ត្រែអ៊ី
- អាវដៃខ្លី ពណ៌ត្រែអ៊ី កខុប ប៉ូលស្មាសង្ខាង កាត់ស្រុងវែងដាក់ក្នុងខោ ហោប៉ៅពីរដេរប៉ះចំកណ្ដាល ដេរបត់ផ្នត់មានគំរបរាងស្នឹកពោធិ ឡេវធម្មតាពណ៌ត្រែអ៊ី
- ខោជើងវែង (ដូចឯកសណ្ឋានលេខ៣) ពណ៌ត្រែអ៊ី
- មួកបេរេពណ៌ត្រែអ៊ី នៅស្រទាប់មួកមានចំណាំមាសតាមបណ្ដោយទំហំ ៨ ម.ម

ហ ៤

- ខ្សែក្រវ៉ាត់តូចពណ៌ត្រែអ៊ី (ដូចខ្សែក្រវ៉ាត់ឯកសណ្ឋានលេខ១)

**២. ឯកសណ្ឋានការងារដៃវែង :**

- ឯកសណ្ឋានការងារដៃវែង មានរូបភាពនិងម៉ូត ដូចឯកសណ្ឋានការងារដៃខ្លីខាងលើ តែមានដៃវែងនៅចុងដៃ អាវមានផែក និងដាក់ឡេវ ។
- ខោ មួក ដូចឯកសណ្ឋានការងារដៃខ្លី ។
- ចំពោះនារី អាវដូចបុរស ខោជើងវែងកាត់ដូចបុរស ឡេវចំហៀង ឬសំពត់ហ្សីបមានផែកពីក្រោយពណ៌ត្រែអ៊ីក្រោមជង្គង់ ។

⁕ ឯកសណ្ឋានការងារ(លេខ៤)នេះ សំរាប់ពាក់ធ្វើការងារធម្មតាក្នុងការិយាល័យ ឬក្នុងបន្ទាយ និងទំនាក់ទំនងការងារធម្មតា។

**គ្រឿងស្លៀកពាក់ :** ពាក់អាវដៃខ្លី ឬដៃវែងពណ៌ត្រែអ៊ី នៅដៃអាវខាងស្តាំដាក់ផ្លាកកងយោធពលខេមរភូមិន្ទ និងនៅដៃអាវខាងឆ្វេងពាក់ផ្លាកកងឯកភាព(បើមាន) ។ ខោជើងវែងពណ៌ត្រែអ៊ី ខ្សែក្រវ៉ាត់តូចពណ៌ត្រែអ៊ី មួកបេរ៉េពណ៌ត្រែអ៊ី មានរូបព្រះសង្ហានៅខាងមុខផ្នែកខាងស្តាំ និងមានសញ្ញាសក្តិនៅខាងមុខផ្នែកខាងឆ្វេង ស្បែកជើងស្បែកកខ្លីពណ៌ខ្មៅ និងស្រោមជើងខ្មៅ ។ ពាក់សញ្ញាប្រភេទទ័ពនៅកអាវ ផ្លាកឈ្មោះនៅខាងលើហោប៉ៅអាវស្តាំ ហានុមានពាក់នៅនឹងឡេវហោប៉ៅអាវស្តាំ សក្តិនៅលើស្មាដែលមានហ្វុងសក្តិខ្មៅក្បាលស្រួច និងពាក់ក្បាលមេដាយ (បើមាន) អាវជានិច្ចកាលត្រូវដាក់ក្នុងខោ ។ ចំពោះកងនាវាចរ និងអាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានការងារ តាមការកំណត់ខាងលើ ហើយពាក់គ្រឿងរួមផ្សំផ្សេង១ទៀត និងរបៀបប្រើប្រាស់ដូចទ័ពជើងគោក តែកងអាកាសចរ និងបណ្ណាកងឯកភាព ដែលមានសញ្ញាលើហោប៉ៅអាវស្តាំ លើផ្លាកឈ្មោះ ត្រូវពាក់ថែមទៀត ។

ចំពោះរូបភាពនៃឯកសណ្ឋានការងារដៃខ្លីនិងដៃវែងមានគំរូក្នុងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ។

**៤. មួកបេរ៉េ :**

- ថ្នាក់ឧត្តមសេនីយ៍ មួកបេរ៉េ ពណ៌ត្រែអ៊ី មានចំពណ៌មាស តាមបណ្តោយស្រទាប់មួក ទំហំ ៨ ម.ម
- ថ្នាក់វរសេនីយ៍ មួកបេរ៉េ ពណ៌ត្រែអ៊ី មានចំពណ៌ក្រហម តាមបណ្តោយស្រទាប់មួក ទំហំ ៥ ម.ម
- ថ្នាក់អនុសេនីយ៍ មួកបេរ៉េ ពណ៌ត្រែអ៊ី មានចំពណ៌ទឹកប្រាក់ តាមបណ្តោយស្រទាប់មួក ទំហំ ៥ ម.ម

នៅខាងមុខមួកបេរ៉េ ផ្នែកខាងស្តាំមានរូបព្រះសង្ហា ផលិតអំពីលោហធាតុពណ៌មាស នៅខាងមុខមួកផ្នែកខាងឆ្វេង មានសញ្ញាសក្តិ ។

ថ្នាក់ឧត្តមសេនីយ៍ សញ្ញាសក្តិ (ផ្កាយ) មានកំពស់ ១៤ ម.ម ផលិតអំពីលោហធាតុពណ៌មាសតម្រៀបគ្នាដូចសក្តិស្មា ។

ថ្នាក់វរសេនីយ៍ និងថ្នាក់អនុសេនីយ៍ សញ្ញាសក្តិប៉ាក់អំពីក្រណាត់មានទំហំបណ្តោយ ៣៥ ម.ម ទទឹង ២៨ ម.ម ។

ចំពោះរូបភាពនៃមួកបេរ៉េ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យនេះ ។

**៥. សញ្ញាអគ្គបញ្ជាការ :**

សញ្ញាអគ្គបញ្ជាការប្រភេទ ១ ដែលមានរូបភាពនិងខ្នាត ត្រូវបានកំណត់ដូចតទៅ ÷

**សញ្ញាអគ្គបញ្ជាការ ប្រភេទ ១** : មានរាងពងក្រពើ គ្មានហ្វុងនៅពីក្រោយ ដែលមានកំពស់ប្រវែង ៤៤ ម.ម បណ្ដោយ ៤៧ ម.ម នៅជុំវិញមានរចនាលំអដោយក្បូរស្រូវពីរកោងរាងស្នែងក្របី ដែលតំណាងឱ្យប្រជារាស្ត្រ។ នៅចំកណ្ដាលមានផ្កាយពណ៌មាសនិងខៀវ មានជ្រុងប្រាំបី ដែលតំណាងឱ្យឫទ្ធីបារមីទិសទាំងប្រាំបី ។ នៅចំកណ្ដាលផ្កាយ មានផ្ដិប្រសព្វដោយរូបលំពែងត្រីសូល្យ ក្រោមរូបមកុដរាជ្យដែលមានកាំរស្មីប្រាំពីរ ស្លាបសត្វហង្ស និងយុថ្កាពណ៌មាស ដែលតំណាងឱ្យកងទ័ពទាំងបីប្រភេទ ។

រូបសញ្ញានេះផលិតពីលោហធាតុ សំរាប់ពាក់នៅលើហោប៉ៅអាវស្ដាំ ពីលើផ្លាកឈ្មោះ នៃឯកសណ្ឋានលេខ ២-៣-៤ ។ សញ្ញានេះសំរាប់ដាក់នៅលើក្បាលលិខិត នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ អគ្គបញ្ជាការដ្ឋាន និង អង្គភាពចំណុះផ្ទាល់ ។

រូបភាព នៃសញ្ញាអគ្គបញ្ជាការ ប្រភេទទី ១ មានគំរូក្នុងឧបសម្ព័ន្ធទី ៥ នៃអនុក្រឹត្យនេះ ។

## ៦. សញ្ញាកងទ័ពជើងគោក :

សញ្ញាកងទ័ពជើងគោក ប្រភេទ ១ ដែលមានរូបភាព និងខ្នាត ត្រូវបានកំណត់ដូចតទៅ ÷

**សញ្ញាកងទ័ពជើងគោក ប្រភេទ ១** : មានរាងពងក្រពើ ពណ៌ទឹកមាស ពណ៌ស ដែលមានកំពស់ ៤៨ ម.ម បណ្ដោយប្រវែង ៥០ ម.ម ។ នៅខាងក្រោមចំកណ្ដាលមានក្បាច់ដកចន្ទី និង មានក្បូរស្រូវព័ទ្ធជុំវិញជារង្វង់ស្នែងក្របី ។ នៅចំកណ្ដាល មានទង់ជាតិដែលមានរាងជាខែល និងមានរូបប្រាសាទអង្គរ ។ រូបមកុដរាជ្យមានកាំរស្មីប្រាំពីរពីលើរូបលំពែងត្រីសូល្យពណ៌មាស ។ដាវនិងកាំភ្លើងពណ៌មាស ដាក់ខ្វែងគ្នាតំណាងឱ្យកងទ័ពជើងគោក ។

រូបសញ្ញានេះផលិតពីលោហធាតុ សំរាប់ពាក់នៅលើហោប៉ៅអាវស្ដាំ ពីលើផ្លាកឈ្មោះ នៃឯកសណ្ឋានលេខ ២-៣-៤ ។ សញ្ញានេះសំរាប់ដាក់លើក្បាលលិខិត នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ បញ្ជាការដ្ឋានកងទ័ពជើងគោក និងអង្គភាពចំណុះ។

រូបភាព នៃសញ្ញាកងទ័ពជើងគោក ប្រភេទទី ១ មានដូចក្នុងឧបសម្ព័ន្ធទី ៦ នៃអនុក្រឹត្យនេះ ។

## ៧. សញ្ញាកងទ័ពជើងទឹក :

សញ្ញាកងទ័ពជើងទឹក ប្រភេទ ១ ដែលមានរូបភាពនិងខ្នាត ត្រូវបានកំណត់ដូចតទៅ ÷

**សញ្ញាកងទ័ពជើងទឹក ប្រភេទ ១** : មានរាងជាទឹករលកពីរជាន់តំណាងផ្ទៃសមុទ្រ ដែលមានកំពស់ ៤៦ ម.ម និងបណ្ដោយ ៧០ ម.ម ។ នៅចំកណ្ដាលទឹករលកមានរូបមកុដរាជ្យ ដែលមានកាំរស្មីប្រាំពីរ និងរូបយុថ្កាដែលតំណាងឱ្យកងទ័ពជើងទឹក ។

រូបសញ្ញានេះផលិតពីលោហធាតុ សំរាប់ពាក់នៅលើហោប៉ៅអាវស្តាំ ពីលើផ្ទាកឈ្មោះ នៃឯកសណ្ឋានលេខ ២-៣-៤ ។ សញ្ញានេះសំរាប់ដាក់លើក្បាលលិខិត នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ បញ្ជាការដ្ឋានកងទ័ពជើងទឹក និងអង្គភាពចំណុះ ។

រូបភាព នៃសញ្ញាកងទ័ពជើងទឹក ប្រភេទទី ១ មានដូចក្នុងឧបសម្ព័ន្ធទី ៧ នៃអនុក្រឹត្យនេះ ។

**៨. សញ្ញាកងទ័ពជើងអាកាស :**

សញ្ញាកងទ័ពជើងអាកាសមាន ១ប្រភេទ ដែលមានរូបភាពនិងខ្នាត ត្រូវបានកំណត់ដូចតទៅ ÷

រូបស្លាបសត្វហង្សដែលជានិមិត្តសញ្ញាកងទ័ពជើងអាកាស មានកំពស់ ៤៣ ម.ម និងបណ្តោយ ៨០ ម.ម ។ នៅចំកណ្តាលស្លាបសត្វហង្សខាងលើ មានរូបមកុដរាជ្យ មានការ៉ស្មីធំប្រាំពីរ ការ៉ស្មីតូចប្រាំពីរ ផ្នែកខាងក្រោមមានទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានរាងដូចខែល ។

រូបសញ្ញានេះផលិតពីលោហធាតុ សំរាប់ពាក់នៅលើហោប៉ៅអាវស្តាំ ពីលើផ្ទាកឈ្មោះ នៃឯកសណ្ឋានលេខ ២-៣-៤ ។ សញ្ញានេះសំរាប់ដាក់លើក្បាលលិខិត នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ បញ្ជាការដ្ឋានកងទ័ពជើងអាកាស និងអង្គភាពចំណុះ ។

រូបភាព នៃសញ្ញាកងទ័ពជើងអាកាស មានដូចក្នុងឧបសម្ព័ន្ធទី ៨ នៃអនុក្រឹត្យនេះ ។

**៩. រូបសញ្ញាក្រសួងការពារជាតិ :**

រូបសញ្ញានេះផលិតពីលោហធាតុ ត្រូវបានពាក់នៅលើហោប៉ៅអាវឆ្វេង នៃឯកសណ្ឋានលេខ ២-៣-៤។ សញ្ញានេះសំរាប់ដាក់នៅ លើក្បាលលិខិត នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ ទីស្តីការក្រសួងការពារជាតិ និងអង្គភាពចំណុះផ្ទាល់ ។

រូបភាព នៃសញ្ញាក្រសួងការពារជាតិ ត្រូវបានកំណត់ដូចក្នុងឧបសម្ព័ន្ធទី ៩ នៃអនុក្រឹត្យនេះ ។

**មាត្រា ២._**

ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន មានសិទ្ធិចេញសេចក្តីប្រកាស ក្នុងការបង្កើតសញ្ញាសំគាល់ឱ្យបណ្តាស្ថាប័ន និងកងឯកភាពចំណុះ ។

**មាត្រា ៣._**

មាត្រា៥ ចំណុច ខ២ មាត្រា៦ ចំណុចទី២១ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ មាត្រា១ ចំណុចក៤ មាត្រា៤ ចំណុចទី៤ នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០០ មាត្រា ១ ចំណុច ក១ - ខ១ - គ១ - ឃ១ - ង នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០១ និង បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃ កងយោធពលខេមរភូមិន្ទ និងក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ដោយចូលជាធរមាន ចាប់ពីថ្ងៃ ដែលបានចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី**

**សហរដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ទៀ បាញ់** **ស៊ីសុវត្ថិ សិរីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ.៤៥ អនក្រ.បក
## ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣
## ស្ដីពីផ្លាកសញ្ញារូបហនុមាន



# ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ.៤៥.អនក្រ.បក
## ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៣
## ស្តីពីសញ្ញាកងឯកភាពឆ័ត្រយោង

ឯកសណ្ឋានការងារ — ឯកសណ្ឋានប្រយុទ្ធ

១. ផ្លាកជំនាញឆ័ត្រយោងស្ថានិក ៧០មម × ២៥មម





២. ផ្លាកជំនាញឆ័ត្រយោងយោធាចារ្យ ៧០មម × ៣០មម





៣. ផ្លាកជំនាញឆ័ត្រយោងបញ្ជា ៧០មម × ៣០មម





៤. ផ្លាកជំនាញកម្មង់ដូ ៤៥មម × ៥២មម





៥. ផ្លាកជំនាញកម្មង់ដូឆ័ត្រយោង ៧០មម × ៣០មម






៦. ផ្លាកជំនាញឯកទេសមុជទឹក ៤៥មម × ៥២មម





ឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យលេខ ៤៥.អនក្រ.បក

ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

## ស្តីពីឯកសណ្ឋានការងារដៃខ្លី និង ដៃវែង





# ឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យលេខ.៤៥.អនក្រ.បក

ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០៣

## ស្តីពីមួក ឃោណោ



## ឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក

## ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

## ស្តីពីផ្លាកសញ្ញាអគ្គបញ្ជាការ

### ប្រភេទ ១



# ឧបសម្ព័ន្ធទី៦ នៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក
## ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣
## ស្ដីពីផ្លាកសញ្ញាកងទ័ពជើងគោក

### ប្រភេទ ១



## ឧបសម្ព័ន្ធទី៧ នៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក
## ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣
## ស្តីពីផ្លាកសញ្ញាកងទ័ពជើងទឹក

### ប្រភេទ ១



## ឧបសម្ព័ន្ធទី៨ នៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក
## ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣
## ស្តីពីសញ្ញាកងទ័ពជើងអាកាស



## ឧបសម្ព័ន្ធទី៩ នៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក

ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

## ស្ដីពីផ្លាកសញ្ញាក្រសួងការពារជាតិ



# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា — ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៨១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- យោងតាមសំណើរបស់ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

## សំរេច

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់ពីបេសកកម្ម តួនាទី ភារកិច្ច និង ការរៀបចំនិងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ហៅកាត់ថា **គ.ឧ.ក**។

### ជំពូកទី២
### បេសកកម្ម តួនាទី និង ភារកិច្ច

**មាត្រា២.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ឧ.ក**មានបេសកកម្ម អនុវត្តនូវគ្រប់ការងាររបស់ **គ.ឧ.ក**។ ក្នុងបេសកកម្មនេះអគ្គលេខាធិការដ្ឋាននៃ **គ.ឧ.ក** មានតួនាទី និង ភារកិច្ច ដូចខាងក្រោមៈ

- រៀបចំគោលនយោបាយនៃការទទួលស្គាល់គុណភាពអប់រំ និង រៀបចំវិធានការចាំបាច់នានាដើម្បីធានា

គុណភាពអប់រំ

- រៀបចំបង្កើត និងកែលំអស្តង់ដារគុណភាពអប្បបរមាមូលដ្ឋាន ដើម្បីធានាគុណភាពអប់រំ ឧត្តមសិក្សា
- ធ្វើការអង្កេត ត្រួតពិនិត្យ វាយតំលៃលើប្រព័ន្ធគ្រប់គ្រង និងកម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សា
- លើកសំណើផ្តល់ការទទួលស្គាល់គុណភាពអប់រំដល់គ្រឹះស្ថានឧត្តមសិក្សា ជូន **គ.ឧ.ក** ដើម្បីសំរេចតាមនីតិវិធី
- លើកសំណើស្តីពីការយល់ព្រមលើកម្មវិធីសិក្សាឆ្នាំមូលដ្ឋានចំពោះនិស្សិតឆ្នាំទីមួយ នៃគ្រឹះស្ថានឧត្តមសិក្សាជូន **គ.ឧ.ក** ដើម្បីសំរេចតាមនីតិវិធី
- លើកសំណើផ្តល់ចំណាត់ថ្នាក់ដល់គ្រឹះស្ថានឧត្តមសិក្សា ជូន **គ.ឧ.ក** ដើម្បីសំរេច តាមនីតិវិធី
- ធ្វើការសំរបសំរួល និងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ភ្នាក់ងារ អង្គការ ជាតិ អន្តរជាតិនានា និងស្ថាប័នឯកជនពាក់ព័ន្ធនឹងកិច្ចការ អប់រំនៅកំរិតឧត្តមសិក្សា និងក្រោយឧត្តមសិក្សា
- លើកអនុសាសន៍កែលំអគុណភាពអប់រំ នៃគ្រឹះស្ថានឧត្តមសិក្សាជូន **គ.ឧ.ក** ដើម្បីសំរេចតាមនីតិវិធី
- ធ្វើការសិក្សាអំពីដំណើរការអភិវឌ្ឍន៍ និងតំរូវការទាក់ទងនឹងធនធានមនុស្ស ដើម្បីកែលំអស្តង់ដារគុណភាពអប្បបរមាមូលដ្ឋាន សំរាប់ទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សានៅកម្ពុជា
- ធានាអោយមានការចូលរួមសមស្រប ពីអ្នកពាក់ព័ន្ធទាក់ទងនឹងលទ្ធផលរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ដែលបានដាក់ពាក្យសុំទទួលស្គាល់គុណភាពអប់រំ
- ផ្សព្វផ្សាយជាសាធារណៈនូវ លទ្ធផលគំហើញរបស់ **គ.ឧ.ក** ក្នុងកិច្ចការងារនៃការទទួលស្គាល់គុណភាពអប់រំ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់អគ្គលេខាធិការ ជូន **គ.ឧ.ក** តាមការកំណត់ និង
- ភារកិច្ចដទៃទៀតដែលធ្វើអោយសំរេចបេសកកម្មរបស់ **គ.ឧ.ក** ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

**មាត្រា៣.-**

អគ្គលេខាធិការដ្ឋានរបស់ **គ.ឧ.ក** ជាអង្គភាពប្រតិបត្តិរបស់ **គ.ឧ.ក** ដែលដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើអនុរដ្ឋលេខាធិការ និងអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

អគ្គលេខាធិការរងទទួល ភារកិច្ចទទួលខុសត្រូវតាមការចាត់តាំងរបស់អគ្គលេខាធិការ ។

**មាត្រា៤.-**

អគ្គលេខាធិការដ្ឋានរបស់ **គ.ឧ.ក** បែងចែកជាបីនាយកដ្ឋានគឺៈ

១. នាយកដ្ឋាន កិច្ចការទូទៅ

២. នាយកដ្ឋាន ស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំ

៣. នាយកដ្ឋាន សហប្រតិបត្តិការ និងពត៌មាន

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូប និង អមដោយអនុប្រធានមួយចំនួន តាមការចាំបាច់។ នាយកដ្ឋាននីមួយៗ ត្រូវមានការិយាល័យចំណុះមួយចំនួន តាមការចាំបាច់។ តួនាទី និងភារកិច្ចរបស់ ការិយាល័យ និង ការបង្កើតឬការលុបចោលការិយាល័យត្រូវសំរេចដោយ **គ.ឧ.ក** តាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា៥.-**

ប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានរបស់ **គ.ឧ.ក** ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ នៃអគ្គលេខាធិការដ្ឋានរបស់ **គ.ឧ.ក**ត្រូវតែងតាំង ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា៦.-**

នាយកដ្ឋានកិច្ចការទូទៅមានភារៈកិច្ចដូចតទៅៈ

- ធានាប្រសិទ្ធភាព និង និរន្តរភាពនៃដំណើរការរដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- ទទួលបន្ទុកការងារពិធីការ ការរៀបចំពិធី និងសិក្ខាសាលាផ្សេងៗ
- ទទួលខុសត្រូវលើការងាររដ្ឋបាលទូទៅ ការងារនីតិកម្ម និងការងារគ្រប់គ្រងបុគ្គលិក
- រៀបចំគំរោងចំណូល-ចំណាយថវិកាប្រចាំឆ្នាំ
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ និង បញ្ជីសារពើភណ្ឌ
- ផ្គត់ផ្គង់សំភារៈ បរិក្ខារ និងការចំណាយផ្សេងៗ សំរាប់ដំណើរការរបស់អគ្គលេខាធិការដ្ឋាន
- លើកសំណើតាមនីតិវិធី ដើម្បីសុំការសំរេចលើគំរោងចំណាយផ្សេងៗ
- ធ្វើទំនាក់ទំនងលើបញ្ហាថវិកាជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គការនានា និង ស្ថាប័នដែលពាក់ពន្ធ័
- រក្សាទុកឯកសារពាក់ព័ន្ធនឹងការវាយតម្លៃ ចំពោះគ្រឹះស្ថានឧត្តមសិក្សានីមួយៗ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ខ្លួនតាមការកំណត់ និង
- អនុវត្តភារៈកិច្ចមួយចំនួនទៀតតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាន។

**មាត្រា៧.-**

នាយកដ្ឋានស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំមានភារៈកិច្ចដូចតទៅ:

- រៀបចំបង្កើត និងកែលំអស្តង់ដារគុណភាពអប្បបរមាមូលដ្ឋានសំរាប់ជាលក្ខណវិនិច្ឆ័យលើគ្រឹះស្ថានឧត្តមសិក្សា
- រៀបចំបង្កើត និងកែលំអគោលការណ៍ណែនាំសំរាប់គ្រឹះស្ថានឧត្តមសិក្សាដើម្បីឈានដល់ស្តង់ដារគុណភាពអប្បបរមាមូលដ្ឋាន ដែលបានកំណត់
- ធានាអោយមានការចូលរួមសមស្របពីអ្នកពាក់ព័ន្ធទាក់ទងនឹងលទ្ធផលរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗដែលបានដាក់ពាក្យសុំទទួលស្គាល់គុណភាពអប់រំ
- ពិនិត្យ និងលើកសំណើតាមនីតិវិធី ដើម្បីសុំការយល់ព្រមលើកម្មវិធីសិក្សាឆ្នាំមូលដ្ឋានចំពោះនិស្សិតឆ្នាំទីមួយថ្នាក់បរិញ្ញាប័ត្រ
- រៀបចំការចុះអង្កេត ត្រួតពិនិត្យ វាយតំលៃការគ្រប់គ្រងគុណភាពសិក្សា និងកម្មវិធីសិក្សា របស់គ្រឹះស្ថាន ឧត្តមសិក្សា។
- ពិនិត្យ និងលើកសំណើតាមនីតិវិធី ដើម្បីសុំផ្តល់ការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា
- ពិនិត្យ និងលើកសំណើតាមនីតិវិធី ដើម្បីសុំផ្តល់ការទទួលស្គាល់កំរិតចំណាត់ថ្នាក់គ្រឹះស្ថានឧត្តមសិក្សា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ខ្លួនតាមការកំណត់ និង
- អនុវត្តភារកិច្ចមួយចំនួនទៀតតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាន។

**មាត្រា៨.-**

នាយកដ្ឋានសហប្រតិបត្តិការ និងពិតមាន មានភារៈកិច្ចដូចតទៅ:

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន ក្រសួង អង្គការជាតិ អន្តរជាតិ និងប្រទេសនានា ដើម្បីពង្រឹង និង កែលំអស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- ធ្វើការសិក្សា ស្រាវជ្រាវលើការអភិវឌ្ឍន៍ និងតំរូវការធនធានមនុស្សដើម្បីជាជំនួយដល់ការបង្កើតនិងការអភិវឌ្ឍគោលនយោបាយទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលគំហើញរបស់ **គ.ឧ.ក** ក្នុងកិច្ចការងារនៃការទទួលស្គាល់គុណភាពអប់រំ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ខ្លួនតាមការកំណត់ និង
- អនុវត្តភារកិច្ចមួយចំនួនទៀតតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាន។

**មាត្រា៩.-**

អគ្គលេខាធិការ អគ្គលេខាធិការរង និង ប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋាន **គ.ឱ.ក** ត្រូវទទួលបានឋានន្តរស័ក្តិ និង ប្រាក់បំណាច់មុខងារ ស្របតាមមុខតំណែង ឬឋានៈនីមួយៗរបស់ខ្លួន។

**មាត្រា១០.-**

មន្ត្រីរាជការបំរើការងារនៅក្នុងអគ្គលេខាធិការដ្ឋានរបស់**គ.ឱ.ក** ត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការដែលស្ថិតក្នុងក្របខ័ណ្ឌមុខងារសាធារណៈរបស់រដ្ឋ។

ការរៀបចំឋានន្តរស័ក្ត ប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការទាំងអស់ នៃអគ្គលេខាធិការដ្ឋានរបស់ **គ.ឱ.ក** ជាបន្ទុករបស់ក្រសួង ឬស្ថាប័នសាមី។

**មាត្រា១១.-**

អគ្គលេខាធិការដ្ឋានរបស់ **គ.ឱ.ក** អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា តាមការចាំបាច់។ ប្រាក់បំណាច់ ឬប្រាក់ឈ្នួល របស់បុគ្គលិកជាប់កិច្ចសន្យា ត្រូវកំណត់ដោយសេចក្តីសំរេចរបស់**គ.ឱ.ក** តាមសំណើរបស់អគ្គលេខាធិការ។

## ជំពូកទី៤

## ថវិកា

**មាត្រា១២.-**

អគ្គលេខាធិការដ្ឋានប្រើប្រាស់ថវិការបស់ **គ.ឱ.ក** ដែលជាឧបសម្ព័ន្ធ នៃថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងដែលបានមកពីប្រភពផ្សេងៗទៀត សំរាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៣.-**

បែបបទ និងនីតិវិធីអនុវត្តការងារក្នុងអគ្គលេខាធិការដ្ឋានរបស់ **គ.ឱ.ក**ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងមួយ របស់អគ្គលេខាធិការដ្ឋាន។

**មាត្រា១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## អនាម័យនៃម្ហូបអាហារសំរាប់មនុស្ស

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួងសំរបសំរួលការត្រួតពិនិត្យគុណភាព សុវត្ថិភាព ផលិតផល និង សេវាកម្ម

-បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០១ កែសម្រួល និងបំពេញបន្ថែមអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួងសំរបសំរួលការត្រួតពិនិត្យគុណភាពសុវត្ថិភាព ផលិតផល និងសេវាកម្ម

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣

## សំរេច

# ជំពូកទី ១
## លក្ខណៈកំណត់ទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់វិធានទូទៅនៃអនាម័យរបស់ផលិតផល ដែលមានទិសដៅសំរាប់ជាម្ហូបអាហាររបស់មនុស្ស ទាំងចំពោះអ្វីដែលទាក់ទងនឹងគ្រឹះស្ថានផលិត ឬ និយោជិតដែលធ្វើការនៅទីនោះ ទាំងចំពោះលក្ខណៈនៃសហគ្គាករណ៍ ទាំងចំពោះបណ្តាចរិតលក្ខណៈអតិសុខុមជីវសាស្ត្រ និងអនាម័យនៃផលិតផលផ្ទាល់ផង ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាព អនុវត្តតាមគ្រប់ដំណាក់ តាំងពីពេលផលិតកម្មគ្រាដំបូងជាអាទិ៍ ការប្រមូលផល ការនេសាទ ការសម្លាប់សត្វ ការរិតទឹកដោះសត្វ ទាំងក្នុងពេលរៀបចំសំរាប់ផលិតសំរេច ពេលកែច្នៃ ពេលវេចខ្ចប់ ពេលស្តុកទុក ពេលដឹកជញ្ជូន ពេលចែកចាយ ពេលលើកដាក់រៀបចំ ពេលតាំងលក់ ឬ ក៏ពេលលក់វត្ថុធាតុដើម និងការប្រគល់ដល់ដៃអ្នកប្រើ ។ វិធានការនេះ មានគោលបំណងដើម្បីធ្វើអោយគ្រប់ការអនុវត្តទាំងនោះ បានសំរេចក្នុងលក្ខណៈសម្បត្តិ អាចទប់ស្កាត់ការចម្លង ការប្រែប្រួលអន់គុណភាព ឬ ខូចគុណភាព ឬ ការរីកសាយនៃអតិសុខុមប្រាណគ្រប់ប្រភេទ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយ ដូចតទៅ:

"ម្ហូបអាហារ" គឺជាសារធាតុទាំងអស់ ទោះត្រូវបានកែច្នៃទាំងស្រុង ត្រូវបានកែច្នៃពាក់កណ្តាលសំរេច ឬ មិនទាន់កែច្នៃក្តី ដែលមានទិសដៅសំរាប់ជាអាហាររបស់មនុស្ស ដោយរាប់បញ្ចូលទាំងភេសជ្ជៈ ស្ករកៅស៊ូ និងសារធាតុទាំងអស់ដែលត្រូវបានប្រើប្រាស់ក្នុងការផលិត ការរៀបចំផលិត និងការកែច្នៃ "ម្ហូបអាហារ" លើកលែងតែគ្រឿងសំអាង ឬ ថ្នាំជក់ ឬ សារធាតុដែលត្រូវបានប្រើសំរាប់តែជាឱសថ ។

"ការលាងសំអាត" គឺការបំបាត់ស្នាមប្រលាក់ សំណល់អាហារ ភាពគ្រេខ្វក់ ខ្លាញ់ ឬ បំបាត់វត្ថុធាតុមិនត្រូវការផ្សេងទៀត ។

"ការចម្លង" គឺវត្តមាននៃសារធាតុមិនត្រូវការគ្រប់ប្រភេទ ក្នុងផលិតផល ។

" ការសម្លាប់មេរោគ " គឺការបន្ថយចំនួនអតិសុខុមប្រាណ ដោយមិនធ្វើអោយខូចផលិតផលតាមវិធីសាស្ត្រគីមី និង/ឬ រូបសាស្ត្រប្រកបដោយលក្ខណៈអនាម័យរហូតដល់ទទួលបានកំរិតមួយ ដែលមិនបង្កអោយមានការចម្លង ប្រកបដោយគ្រោះថ្នាក់ដល់ផលិតផល ។

"សំបកវេចខ្ចប់" គឺជាសម្ភារៈប្រើសំរាប់វេចខ្ចប់ ដូចជា ដប ប្រអប់ធ្វើដោយក្រដាសរឹង កេស ទូមានខណ្ឌ និងថង់ ឬ សម្ភារៈសំរាប់រុំ ខ្ចប់ ដូចជាស្លឹក លោហធាតុ ក្រដាស ក្រដាសលាបប្រេងប៉ារ៉ាហ្វីន និងក្រណាត់ ។

" សហគ្គាករណ៍ " គឺការលាយផ្សំ ការកាន់ប៉ះពាល់ ការរៀបចំ ឬសកម្មភាពនានាផ្សេងទៀត ដែលប៉ះពាល់ដល់ម្ហូបអាហារ ។

## ជំពូកទី ២

## លក្ខណៈកំណត់ចំពោះកន្លែង អាគារ និង អាគារឧបសម្ព័ន្ធ

### មាត្រា ៤.-

កន្លែង ឬ អាគារ និងបណ្តាអាគារឧបសម្ព័ន្ធ ត្រូវតែមានទីតាំងស្ថិតក្នុងតំបន់មួយដែលមានលក្ខណៈសមស្រប នឹងសកម្មភាពសំរាប់អាគារនោះ។ អាគារ និងឧបសម្ព័ន្ធត្រូវតែស្អាត មានការថែទាំត្រឹមត្រូវល្អ និងមានទំហំសមាមាត្រទៅនឹងសកម្មភាពដែលមានដំណើរការនៅទីនោះ ដើម្បីចៀសវាងនូវប្រការដែលសម្ភារៈត្រូវដាក់គរលើគ្នា ឬ ក៏និយោជិត ត្រូវប្រជ្រៀតគ្នា។ បន្ទប់អាគារ និងអាគារឧបសម្ព័ន្ធ ត្រូវស្ថាបនាដើម្បីការពារពន្លឺកំដៅព្រះអាទិត្យ និងភាពក្រខ្វក់ពីខាងក្រៅជាអាទិ៍ ភាពក្រខ្វក់បណ្តាលមកពីធាតុអាកាសប្រែប្រួល ការចូលទឹក ការជ្រៀតចូល និងការរីកសាយ នៃសត្វល្អិតនៃពពួកសត្វកកេរ និងបណ្តាសត្វផ្សេងៗទៀត ។ សត្វពាហនៈត្រូវហាមឃាត់មិនអោយចេញចូលក្នុងទីនេះ ។ បន្ទប់អាគារ និង ឧបសម្ព័ន្ធមិនត្រូវមានការឆ្លងទាក់ទងគ្នាផ្ទាល់ជាមួយកន្លែងទុកខោអាវ បន្ទប់អនាម័យ ឬ បន្ទប់ទឹកឡើយ ។

### មាត្រា ៥.-

ក្នុងករណីចាំបាច់ ត្រូវមានប្រតិបត្តិការកំចាត់សត្វល្អិត សត្វកណ្តុរ និងពពួកសត្វកកេរ ចេញពីបណ្តាបន្ទប់អាគារ និងអាគារឧបសម្ព័ន្ធដើម្បីចៀសវាងនូវការចម្លងដល់ម្ហូបអាហារដែលនៅទីនោះ ។ ការសម្លាប់មេរោគក្នុងបន្ទប់អាគារទាំងនោះ ជាពិសេសការបាញ់ថ្នាំនឹងអាចធ្វើបានតែពេលដែលសកម្មភាពគ្រប់បែបនៃការផលិតកែច្នៃ ឬ វេចខ្ចប់ត្រូវបានបញ្ចប់ និងក្នុងល័ក្ខខ័ណ្ឌដែលផលិតផលម្ហូបអាហារស្ថិតនៅទីនោះ ត្រូវបានការពារដោយមានប្រសិទ្ធភាព ។ ការសំអាតបន្ទប់អាគារ ដែលបង្កអោយមានការហុយធូលីត្រូវហាមឃាត់ ។

**មាត្រា ៦.-**

កន្លែងសំរាប់ទទួល និងស្តុកទុកវត្ថុធាតុដើមត្រូវតែខណ្ឌដាច់ ពីកន្លែងដែលមានការរៀបចំ និងវេចខ្ចប់ផលិតផលសំរេចជាស្រេចរាល់ពេលដែលអាចធ្វើទៅបាន ដើម្បីចៀសវាងនូវការចម្លងគ្រប់ប្រភេទ ទៅលើផលិតផលសំរេចនោះ ។ កន្លែងនិងផ្នែកដែលប្រើប្រាស់សំរាប់ការស្តុកទុក ការផលិត ឬ ការចាត់ចែងទុកដាក់ផលិតផលអាចបរិភោគបាន ត្រូវតែខណ្ឌដាច់ដោយឡែកពីបណ្តាកន្លែង ឬ ផ្នែកប្រើប្រាស់សំរាប់ផលិតផលដែលមិនអាចបរិភោគបាន ។ ក្នុងលក្ខណៈដែលអាចធ្វើបានកន្លែងសំរាប់ការចាត់ចែងទុកដាក់ផលិតផលម្ហូបអាហារ ត្រូវតែខណ្ឌដាច់ពីបន្ទប់អាគារប្រើប្រាស់សំរាប់ការស្នាក់នៅ ។

សហគ្គករណ៍ចំពោះផលិតផលដែលត្រូវរៀបចំផ្សំក្នុងលក្ខណៈនៅក្តៅ មិនត្រូវធ្វើនៅក្បែរផលិតផលកំពុងដាក់អោយត្រជាក់ ឬ នៅក្បែរវត្ថុធាតុដើម លើកលែងតែនៅពេលកំពុងប្រើប្រាស់វត្ថុធាតុដើមនេះ ។

**មាត្រា ៧.-**

បណ្តាបន្ទប់អាគារ និងអាគារឧបសម្ព័ន្ធ ត្រូវអោយមានពន្លឺគ្រប់គ្រាន់ និងខ្យល់ផ្លាស់ប្តូរបានល្អ ។ នៅក្នុងកន្លែងដែលសំភារៈឧបករណ៍ណាមួយនាំបង្កនូវកំដៅខ្លាំង ឬ ផ្សែងចំហាយ ឬ ខ្យល់ក្រខ្វក់ ប្រព័ន្ធបញ្ចេញខ្យល់ចោល ត្រូវតែរៀបចំតាមលក្ខណៈបច្ចេកទេស ដើម្បីអោយការភាយចេញ និងការបញ្ចេញខ្យល់ចោលទាំងនោះមិនបង្កើតជាប្រភពធ្វើអោយប្រែខូច ឬ អោយមានការចម្លងចំពោះផលិតផលម្ហូបអាហារ ។

ប្រព័ន្ធផ្លាស់ប្តូរខ្យល់ល្អ ដោយលក្ខណៈធម្មជាតិ ឬ ដោយមេកានិច ត្រូវតែធានាអោយបាន ដើម្បីទប់ស្កាត់មិនអោយមានការកកើតដំណក់ទឹក ឬ មិនអោយមានការរីកដុះនូវផ្សិតលើផ្ទៃខាងលើនៃបន្ទប់អាគារទាំងនោះ ដែលអាចជ្រុះធ្លាក់មកលើ និងនាំអោយប៉ះពាល់ដល់ផលិតផលម្ហូបអាហារ ។

បណ្តាប្រព័ន្ធផ្លាស់ប្តូរខ្យល់ទាំងនោះ ត្រូវតែបង្កើតតាមរបៀបងាយស្រួលចូលដល់សំភារៈតម្រង និងគ្រឿងពាក់ព័ន្ធផ្សេងទៀត ដែលត្រូវការដុសលាង ឬ ដូរផ្លាស់ ។

**មាត្រា ៨.-**

គ្រឹះស្ថាន និងកន្លែងផលិតនានា ត្រូវមានបន្ទប់ដាក់សំលៀកបំពាក់ និងទីតាំងអនាម័យគ្រប់គ្រាន់សំរាប់និយោជិតត្រូវមានភាជនីលុបលាងខ្លួន បន្ទប់ងូតទឹក បន្ទប់ដាក់សំលៀកបំពាក់ និងបង្គន់ដែលប្រើប្រព័ន្ធទឹករុញសំអាតមានពន្លឺគ្រប់គ្រាន់ មានខ្យល់ចេញចូល រក្សាថែទាំជាប្រចាំក្នុងល័ក្ខខ័ណ្ឌអនាម័យល្អប្រសើរ និងមិនជាប់ទាក់ទងផ្ទាល់ជាមួយបន្ទប់ទុកដាក់ផលិតផលម្ហូបអាហារ ។ ភាជនីលុបលាងខ្លួនត្រូវដាក់អោយឃើញច្បាស់នៅច្រកចេញ

ពីបង្គន់ និងនៅក្បែរកន្លែងធ្វើការ ។ ភាជន៍នោះត្រូវបំពាក់អោយមានចរន្តទឹកក្តៅ និងត្រជាក់ ព្រមទាំងឧបករណ៍រៀបចំសំរាប់លាង និងសំងួតដៃប្រកបដោយអនាម័យ ។ នៅក្នុងបន្ទប់បង្គន់ត្រូវបិទប្រកាសដាក់បញ្ញត្តិអោយនិយោជិតចាំបាច់ត្រូវលាងដៃពេលចេញពីបង្គន់ ។

**មាត្រា ៩.-**

ជណ្តើរ ប្រដាប់យោង និងបណ្តាឧបករណ៍ជំនួយដូចជា ឧបករណ៍សំរាប់លើក ជណ្តើរចល័ត ។ល។ ត្រូវតែមានទីតាំងស្ថាបនា និងថែទាំតាមរបៀបដែលមិននាំអោយមានការចម្លងដល់ផលិតផលម្ហូបអាហារ ។

**មាត្រា ១០.-**

ការថែរក្សាទុកដាក់ផលិតផលងាយរលួយខូចដែលត្រូវប្រើប្រាស់ ឬ ត្រូវបានរៀបចំសំរាប់ផលិតក្នុងបន្ទប់អាគារទាំងនោះត្រូវអនុវត្តក្នុងបន្ទប់ត្រជាក់ ដោយកំរិតសីតុណ្ហភាពសមស្រប ដូចមានចែងនៅឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

**មាត្រា ១១.-**

បណ្តាវត្ថុសារធាតុ ឬ ផលិតផលដែលអាចចម្លងដល់ម្ហូបអាហារ ត្រូវតែទុកដាក់ក្នុងបន្ទប់ ឬ ទូដាច់ដោយឡែកដោយមានចាក់សោរ ។ ការរៀបចំបែបនេះ អនុវត្តចំពោះផលិតផលសម្រាប់បំរើការថែទាំ និងការលាងសំអាត ដែលត្រូវប្រើប្រាស់ដោយមិននាំអោយមានគ្រោះចម្លងដល់ផលិតផលម្ហូបអាហារ ។

## ជំពូកទី ៣
## លក្ខណៈកំណត់ដោយឡែកចំពោះបន្ទប់អាគារដែលផលិតផលម្ហូបអាហារ ត្រូវបានរៀបចំ ឧទ្ទេសប្រព្រឹត្តិកម្ម ឬកែច្នៃ

**មាត្រា ១២.-**

ផ្ទៃក្រាល ជញ្ជាំង សន្ទះខណ្ឌ ត្រូវធ្វើពីសំភារៈរឹង រលោង ពុំមានធ្លុតប្រហោង ងាយស្រួលដុសលាង និងសម្លាប់មេរោគ ។ ជញ្ជាំង និងសន្ទះខណ្ឌនានា ត្រូវមានសំភារៈរឹងធន់នឹងការប៉ះទង្គិច មិនជ្រាបទឹក មិនពុកផុយ និងងាយស្រួលសំរាប់ការដុសលាង និងការសម្លាប់មេរោគរហូតដល់កំពស់យ៉ាងតិចពីរម៉ែត្រ ។ បើសិនជាគេប្រើបន្ទះភ្ជាប់ៗគ្នា បន្ទះនោះត្រូវតែភ្ជិតជាប់គ្នាអោយបានល្អ ។ ចំពោះផ្ទៃជញ្ជាំង និងសន្ទះខណ្ឌដែលនៅសល់ ព្រមទាំង

ពិតានត្រូវលាបពណ៌ ហើយលាបសារជាថ្មីឡើងវិញ អោយបានទៀងទាត់តាមពេលវេលា បើពុំមានសំភារៈដែលមានលក្ខណៈដូចបញ្ជាក់ខាងលើ ។ មុំជ្រុងទាំងឡាយ ត្រូវតែប្រមុំអោយមានរាងកោង យ៉ាងហោចណាស់នៅកន្លែងភ្ជាប់នឹងផ្ទៃក្រាលខាងក្រោម ។

**មាត្រា ១៣.-**

ពិតានបញ្ឆោត និងបណ្តាបរិក្ខារពន្លឺរជាអាទិ៍ អំពូលភ្លើង ប្រដាប់អគ្គិសនី ត្រូវតែរៀបចំ និងដាក់នៅកន្លែងតាមរបៀបដែលទប់រាំងការកកក្អែល ដែលបន្ថយការកជាដំណក់ទឹក និងមិនមែនជាប្រភពចម្លង ឬ ប្រភពផ្តល់នូវអង្គធាតុដទៃចូលក្នុងផលិតផលម្ហូបអាហារ ។

**មាត្រា ១៤.-**

បណ្តាបង្អួច និងរន្ធខ្យល់ផ្សេងទៀត ត្រូវតែធ្វើតាមរបៀបដែលជៀសវាងនូវការជាប់ធូលី ឬ កកក្អែល ។ បង្អួច ឬ រន្ធខ្យល់ណាដែលបើកចេញទៅនឹងបរិស្ថានខាងក្រៅ ត្រូវតែបំពាក់នូវរបាំងការពារសត្វល្អិតដែលអាចដោះចេញយកទៅដុសលាងបានស្រួលបើមានការចាំបាច់ ។ បណ្តាបង្អួចត្រូវតែរក្សាបិទជិតពេលដំណើរការផលិត កាលបើបើកទៅហើយអាចនាំមកនូវការចម្លងដល់ផលិតផលម្ហូបអាហារ ។

**មាត្រា ១៥.-**

បណ្តាទ្វារត្រូវតែធ្វើដោយសំភារៈរលោង មិនជប់ទឹក ងាយស្រួលដុសលាង និងសម្លាប់មេរោគបើចាំបាច់ ។

**មាត្រា ១៦.-**

ត្រូវមានការរៀបចំនូវឧបករណ៍សមស្របសំរាប់ ដុសលាង និងសម្លាប់មេរោគ ដែលជាប់លើឧបករណ៍និងបរិក្ខារ ។ ឧបករណ៍សំរាប់ដាក់ដុសលាងទាំងនោះ ត្រូវធ្វើអំពីសំភារៈធន់នឹងអុកស៊ីដកម្ម ឬ ការកាត់ស៊ីងាយស្រួលក្នុងការដុសលាង និងបំពាក់នូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត អាចបរិភោគបានទាំងក្តៅ និង ត្រជាក់ ។

**មាត្រា ១៧.-**

ភាជន៍ ឬ ឧបករណ៍ សំរាប់ដាក់លាងម្ហូបអាហារ ត្រូវមានបំពាក់ដោយប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ក្តៅ និង/ឬ ត្រជាក់តាមការចាំបាច់ និងត្រូវមានការដុសលាងដោយទៀងទាត់។

៥

## ជំពូកទី ៤
## លក្ខណៈកំណត់ទូទៅចំពោះការដឹកជញ្ជូន

**មាត្រា ១៨.-**

បណ្តាមធ្យោបាយដឹកជញ្ជូន ដូចជា ទ្រុងរថយន្ត និង/ឬ កុងតែន័រ ប្រើប្រាស់ដាក់ម្ហូបអាហារមិនត្រូវបង្កជាគ្រោះនៃការចម្លង ឬ នៃការបង្កអោយខូចផលិតផលម្ហូបអាហារ ដែលបណ្តាលមកពីការរៀបចំ ការថែរក្សា ឬ ការផ្ទុកនៃមធ្យោបាយដឹកជញ្ជូននោះឡើយ ។ មធ្យោបាយដឹកជញ្ជូនត្រូវមានបំពាក់ដោយបរិក្ខារចាំបាច់សំរាប់ការថែរក្សាទុកដាក់ម្ហូបអាហារក្នុងលក្ខណៈបានល្អ និងត្រូវបានដុសលាង និង/ឬ សម្លាប់មេរោគដោយផ្ចិតផ្ចង់ក្រោយពីការប្រើប្រាស់រួចម្តងៗ ។ មធ្យោបាយដឹកជញ្ជូននោះ មិនត្រូវយកទៅប្រើប្រាស់សំរាប់ការដឹកជញ្ជូនសត្វរស់ ឬ ទំនិញដែលអាចធ្វើអោយប្រែខូចគុណភាព ឬ ចម្លងដល់ម្ហូបអាហារ ដែលត្រូវដឹកនោះទេ ។ វិធានដោយឡែកត្រូវកំណត់ដោយប្រកាសរបស់អន្តរក្រសួងអនុលោមទៅតាមមាត្រា ៥០ នៃអនុក្រឹត្យនេះ ចំពោះអ្វីដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនព្រមគ្នា ឬ បន្តបន្ទាប់គ្នានូវទំនិញ ឬ ផលិតផលម្ហូបអាហារមួយចំនួន ។

**មាត្រា ១៩.-**

ក្នុងពេលប្រតិបត្តិការផ្ទុក ឬ រើចេញផលិតផលម្ហូបអាហារ ដែលមិនទុកដាក់ក្នុងសំបកវេចខ្ចប់រឹងមាំព័ទ្ធជិតទេនោះមិនត្រូវដាក់ផ្ទាល់នឹងដីឡើយ ។ ត្រូវប្រុងប្រយ័ត្នដើម្បីកុំអោយម្ហូបអាហារដែលបញ្ចូលទៅក្នុងមធ្យោបាយដឹកជញ្ជូនប៉ះផ្ទាល់ទៅនឹងផ្ទៃក្រាល កាលបើម្ហូបអាហារទាំងនោះមិនបានទុកដាក់ក្នុងសំបកវេចខ្ចប់ដែលរុំព័ទ្ធជិតទេនោះ ។

## ជំពូកទី ៥
## លក្ខណៈកំណត់ទូទៅចំពោះគ្រឿងបរិក្ខារ

**មាត្រា ២០.-**

សម្ភារៈគ្រប់មុខ ដែលអាចប៉ះទៅនឹងផលិតផលម្ហូបអាហារ ព្រមទាំងផលិតផលសំរាប់ដុសលាង និងសំរាប់សម្លាប់មេរោគលើសម្ភារៈទាំងនោះ ត្រូវតែមានលក្ខណៈស្របតាមការណែនាំ ។

**មាត្រា ២១.-**

ជាទូទៅ ការតម្លើងនូវសម្ភារៈ និងគ្រឿងបរិក្ខារទាំងឡាយដែលប៉ះទៅនឹងផលិតផលម្ហូបអាហារ ត្រូវតែធ្វើអោយសំរេចបាននូវការកាត់បន្ថយជាអតិបរមា នូវគ្រោះនៃការចម្លងដល់ម្ហូបអាហារ ។ ការតម្លើងនេះត្រូវសំរួលអោយដល់ការដុសលាងប្រព្រឹត្តទៅបានតាមតំរូវការដែលចង់បាន និងអោយការសម្លាប់មេរោគបានគ្រប់គ្រាន់ កាលបើចាំបាច់ អនុលោមទៅលើគោលដៅដែលបានកំណត់ ។ សម្ភារៈនិងគ្រឿងបរិក្ខារទាំងនោះ ត្រូវរៀបតម្លើងតាមរបៀបដែលផ្តល់លទ្ធភាពអោយការដុសលាងបរិវេណជុំវិញ ប្រព្រឹត្តទៅបានស្អាត ។

**មាត្រា ២២.-**

ផ្ទៃទាំងឡាយដែលប៉ះផ្ទាល់និងម្ហូបអាហារ ត្រូវតែមានលក្ខណៈរលោង ពុំមានប្រហោង ស្នាមប្រេះ និងស្នាមរបើក ពិសេសចំពោះផ្ទៃធ្វើអំពីឈើ ។ ផ្ទៃនោះត្រូវតែធន់នឹងសកម្មភាពផលិតម្ហូបអាហារ និងប្រតិបត្តិការនៃការដុសលាង និងការសម្លាប់មេរោគ ដែលត្រូវធ្វើច្រើនសាដដែលៗ ។ តុ និងជ្រុញធ្វើអំពីឈើប្រើប្រាស់សំរាប់កាត់សាច់ត្រូវតែកោសសំអាត និងសម្លាប់មេរោគដោយយកចិត្តទុកដាក់នៅពេលបញ្ចប់ការងារប្រចាំថ្ងៃ ។

**មាត្រា ២៣.-**

គ្រឿងប្រើប្រាស់សំរាប់សហគ្គករណ៍ម្ហូបអាហារ ត្រូវតែបានដុសលាង និងសម្លាប់មេរោគដោយយកចិត្តទុកដាក់រៀងរាល់ពេលដែលមានការចាំបាច់ក្នុងកំឡុងពេលថ្ងៃធ្វើការ ព្រមទាំងពេលចប់ថ្ងៃការងារនិមួយៗ និងមុនពេលយកទៅប្រើប្រាស់សារជាថ្មីពេលដែលប្រឡាក់ ។ ក្រោយពេលដែលដុសលាងហើយ គ្រឿងប្រើប្រាស់នោះត្រូវតែទុកដាក់អោយផុតពីប្រភពធ្វើអោយក្រខ្វក់គ្រប់បែប រហូតដល់ពេលយកទៅប្រើប្រាស់សារជាថ្មីទៀត ។ បណ្តាគ្រឿងម៉ាស៊ីនដែលដំណើរការជាប់ជាប្រចាំក្នុងការបំរើផលិតកម្ម ត្រូវតែដុសលាង និង សម្លាប់មេរោគពេលចប់ការងារ ។

**មាត្រា ២៤.-**

គ្រឿងបរិក្ខារប្រើប្រាស់សំរាប់សំរេចសុវត្ថិភាពម្ហូបអាហារដោយកំដៅ ក្រៅពីការចំអិនធម្មតា ត្រូវមានបំពាក់នូវគ្រឿងឧបករណ៍សំរាប់កត់ត្រាសីតុណ្ហភាព និងរយៈពេលដែលសីតុណ្ហភាពនោះត្រូវបានរក្សាអោយនៅថេររហូត ។ កំណត់ត្រាទាំងនោះ ត្រូវថែរក្សាទុកដោយភ្នាក់ងារត្រួតពិនិត្យនៃមូលដ្ឋានផលិតកម្ម ក្នុងអាយុកាលធម្មតានៃផលិតផលដែលបានកែច្នៃតាមរបៀបនោះ ។

មាត្រា ២៥.-

ផ្ទៃពាសខាងក្នុងនៃឧបករណ៍បង្កធាតុត្រជាក់ជាអាទិ៍ បន្ទប់ត្រជាក់ និងទូកញ្ចក់ត្រជាក់ ត្រូវតែមានលក្ខណៈងាយស្រួលដុសលាង និងសម្លាប់មេរោគ ។ ផ្ទៃពាសនោះត្រូវធ្វើដោយសម្ភារៈ មិនពុកផុយ មិនជ្រាបទឹកធន់ ទឹងការប៉ះទង្គិច និងមិនត្រូវធ្វើអោយម្ហូបអាហារប្រែខូច ឬ បណ្តាលអោយម្ហូបអាហារផ្តល់គ្រោះចង្រៃដល់សុខភាព ។ ឧបករណ៍បង្កធាតុត្រជាក់ ត្រូវតែធ្វើអោយបានសំរេចតាមវិធីណាដែលអាចអោយសីតុណ្ហភាពរបស់ចំហាយខ្យល់ រក្សាបាននូវកំរិតសីតុណ្ហភាពដូចៗគ្នានៅគ្រប់ចំណុចទាំងអស់នៃផលិតផល ចំពោះប្រភេទផលិតផលម្ហូបអាហារនិមួយៗ ។ ឧបករណ៍បង្កធាតុត្រជាក់នោះ ត្រូវមានសីតុណ្ហមាត្រ ដែលគេអាចពិនិត្យមើលឃើញបានយ៉ាងងាយស្រួល ។ ផ្នែកសំរាប់ទទួលនូវការប្រែប្រួលសីតុណ្ហភាពរបស់សីតុណ្ហមាត្រ ត្រូវតែដាក់តាមរបៀបណាដែលអាចវាស់ស្ទង់សីតុណ្ហភាពនៅចំណុចខ្ពស់បំផុត ឬ នៅត្រឹមកំពស់របស់ឧបករណ៍សំរាប់រក្សាសីតុណ្ហភាពអោយថេរ ។

## ជំពូកទី ៦
## ការគ្រប់គ្រងសំណល់រឹង រាវ និង ទឹកកខ្វក់

មាត្រា ២៦.-

សំណល់ឥតប្រយោជន៍គ្រប់ប្រភេទ ត្រូវតែបញ្ចេញចោលពីកន្លែងធ្វើការជាញឹកញាប់ ។ ក្នុងកិច្ចការនេះ សំណល់ទាំងនោះត្រូវយកទៅដាក់ចូលជាបន្ទាន់ទៅក្នុងប្រដាប់សំរាប់ដាក់ប្រកបដោយគំរបបើកបិទបាន ហើយត្រូវបិទជិតនៅចន្លោះនៃការប្រើប្រាស់ម្តងៗ រួចត្រូវចាក់ចេញអោយអស់ ដុសលាង និងសម្លាប់មេរោគ យ៉ាងហោចណាស់មួយដងក្នុងមួយថ្ងៃ ។ ក្រៅម៉ោងប្រើប្រាស់ប្រដាប់ដាក់សំណល់ ត្រូវតែដឹកលំទុកក្នុងបន្ទប់ដោយឡែកស្ថិតនៅក្រៅកន្លែងដែលមានការផ្សំ កាន់ប៉ះពាល់ដល់ផលិតផលម្ហូបអាហារ ។ បន្ទប់ដាក់សំណល់នោះ និងផ្ទៃផ្សេងទៀតសំរាប់ការស្តុកដឹកលំសំណល់ ត្រូវតែរក្សាអោយស្អាតជាអចិន្ត្រៃយ៍ ដើម្បីការពារកុំអោយសត្វល្អិត និងសត្វចង្រៃផ្សេងទៀតចូលបាន និងការពារការចម្លងផលិតផលម្ហូបអាហារ ទឹកស្អាត និងបរិក្ខារ ព្រមទាំងបន្ទប់អាគាររៀបចំសំរាប់ទុកដាក់ម្ហូបអាហារ ។

មាត្រា ២៧.-

បណ្តាបំពង់ និងបណ្តាញបញ្ចេញសំណល់រាវ ដោយរួមទាំងបណ្តាញលូទឹកកខ្វក់ ត្រូវតែមានចំនួនគ្រប់គ្រាន់ ដើម្បីធានាការបញ្ចេញទឹកសំណល់ ពេលមានសកម្មភាពមមាញឹកបំផុត ។ បំពង់ទាំងអស់ត្រូវតែភិត

និងប្រកបដោយស៊ីហ្វុង និងប្រហោងពិនិត្យត្រឹមត្រូវ ។ ទឹកសំណល់ទាំងឡាយត្រូវតែបញ្ចេញចោលតាមរយៈអាងប្រព្រឹត្តិកម្ម និងត្រូវឆ្លើយតបទៅតាមស្តង់ដារបរិស្ថាន និងត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្តិនៃបរិស្ថាន និងក្នុងលក្ខណៈកុំអោយចម្លង ដល់បណ្តាញផ្គត់ផ្គង់ទឹកស្អាត ។

## ជំពូកទី ៧
## ការផ្គត់ផ្គង់ទឹក

**មាត្រា ២៨.-**

កន្លែង ឬបន្ទប់អាគារ ត្រូវមានឧបករណ៍ដែលធានាការផ្គត់ផ្គង់យ៉ាងគ្រប់គ្រាន់នូវទឹកស្អាតពិសាបាន ។ ទឹកស្អាតពិសាបាននោះ ត្រូវតែប្រើប្រាស់តាមការចាំបាច់ដើម្បីចៀសវាងការចម្លងផលិតផលម្ហូបអាហារ ។

**មាត្រា ២៩.-**

ទឹកកកត្រូវផលិតអំពីទឹកស្អាតពិសាបាន និងត្រូវតែប្រើប្រាស់រៀងរាល់ពេលដែលចាំបាច់ ដើម្បីចៀសវាងការចម្លងមេរោគដល់ផលិតផលម្ហូបអាហារ ។ ទឹកកកនោះត្រូវតែផលិត កាន់ ប៉ះពាល់ ឬស្តុកទុក ក្នុងល័ក្ខខ័ណ្ឌទប់ស្កាត់ពុំអោយមានកើតឡើងនូវការចម្លងមេរោគដល់ផលិតផលម្ហូបអាហារនោះ ។

**មាត្រា ៣០.-**

ចំហាយប្រើប្រាស់ប៉ះផ្ទាល់ជាមួយផលិតផលម្ហូបអាហារ មិនត្រូវមានសារធាតុណាមួយប្រកបដោយគ្រោះថ្នាក់ចំពោះសុខភាព ឬក៏អាចចម្លងផលិតផលម្ហូបអាហារ ។

**មាត្រា ៣១.-**

ទឹកសំរាប់ប្រើប្រាស់ដើម្បីផលិត ចំហាយ បង្កធាតុត្រជាក់ ប្រយុទ្ធនឹងអគ្គិភ័យ ឬដើម្បីបំរើទិសដៅផ្សេងទៀតដូចគ្នា ដែលពុំមានការទាក់ទងជាមួយផលិតផលម្ហូបអាហារ មិនត្រូវចម្លងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឡើយ ។

## ជំពូកទី ៨
## អនាម័យនៃបុគ្គលិក

**មាត្រា ៣២.-**

បុគ្គលិកទាំងឡាយដែលមានមុខងារផ្សំ ឬប៉ះពាល់ម្ហូបអាហារ ត្រូវកំហិតអោយមានភាពស្អាតខ្ពស់បំផុត

ចំពោះខ្លួនប្រាណ និងសំលៀកបំពាក់ ។ បុគ្គលិកទាំងឡាយនោះ នៅពេលបំពេញការងារត្រូវស្លៀកពាក់ខោអាវពាក់ស្បែកជើង ពាក់ស្រោមដៃ និងប្រដាប់គ្របសក់ដែលត្រូវបានរៀបចំដោយឡែក និងពិសេសសំរាប់តែការងារនោះ ។ បញ្ញត្តិទាំងឡាយនោះ ត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់និយោជិត ។ ម្យ៉ាងទៀតត្រូវហាមឃាត់ជាដាច់ខាតនូវការខាកស្ដោះ ជក់បារី ឬបរិភោគអាហារ នៅក្នុងបន្ទប់អាគារ ដែលបុគ្គលិកទាំងនោះ ផ្សំ កាន់ ប៉ះពាល់ផលិតផលម្ហូបអាហារ ។

**មាត្រា ៣៣.-**

ការកាន់ ប៉ះពាល់ ផលិតផលម្ហូបអាហារត្រូវហាមឃាត់ចំពោះបុគ្គលទាំងឡាយណាដែលអាចចម្លងមេរោគដល់ម្ហូបអាហារនោះជាអាទិ៍ បុគ្គលកើតមានជម្ងឺសើស្បែក និងជម្ងឺឆ្លងផ្សេងៗទៀត ។ បុគ្គលទាំងឡាយដែលមានភារកិច្ចផ្សំប៉ះពាល់ផលិតផលម្ហូបអាហារ ត្រូវតែទទួលការត្រួតពិនិត្យសុខភាពទៀងទាត់ តាមពេលកំណត់ និងត្រូវទទួលការចាក់ថ្នាំបង្ការតាមបែបបទកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីទទួលបន្ទុកការងារអនុលោមទៅតាមមាត្រា ៥០នៃអនុក្រឹត្យនេះ ។ ប្រកាសនេះកំណត់នូវប្រភេទជម្ងឺដែលអ្នកមានជម្ងឺនោះអាចចម្លងដល់ម្ហូបអាហារ ។

## ជំពូកទី ៩
## លក្ខណៈកំណត់ចំពោះវត្ថុធាតុដើមគ្រឿងផ្សំនិងផលិតផលម្ហូបអាហារ

**មាត្រា ៣៤.-**

វត្ថុធាតុដើម និងគ្រឿងផ្សំសំរាប់ផ្សំផលិតម្ហូបអាហារ ត្រូវតែបានមកក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល និងសេវា ជាអាទិ៍ ទៅនឹងអ្វីដែលពាក់ព័ន្ធជាមួយវត្ថុធាតុចម្លង និងវត្ថុធាតុអាក្រក់ផ្សេងទៀតដែលអាច នាំអោយមានគ្រោះថ្នាក់ដល់សុខភាព ។ ម្យ៉ាងទៀត ផលិតផលទាំងនោះត្រូវតែស្របទៅនឹងលក្ខណៈវិនិច្ឆ័យផ្នែកអតិសុខុមជីវសាស្ត្រ ដែលមាននៅក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះបើសិនជាលក្ខណៈវិនិច្ឆ័យមានកំណត់ចំពោះ វត្ថុធាតុដើម ឬគ្រឿងផ្សំនោះ ។

**មាត្រា ៣៥.-**

វិធីដាំដុះ វិធីប្រមូលផល គ្រឿងបរិក្ខារ សំភារៈមធ្យោបាយដឹកជញ្ជូន បន្ទប់អាគារ និងអាគារឧបសម្ព័ន្ធដែលបានប្រើប្រាស់នៅដំណាក់នៃផលិតកម្មដំបូង មិនត្រូវបង្កើតជាប្រភពចំលង នៃការចម្លងចំពោះវត្ថុធាតុដើមឡើយ ។

**មាត្រា ៣៦.-**

វត្ថុធាតុដើម គ្រឿងផ្សំ ផលិតផលម្ហូបអាហារពាក់កណ្ដាលសំរេច ឬ សំរេច ទោះក្នុងករណីណាក៏ដោយ មិនត្រូវប៉ះផ្ទាល់ទៅនឹងដី ឬ ត្រូវបានផ្សំ កាន់ប៉ះពាល់ ឬ ស្ដុកទុកក្នុងលក្ខណៈដែលអាចនាំអោយចម្លងដល់ផលិតផលនោះបាន ។

**មាត្រា ៣៧.-**

ផលិតផលម្ហូបអាហារ ត្រូវតែមានការការពារពីការចម្លងគ្រប់ប្រភេទដោយសំភារៈជាសំបកវេចខ្ចប់ដែលរុំខ្ចប់ជិតពេញលេញនូវផលិតផលនោះ លើកលែងតែផលិតផលដែលមានការការពារពីកំណើតធម្មជាតិ ដោយសំបក ស្រកា ឬ ស្បែកដែលត្រូវបកចេញមុនពេលបរិភោគ ។ អ្នកលក់មិនត្រូវអនុញ្ញាតអោយអតិថិជនរបស់ខ្លួនកាន់ ប៉ះពាល់ ផលិតផលម្ហូបអាហារ លើកលែងករណីម្ហូបអាហារដែលមានការការពារពីកំណើតធម្មជាតិ ឬ មានការវេចខ្ចប់ត្រឹមត្រូវ ។

**មាត្រា ៣៨.-**

សំភារៈវេចខ្ចប់ត្រូវស្អាត ផុតចាកពីការចម្លងគ្រប់ប្រភេទ និងត្រូវស្របតាមស្ដង់ដារបច្ចេកទេស ស្ដីពីសំភារៈប៉ះពាល់នឹងផលិតផលម្ហូបអាហារ ។

**មាត្រា ៣៩.-**

ផលិតផលម្ហូបអាហាររៀបចំស្រេច សំរាប់ការលក់ភ្លាមៗ ត្រូវតែរក្សាទុក ឬ ដាក់លក់ក្នុងលក្ខណៈដែលចៀសវាងនូវការប្រែខូច ឬ ការចម្លងគ្រប់បែប។ រានលក់ទំនិញ តុលក់សាច់ ត្រី បន្លែ ផ្លែឈើ ត្រូវសាងដោយសំភារៈដែលអាចដុសលាងបាន និងរក្សាទុកក្នុងស្ថានភាពស្អាត និងមានការថែទាំ ព្រមទាំងសំអាតកំចាត់មេរោគ ។ ផលិតផលម្ហូបអាហារមិនត្រូវដាក់តាំងនៅកំពស់ទាបជាងហាសិបសង់ទីម៉ែត្រ (៥០ស.ម) ពីដីឡើយ ។ ផលិតផលម្ហូបអាហារដែលមិនមានការការពារពីកំណើតធម្មជាតិ ឬ មិនត្រូវបានលក់ដោយមានការវេចខ្ចប់ទេនោះ ត្រូវតែ

ដាក់ខណ្ឌអោយឃ្លាតពីសាធារណជន ដោយកញ្ចក់ ដោយបន្ទះខណ្ឌមានសំណាញ់ក្រឡាញឹក ឬ ក៏ដោយរបៀបផ្សេងដែលមិនអោយមានកកើតឡើងបាននូវភាពកខ្វក់ណាមួយ ។ ផលិតផលម្ហូបអាហារមិនអាចបរិភោគ ឬ ប្រើប្រាស់បាន ទោះវេចខ្ចប់ក្តី ឬ មិនវេចខ្ចប់ក្តី ត្រូវតែដកចេញពីការលក់ដូរ និងបំផ្លាញចោល ។

**មាត្រា ៤០.-**

ផលិតផលដែលមានបញ្ជាក់នៅឧបសម្ព័ន្ធ ទី១ នៃអនុក្រឹត្យនេះ ត្រូវតែស្តុកទុក ដឹកជញ្ជូន ដាក់លក់ ឬលក់ក្នុងល័ក្ខខ័ណ្ឌនៃសីតុណ្ហភាពត្រឹមត្រូវដូចដែលបានបញ្ជាក់ក្នុងឧបសម្ព័ន្ធនោះ ។

**មាត្រា ៤១.-**

ផលិតផលម្ហូបអាហារដែលមានបញ្ជាក់នៅឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ ត្រូវតែមានលក្ខណៈសមស្របទៅនឹងស្តង់ដារផ្នែកអតិសុខុមជីវសាស្ត្រដែលបានកំណត់នៅឧបសម្ព័ន្ធនេះ ។

## ជំពូកទី ១០
## ការបណ្តុះបណ្តាល និងស្វ័យត្រួតពិនិត្យ

**មាត្រា ៤២.-**

អ្នកទទួលខុសត្រូវនៃគ្រឹះស្ថានឧស្សាហកម្មទាំងឡាយ ដែលមានការផ្សំ កាន់ប៉ះពាល់ផលិតផលម្ហូបអាហារ ត្រូវតែងតាំងបុគ្គលមួយរូបដែលត្រូវទទួលរ៉ាប់រង ពិសេសឃ្លាំមើលអោយមានការគោរព បណ្តាវិធានអនាម័យកំណត់ក្នុងអនុក្រឹត្យនេះ និងបណ្តុះបណ្តាលបុគ្គលិកក្នុងបញ្ហាអនាម័យម្ហូបអាហារ ។

**មាត្រា ៤៣.-**

អ្នកទទួលខុសត្រូវនៃគ្រឹះស្ថានឧស្សាហកម្មទាំងឡាយ ដែលមានការផ្សំ រៀបចំ ផលិតផលម្ហូបអាហារដែលស្ថិតក្រោមស្តង់ដារផ្នែកអតិសុខុមជីវសាស្ត្រ ត្រូវតែមានការត្រួតពិនិត្យភាពត្រឹមត្រូវទៅនឹងស្តង់ដារនោះ នៅក្នុងមន្ទីរពិសោធន៍ ដែលត្រូវបានទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច ។ បែបបទនៃការត្រួតពិនិត្យនេះ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល និងក្រសួងពាក់ព័ន្ធ ដោយអនុលោមតាមមាត្រា ៥០ នៃអនុក្រឹត្យនេះ ។

# ជំពូកទី ១១

## លក្ខណៈកំណត់ពិសេសចំពោះផ្សារ និងចំពោះសកម្មភាពចែកចាយ ឬ ចំពោះសកម្មភាពភោជនីយដ្ឋានចល័ត ឬ ដោយពេល

**មាត្រា ៤៤.-**

មានតែបណ្ដាលក្ខណៈកំណត់ នៃជំពូកនេះ និងជំពូក ទី ៩ ស្ដីពីវត្ថុធាតុដើម គ្រឿងផ្សំ និងផលិតផលម្ហូបអាហារតែប៉ុណ្ណោះដែលត្រូវអនុវត្ត ចំពោះទីផ្សារ ចំពោះសកម្មភាពចែកចាយ ឬចំពោះសកម្មភាពភោជនីយដ្ឋានចល័ត ឬដោយពេល ។

**មាត្រា ៤៥.-**

ផលិតផលម្ហូបអាហារត្រូវតែមានការការពារប្រកបដោយប្រសិទ្ធភាព ពីកំដៅ និង ពន្លឺព្រះអាទិត្យ ធូលីអាកាសធាតុប្រែប្រួល សត្វល្អិត ពពួកសត្វកកេរ និងសត្វផ្សេងទៀត ។ ផលិតផលម្ហូបអាហារឆាប់ខូចទុកមិនបានយូរត្រូវតែដាក់ក្នុងលក្ខណៈត្រជាក់ត្រឹមត្រូវ ដោយប្រើទឹកកក ឬ មធ្យោបាយផ្សេងទៀត ។ បណ្ដាគ្រឿងប្រើប្រាស់ និងគ្រឿងបរិក្ខារការងារ ត្រូវតែរក្សាទុកក្នុងលក្ខណៈស្អាតល្អ និងមានការសម្លាប់មេរោគ បើចាំបាច់ ។

**មាត្រា ៤៦.-**

បណ្ដាបុគ្គលដែលមានភារកិច្ចផ្សំ កាន់ ប៉ះពាល់ ផលិតផលម្ហូបអាហារ ត្រូវមានអនាម័យស្អាតជានិច្ចចំពោះខ្លួនប្រាណ និងសំលៀកបំពាក់របស់ខ្លួន ។ បុគ្គលទាំងនោះមិនត្រូវមានជម្ងឺសើស្បែក និងជម្ងឺឆ្លងផ្សេងៗដែលអាច ចម្លងដល់ម្ហូបអាហារ ។

**មាត្រា ៤៧.-**

នៅតាមទីផ្សារអចិន្ត្រៃយ៍ ត្រូវរៀបចំគ្រឿងឧបករណ៍សំរាប់អោយបណ្ដាបុគ្គល ដែលផ្សំ កាន់ ប៉ះពាល់ ផលិតផលម្ហូបអាហារបានលាងដៃប្រកបដោយលក្ខណៈអនាម័យ កាលបើពុំមានឧបករណ៍អនាម័យអចិន្ត្រៃយ៍ទេ ។ ត្រូវបង្កើតអោយមានទីតាំងមានទឹកស្អាតមួយសំរាប់ដុសលាងសំអាតឧបករណ៍ប្រើប្រាស់ និងគ្រឿងបរិក្ខារការងារ ។

**មាត្រា ៤៨.-**

នៅតាមទីផ្សារអចិន្ត្រៃយ៍ ត្រូវរៀបចំអោយមានទីតាំង ឬ/និង ឋបនភ័ណ្ឌសមស្របសំរាប់ទុកនូវសារធាតុ និងសំណល់គ្រោះថ្នាក់ និង/ឬ ដែលមិនអាចបរិភោគបាន ទោះជាលក្ខណៈរឹង ឬរាវក៏ដោយមុននឹងបញ្ជូនចោលទៅតាមទីកន្លែងទុកដាក់ចុងក្រោយតាមការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច ។

## ជំពូកទី ១២
## ទោសប្បញ្ញត្តិ

**មាត្រា ៤៩.-**

ដោយពុំទាន់គិតដល់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ដែលកំណត់ដោយប្រកាសរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ អំពើប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃអនុក្រិត្យនេះ ហើយមិនមែនជាបទល្មើសដូចបានកំណត់ក្នុងមាត្រា ៦១ ដល់ មាត្រា ៧១ (ជំពូកទី ៧) នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦០០ /០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ត្រូវពិន័យជាប្រាក់ ពីប្រាំរយ (៥០០) រៀល ដល់ ដប់ម៉ឺន (១០០.០០០) រៀល ។

## ជំពូកទី ១៣
## លក្ខណៈកំណត់ផ្សេងៗ

**មាត្រា ៥០.-**

ប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬបណ្តារដ្ឋមន្ត្រី ដែលមានការពាក់ព័ន្ធក្រោយការផ្តល់មតិរបស់គណៈកម្មាធិការអន្តរក្រសួង សំរាប់កិច្ចសំរបសំរួលការត្រួតពិនិត្យគុណភាព និង សុវត្ថិភាព ផលិតផល និងសេវាកម្ម ហៅថា គណៈកម្មាធិការកូដិចជាតិអាច ÷

ក) -កែប្រែ ឬបំពេញបន្ថែមនូវឧបសម្ព័ន្ធ ទី ១ & ទី ២ នៃអនុក្រិត្យនេះ ។

ខ) -ដាក់ចេញនូវបទប្បញ្ញត្តិពិសេសទាំងឡាយសំរាប់អនុវត្តសកម្មភាព ចំពោះផលិតផលម្ហូបអាហារ ឬចំពោះបណ្តាវិធីមួយចំនួនសំរាប់កែច្នៃផលិតផលម្ហូបអាហារ ។

គ) -ដាក់ចេញនូវបទប្បញ្ញត្តិលើកលែង ជាលក្ខណៈបណ្តោះអាសន្ន និងលក្ខណៈកំណត់ទាំងឡាយនៃអនុក្រិត្យនេះ ចំពោះតំបន់ភូមិសាស្ត្រ ឬតំបន់សេដ្ឋកិច្ច ជាកំណត់មួយចំនួនតាមសំណើរបស់អភិបាលខេត្ត ។

ឃ) -ចាត់វិធានការសមស្របចាំបាច់សំរាប់ការអនុវត្តត្រូវតែស្របនឹងអនុក្រឹត្យនេះ ។

**មាត្រា ៥១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥២.-**

អនុក្រឹត្យនេះ នឹងចូលជាធរមានក្នុងរយៈពេលប្រាំបួន(៩)ខែ លើកលែងតែលក្ខណៈកំណត់នៃមាត្រា ៤០ ដែលត្រូវចូល ជាធរមានក្នុងរយៈពេលបី(៣)ខែ និងលក្ខណៈកំណត់នៃមាត្រា ៤១ ដែលត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**មាត្រា ៥៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដី ខេត្ត-ក្រុង ត្រូវទទួលរ៉ាប់រងតាមសមត្ថកិច្ចរៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ៥៣
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ ទី១

**ភ្ជាប់នឹងអនុក្រឹត្យ ស្តីពីអនាម័យនៃម្ហូបអាហារសំរាប់មនុស្សលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ២០០៣**

**១. គំនិតទូទៅ**

សីតុណ្ហភាពទាំងឡាយបញ្ជាក់នៅចំណុច ២ គឺជាសីតុណ្ហភាពអតិបរិមា ។ ចំពោះផលិតផលម្ហូបអាហារបង្កក គេពុំមានកំណត់កំរិតទាបក្រោមឡើយ ។ ចំពោះផលិតផលម្ហូបអាហារដាក់អោយត្រជាក់ កំរិតសីតុណ្ហភាពទាបខាងក្រោមជាកំរិតដែលផលិតផលម្ហូបអាហារចាប់ផ្តើមកក ។ ពុំមានផលិតផលម្ហូបណាមួយដែលអាចរក្សាទុកក្នុងចន្លោះសីតុណ្ហភាពដែលផលិតផលម្ហូបអាហារចាប់ផ្តើមកក និង សីតុណ្ហភាពអតិបរមាកំណត់ចាំបាច់ចំពោះផលិតផលបង្កក ។

គេត្រូវតែគោរពអោយបានគ្រប់ពេលវេលានូវសីតុណ្ហភាពទាំងឡាយបញ្ជាក់នៅកថាខ័ណ្ឌពីរតាំងពីការផលិត រៀបចំរហូតដល់ការលក់អោយអ្នកប្រើ ។

មធ្យោបាយដឹកជញ្ជូនត្រូវតែមានការបំពាក់ ជាពិសេសនូវបរិក្ខារ តាមរបៀបដែលអោយសីតុណ្ហភាពទាំងនោះ ត្រូវអនុវត្តតាមជានិច្ច ។ ប៉ុន្តែចំពោះដំណើរផ្លូវមិនលើសពី ១ ម៉ោង និងពេលដែលការដឹកជញ្ជូនត្រូវធ្វើឡើងដោយមានទិសដៅឆ្ពោះចំសហគ្រាសឬអ្នកប្រើតែមួយគត់ នោះផលិតផលម្ហូបអាហារតំរូវដាក់អោយត្រជាក់អាចត្រូវដឹកជញ្ជូន ក្នុងមធ្យោបាយដែលមិនមានបំពាក់នូវបរិក្ខារពិសេសសំរាប់ផ្តល់ ឬ រក្សាធាតុត្រជាក់បាន ។ នៅពេលចុងបញ្ចប់នៃការដឹកជញ្ជូន សីតុណ្ហភាពនៃផលិតផលម្ហូបអាហារទោះក្នុងលក្ខណៈសម្បត្តិណាក៏ដោយ ពុំត្រូវ លើសហួសពី ៥០% នៃកំរិតអតិបរមាដែលកំណត់ឡើយ ។

**២. តារាងនៃបណ្តាសីតុណ្ហភាពអតិបរិមាត្រូវអនុវត្តតាម**

| **ផលិតផលម្ហូបអាហារបង្កក** | **សីតុណ្ហភាព (°C)** |
|---|---|
| ប៊ឺរ និង ខ្លាញ់សត្វ | -១៤ |
| ការ៉េមកក ការ៉េម ភេសជ្ជៈ ធ្វើដោយទឹកដមផ្លែឈើលាយស្ករ និងសុរា | -២០ |
| ផលិតផលសមុទ្រ និងទឹកសាប | -១៨ |
| ផលិតផលរុក្ខជាតិ | -១៨ |
| ផលិតផលធ្វើអំពីស៊ុត | -១២ |
| ផ្នែកបន្ទាប់បន្សំ គ្រឿងក្នុង( នៃសត្វយកសាច់) | -១២ |
| សាច់បរិភោគគ្រប់ប្រភេទ | -១២ |
| ម្ហូបចំអិន នំ បង្អែម | -១៨ |
| ក្រែមដាក់លើនំផ្អែមធ្វើដោយម្សៅ | -១៨ |
| ផលិតផលម្ហូបអាហារបង្កកផ្សេងៗទៀត | -១៨ |

| ផលិតផលម្ហូបអាហារដាក់អោយត្រជាក់ | សីតុណ្ហភាព (°C) |
|---|---|
| ផលិតផលសមុទ្រ និងទឹកសាប( ត្រី និងសត្វវង្គជាតិ ជាអាទិ៍ ក្តាម បង្កង បង្គា... ត្រូវរក្សាដាក់ក្នុងទឹកកកកិនហ្មត់) | ២ |
| ផ្នែកបន្ទាប់បន្សំ គ្រឿងក្នុង( នៃសត្វយកសាច់) | ៣ |
| សាច់បរិភោគគ្រប់ប្រភេទ | ៧ |
| សាច់វេចខ្ចប់ជាកញ្ចប់សំរាប់លក់រាយអោយអ្នកប្រើ | ៣ |
| ផលិតផលផ្សំអំពីសាច់ជ្រូក (លើកលែងតែផលិតផល ដែលធ្វើអោយមានស្ថេរភាព ដោយហាល ឆ្អើរ ផ្អាប់ឡើងមេ ) | ៦ |
| ផលិតផលផ្សំអំពីសាច់ជ្រូកវេចខ្ចប់ជាកញ្ចប់សំរាប់លក់អោយអ្នកប្រើ | ៣ |
| ម្ហូបចំអិនរៀបចំស្រេចសំរាប់លក់ | ៣ |
| ប្រភេទនំធ្វើអំពីម្សៅដាក់ក្រែម បង្អែមបំរើពេលចប់អាហារ ក្រែមចំអិនដាក់លើនំធ្វើពីម្សៅ | ៣ |
| ម្សៅស្អិតនៅស្រស់ | ៦ |
| ទឹកដោះគោនៅឆៅ ទឹកដោះគោកំដៅសំលាប់មេរោគតាមវិធីប៉ាស្ទ័រ ទឹកដោះគោធ្វើអោយឡើងមេ ទឹកដោះគោប្លែងភាពជាចាហួយ បង្អែមមានដាក់ទឹកដោះគោ | ៤ |
| ក្រែមធម្មតា | ៤ |
| ហ្វ្រូម៉ាសស្រស់ ក្រែមជូរ | ៦ |
| ប៊ឺរ | ៦ |
| បណ្តាផលិតផលខ្លាញ់ក្រៅអំពីប៊ឺរ | ១០ |
| ហ្វ្រូម៉ាសជាលក្ខណៈម្សៅស្អិតទន់ ឬមានផ្សិតខៀវ | ៨ |
| ហ្វ្រូម៉ាសជាលក្ខណៈម្សៅច្របាច់ ឬចំអិន | ១៥ |
| ផលិតផលធ្វើអំពីស៊ុត | ៣ |
| ស៊ុតនៅទាំងសំបកដាក់អោយត្រជាក់ (១) | ៨ |
| ភេសជ្ជៈពុំមានការវេចខ្ចប់ | ១០ |
| អាហារដាក់ប្រអប់បិទជិត មានអាយុកាលសំរាប់ប្រើរយៈពេលខ្លី (២) | ១០ |

(១) - បណ្តាស៊ុតនៅទាំងសំបកត្រូវតែទុកដាក់នៅកន្លែងល្ហើយត្រជាក់ល្មម តែជាគោលការណ៍មិនត្រូវដាក់ អោយត្រជាក់ (សីតុណ្ហភាព >៨ °C) ទេ លើកលែងតែដាក់លក់ក្រោមគុណស័ព្ទ "ដាក់អោយ ត្រជាក់"

(២) - ប៉ុន្តែសីតុណ្ហភាពនៃការស្តុកទុកបណ្តោះអាសន្នក្នុងឃ្លាំង នៃប្រភេទអាហារដាក់ប្រអប់បិទជិត មានអាយុកាលសំរាប់ប្រើរយៈពេលខ្លីនិមួយៗ ត្រូវតែសរសេរបញ្ជាក់លើសំបកវេចខ្ចប់ ។ គឺ សីតុណ្ហភាពនោះហើយ ដែលមិនត្រូវខ្ពស់លើសពី ១០ °C ហើយដែលត្រូវកំណត់អោយ អនុវត្តតាម ។

## ឧបសម្ព័ន្ធ ទី២

ភ្ជាប់នឹងអនុក្រឹត្យ ស្តីពីអនាម័យនៃម្ហូបអាហារសំរាប់មនុស្សលេខ ៤៧អនក្រ.បក ចុះថ្ងៃទី១២ ខែ មិថុនា ឆ្នាំ២០០៣

### សញ្ញាណនៃគំរោងយកគំរូ

តាមគណៈកម្មាធិការអន្តរជាតិបញ្ញត្តិចរិតលក្ខណៈផ្នែកអតិសុខុមជីវសាស្ត្រសំរាប់ម្ហូបអាហារ ( I.C.M.S.F –*International Commission on Microbiological Specifications for Food*) គំរោងយកគំរូមួយមានរួមនូវលក្ខណៈវិនិច្ឆ័យដូចតទៅ ដែលមានសំដែងដោយអក្សរ n.m.M និង c ។

- "n" ជាចំនួនឯកតាដែលផ្សំជាគំរូមួយ
- "m" និង"M" ជាលក្ខណៈវិនិច្ឆ័យកំណត់ក្នុងឧបសម្ព័ន្ធនេះ ។ អក្សរនេះសំដែងបញ្ជាក់ចំនួនមេរោគដែលមានវត្តមានក្នុង ម្ហូបអាហារទំងន់ ១ក្រាម ឬ ១ មីលីលីត្រ (ក្នុងម្ហូបអាហារទំងន់ ២៥ក្រាម ចំពោះ Salmonella);
- "c" តំណាងចំនួនឯកតានៃគំរូដែលផ្តល់នូវចំនួនមេរោគស្ថិតនៅចន្លោះ "m" និង "M" ។

### គំរោងយកគំរូជា ៣ថ្នាក់

គំរោងនេះមានឈ្មោះបែបនេះ ព្រោះលទ្ធផលនៃការវិភាគដែលត្រូវបកស្រាយលើមូលដ្ឋាននេះ អាចកំណត់ការចំលងមេរោគ ជា ៣ថ្នាក់ :

- ថ្នាក់ទាបជាង ឬស្មើនឹងលក្ខណៈវិនិច្ឆ័យ "m" : ឡូតិ៍ប្រកបដោយគុណភាពត្រូវតាមកំណត់ ។
- ថ្នាក់នៅចន្លោះរវាងលក្ខណៈវិនិច្ឆ័យ "m" និងលក្ខណៈវិនិច្ឆ័យ "M": ឡូតិ៍ប្រកបដោយគុណភាព អាចទទួលបានតែត្រូវមានការឃ្លាំពិនិត្យ ។
- ថ្នាក់ខ្ពស់លើស "M": ឡូតិ៍ប្រកបដោយគុណភាពពុំអាចទទួលបានគឺត្រូវបដិសេធចេញ ។

### គំរោងយកគំរូជា ២ ថ្នាក់

គំរោងនេះមានឈ្មោះបែបនេះ ព្រោះលទ្ធផលនៃវិភាគដែលត្រូវបកស្រាយលើមូលដ្ឋាននេះ អាចកំណត់ការឆ្លងមេរោគតែត្រឹម ២ ថ្នាក់ ប៉ុណ្ណោះ ។ ប្រភេទគំរោងនេះ មិនទទួលយល់ព្រមនូវការអនុគ្រោះណាមួយទេ ទោះជា លក្ខណៈវិភាគក៏ដោយ ហើយច្រើនតែត្រូវនឹងពាក្យបញ្ជាក់ថា :

"អវត្តមានក្នុង" : លទ្ធផលត្រូវចាត់ទុកថា ត្រូវតាមការកំណត់ ។

"វត្តមានក្នុង" : លទ្ធផលត្រូវចាត់ទុកថា មិនត្រូវតាមការកំណត់ ។

**តារាងទី ១ : ផលិតផលនេសាទ**

| **រាយមុខផលិតផល** | n | c | m | M |
|---|---|---|---|---|
| **១‑ត្រីហាន់ជាចំរៀកនិងសាច់ចម្លកដាក់អោយត្រជាក់ ឬ បង្កក** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ ក្រាម | ៥ | ៣ | ១០០,០០០ | ១០,០០០,០០០ |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ៣ | ៤ | ១,០០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ៣ | ១០០ | ៥,០០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **២‑ម្ហូបរៀបផ្សំអំពីសាច់ត្រីចិញ្ច្រាំនៅឆៅដាក់អោយត្រជាក់ ឬបង្កក** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ២ | ១,០០០,០០០ | ១០,០០០,០០០ |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ១,០០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ៥,០០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៣‑សណ្តាន ខ្យង ខ្ចៅ មានសំបកសន្ទះពីរ នៅឆៅ (ស្វែងរកក្នុងល្បាយសាច់ និង ទឹកចន្លោះសំបកចំណុះ ១០០ មីលីលីត្រ )** | | | | |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ៣០០ | ៣,០០០ |
| ស្ត្រិបតូកូកប្រភពពីលាមក*(Faecal streptococci)* ក្នុង ១ក្រាម | ៥ | ២ | ២,៥០០ | ៥,០០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |

| | | | | |
|---|---|---|---|---|
| **៤. សត្វបក្ខជាតិ (ក្ងាន បក្ខ) ចំអិនទាំងមូល ដាក់អោយត្រជាក់ ឬបង្កក** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ១ | ១០០,000 | ១០,000,000 |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ១ | ១ | ១០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ១ | ១០ | ១,000 |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | 0 | 0 | |
| **៥. សត្វបក្ខជាតិនៅឆៅ បង្កក** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ៣ | ១,000,000 | ១០,000,000 |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ៣ | ១០ | ១០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ៣ | ១០០ | ៥,000 |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | 0 | 0 | |

**<u>តារាងទី ២</u>: សាច់សត្វគ្រប់ប្រភេទ បសុបក្សី និងផលិតផលចេញពីសាច់សត្វទាំងនោះ**

| **រាយមុខ** | n | c | m | M |
|---|---|---|---|---|
| **១. គ្រោងឆ្អឹងឬគ្រោងឆ្អឹងកាត់ជាដុំនៅដំណាក់ មុនការលក់រាយដាក់អោយត្រជាក់ ឬបង្កក** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ៣ | ១,000,000 | ១០,000,000 |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | 0 | 0 | |
| **២. សាច់គ្រប់ប្រភេទទេចខ្ទប់ជាចំណែកសំរាប់ការលក់រាយ** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ៣ | ១,000,000 | ១០,000,000 |
| កូលីហ្វមប្រភពពីលាមក*(Faecal coliforms)* ក្នុង១ក្រាម | ៥ | ២ | ៣០០ | ១០,000 |

| | | | | |
|---|---|---|---|---|
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ៥,០០០ |
| ក្លូសទ្រីឌីយ៉ូមពែរហ្វ្រិងសិន*(Clostridium perfringens)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ១០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៣-  សាច់ចិញ្រ្ចាំគ្រប់ប្រភេទ** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ២ | ៥០០,០០០ | ៥,០០០,០០០ |
| កូលីហ្វមប្រភពពីលាមក*(Faecal coliforms)* ក្នុង១ក្រាម | ៥ | ២ | ១០០ | ១,០០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ៥,០០០ |
| ក្លូសទ្រីឌីយ៉ូមពែរហ្វ្រិងសិន*(Clostridium perfringens)* ក្នុង ១ក្រាម | ៥ | ២ | ៣០ | ១,០០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៤- ផ្នែកបន្ទាប់បន្សំ-គ្រឿងក្នុង (នៃសត្វយកសាច់)** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ៣ | ៥០០,០០០ | ៥០,០០០,០០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ១ | ០ | |
| **៥- បសុបក្សីនៅនឹងមូល** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ៣ | ៥០០,០០០ | ១០,០០០,០០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុងសាច់ដុំទ្រូង ២៥ក្រាម | ៥ | ១ | ០ | |

| | | | | |
|---|---|---|---|---|
| **៦.សាច់បសុបក្សីខ្ចៃ និងសាច់ បសុបក្សីជា ចំណិតស្តើងសាច់បសុបក្សីហូតឆ្អឹងចេញ(នៅឆៅ)** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ២ | ១,000,000 | ១០,000,000 |
| កូលីហ្វមប្រភពពីលាមក*(Faecal coliforms)* ក្នុង១ក្រាម | ៥ | ២ | ១,000 | ១០,000 |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ៥00 | ៥,000 |
| ក្លូសទ្រីឌីយ៉ូមពែរហ្វ្រិងសិន*(Clostridium perfringens)* ក្នុង ១ក្រាម | ៥ | ២ | ៣0 | ១,000 |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ១ ក្រាម | ៥ | 0 | 0 | |
| **៧.សាច់បសុបក្សីឆ្អិនហើយខ្ចៃ និងបសុបក្សី ចំអិន** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ២ | ៣00,000 | ១០,000,000 |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣00 |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ១00 | ៣,000 |
| ក្លូសទ្រីឌីយ៉ូមពែរហ្វ្រិងសិន*(Clostridium perfringens)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣00 |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | 0 | 0 | |
| **៨.ផលិតផលរៀបចំពីសាច់ជ្រូកឆៅសំរាប់ បរិភោគក្រោយចំអិន** | | | | |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១,000 | ៣0,000 |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ១,000 | ១០,000 |

| | | | | |
|---|---|---|---|---|
| ក្លូសទ្រីឌីយ៉ូមពែរហ្វ្រិងសិន(*Clostridium perfringens*) ក្នុង ១ក្រាម | ៥ | ២ | ១០០ | ៣,០០០ |
| សាល់ម៉ូណែលឡា (*Salmonella*) ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៩_ផលិតផលរៀបផ្សំពីសាច់ជ្រូកឆ្អិន ម្ហូបចំអិនស្រេច ធ្វើពីសាច់ ឬត្រី និង ជុំសាច់ឆ្អិន** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ២ | ១,០០០,០០០ | ៥,០០០,០០០ |
| កូលីហ្វមប្រភពពីលាមក (*Faecal coliforms*) ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស (*Staphylococcus aureus*) ក្នុង ១ក្រាម | ៥ | ២ | ១០០ | ៣,០០០ |
| ក្លូសទ្រីឌីយ៉ូមពែរហ្វ្រិងសិន(*Clostridium perfringens*) ក្នុង ១ក្រាម | ៥ | ២ | ៣០ | ១,០០០ |
| សាល់ម៉ូណែលឡា (*Salmonella*) ក្នុង ២៥ក្រាម | ៥ | ០ | ០ | |

**<u>តារាងទី ៣:</u> ទឹកដោះគោ និងផលិតផលអំពីទឹកដោះគោ**

| **រាយមុខ** | n | c | m | M |
|---|---|---|---|---|
| **១_ទឹកដោះគោកំដៅរំខាប់មេរោគតាមវិធីប៉ាស្ទ័រ ទេចខ្ចប់** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ ម.ល | ១ | | ៣០,០០០ | ១,០០០,០០០ |
| កូលីហ្វម (*Coliforms*) ៣០ °C ក្នុង ១ ម.ល (ចេញពីរោងចក្រ) | ១ | | ១ | ១០ |
| កូលីហ្វម (*Coliforms*) ៣០ °C ក្នុង ១ ម.ល (លក់រាយ) | ១ | | ១០ | ១០០ |
| កូលីហ្វមប្រភពពីលាមក (*Faecal coliforms*) ក្នុង ១ ម.ល | ១ | | ១ | ១ |
| សាល់ម៉ូណែលឡា (*Salmonella*) ក្នុង ២៥០ ម.ល | ១ | | ០ | |
| **២_ទឹកដោះគោធ្វើអោយឡើងមេ** | | | | |

| | | | | |
|---|---|---|---|---|
| កូលីហ្វម *(Coliforms)* ៣០ °C ក្នុង ១ ក្រាម | ៥ | ២ | ៣០ | ១០០ |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៣- ទឹកដោះគោបំលែងធាតុជាចាហួយ និងបង្អែមមានជាតិទឹកដោះគោ** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ២ | ១,០០០ | ៣០,០០០ |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ៣ | ៣០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៤-ទឹកដោះគោម្សៅ** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ក្រាម | ៥ | ២ | ៥០,០០០ | ១,០០០,០០០ |
| កូលីហ្វម *(Coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ១០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ១ | ១០ | ១០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៥ - ប្រូម៉ាស្រស់កំដៅសំលាប់មេរោគតាមវិធីប៉ាស្ទ័រ** | | | | |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៦ - ប្រូម៉ាសាច់ស្អិត រឹង ឬស្ទើររឹង** | | | | |

| | | | | |
|---|---|---|---|---|
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ១ | ១០០ | ១០,០០០ |
| **៧ - ប្រហិតសាច់មេ្សៀរស្លិត ជ្រាយ** | | | | |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ១០,០០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ១ | ១០០ | ១០,០០០ |
| **៨- ចំរក់ដៅរំខាប់មេរោគតាមវិធីប៉ាស្ទ័រ** | | | | |
| មេរោគ Gram- ចំនួនសរុប *(Gram Negative Total Count)* ក្នុង១ក្រាម | ៥ | ២ | ១០០ | ១០,០០០ |
| កូលីហ្វម *(Coliforms)* ៣០ °C ក្នុង ១ក្រាម | ៥ | ២ | ២៥ | ១,០០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ២ | ០ | ០ |

**៩-ទឹកដោះគោរំខាប់មេរោគដោយវិធីស្ទើរីល**

បរិមាណគំរូដែលយក គឺមានទឹកដោះគោដាក់ក្នុងសំបកវេចខ្ចប់ចំនួនប្រាំដែលដកយកចេញពីឡូត៍ផលិតផលតែមួយ ។ ការវិភាគគំរូនេះមានសកម្មភាពដូចតទៅ :

- រក្សាគំរូចំនួនពីរទាំងសំបក ក្នុងទូកំដៅ នៅសីតុណ្ហភាព ៣២ °C ± ២ °C ក្នុងរយៈពេល ៧ថ្ងៃ ។
- រក្សាគំរូចំនួនពីរទាំងសំបក នៅ ៥៥ °C ± ២ °C ក្នុងរយៈពេល ៧ថ្ងៃ ។
- ការពិនិត្យឃើញក្រោយការកំដៅរួច :
  - គ្មានភាពប៉ោង ឬការលេចចេញណាមួយឡើយ ។
  - ការពិនិត្យដោយញាណៈគ្មានកំណកជាដុំ គ្មានប្រតិកម្មបំបែកប្រូតេអ៊ីន គ្មានភាពខុសប្លែកផ្នែករសជាតិ ឬ ក្លិនឡើយ ។
  - វាស់ pH : កំរិតនៃលំអៀង pH រវាងទឹកដោះគោដែលរក្សាទុកក្នុងទូកំដៅ និងទឹកដោះគោជាគោលត្រូវមានកំរិតទាបជាង ០,៣ ។
  - វិធីសាកល្បងនៃចំណុចពុះ : ក្រោយអំពីការពន្លិចចូលទៅក្នុងទឹកកំពុងពុះ កំដៅ ១០០°C អស់រយៈពេល១០នាទីមិនត្រូវមានដុំកកតូចៗ (Floculation) ឬ ការកកពេញ (Coagulation) ឡើយ ។

- វាស់កំរិតជាតិអាស៊ីត(ដែលអាចបង្ហាញចេញជាបរិមាណបាន) : កំរិតជាតិអាស៊ីតនេះ ត្រូវទាបជាង ១៨° Dornic ។
- រាប់ចំនួនអតិសុខុមកាយរស់ដោយត្រូវការខ្យល់(មជ្ឈដ្ឋាន" Plate count agar") និងអតិសុខុមរស់ដោយគ្មានខ្យល់ (មជ្ឈដ្ឋានសាច់ផ្សិតដំបែ) ក្នុង៣២ °C និង ៥៥ °C ។ ចំនួន អតិសុខុមកាយនានា ត្រូវតែទាបជាង ឬស្មើនឹង ១០ ក្នុងទឹកដោះគោ ចំនួន 0,១ ម.ល ។

## តារាងទី ៤ : នំផ្អែមធ្វើដោយម្សៅ ការ៉េមកក និងការ៉េម

| **រាយមុខផលិតផល** | n | c | m | M |
|---|---|---|---|---|
| **១. នំផ្អែមធ្វើដោយម្សៅ ក្រែម ចំអិនដាក់លើនំធ្វើពីម្សៅ** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០°C ក្នុង ១ ក្រាម | ៥ | ២ | ៣០០,០០០ | ៥,០០០,០០០ |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ១០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ៣,០០០ |
| ក្លូសទ្រីឌីយ៉ូមពែរហ្វ្រិងសិន *(Clostridium perfringens)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៥០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **២. ការ៉េមកក និងការ៉េម** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ ក្រាម | ៥ | ២ | ៣០០,០០០ | ៥,០០០,០០០ |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ១ | ១០ | ៥០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |

**តារាងទី៥ : ផលិតផលផ្កាច់ទឹកចេញ ពុំមានចាត់ជាក្រុមនៅផ្នែកផ្សេង និងផលិតផលផ្សេងៗ**

| **រាយមុខផលិតផល** | n | c | m | M |
|---|---|---|---|---|
| **១. ល្បាយសំរាប់ធ្វើនំដែលមានស៊ុតឬមានម្សៅស្ងួតលាយស៊ុត** | | | | |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| ផ្សិតនានា *(Mould)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ១០,០០០ |
| **២. ស៊ុបគ្រប់ប្រភេទ** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ ក្រាម | ៥ | ២ | ១០០,០០០ | ១០,០០០,០០០ |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ៣០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម | ៥ | ១ | ១០០ | ១០,០០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៣. គ្រឿងទេស** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ ក្រាម | ៥ | ២ | ១០០,០០០ | ១០,០០០,០០០ |
| ផ្សិតនានា *(Mould)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ១០,០០០ |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ១,០០០ |
| **៤. ផ្លែឈើក្រៀមនានា** | | | | |
| ផ្សិតដំបែ *(Yeast)* ក្នុង ១ក្រាម | ៥ | ២ | ១០ | ១,០០០ |
| ផ្សិតនានា *(Mould)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ១០,០០០ |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | តិចជាង ៣ | ១០ |
| **៥. ផលិតផលកែច្នៃចេញពីធញ្ញជាតិ(ម្សៅមីកញ្ចប់ស្រូវសាលី)** | | | | |
| ផ្សិតនានា *(Mould)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ១០,០០០ |

| | | | | |
|---|---|---|---|---|
| ក្លូសទ្រីឌីយ៉ូមពែរហ្វ្រិងសិន*(Clostridium perfringens)* ក្នុង ១ក្រាម | ៥ | ១ | ១០០ | ១០,០០០ |
| ស្ព័រនៃអតិសុខុមកាយដែលរស់ដោយគ្មានខ្យល់ *(Anaerobe Spores)* នៅកំរិត សីតុណ្ហភាព ៣៧ °C | ៥ | ១ | ១,០០០ | ១០០,០០០ |
| **៦. សូកូឡា កាកាវ** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ ក្រាម | ៥ | ២ | ១០,០០០ | ១,០០០,០០០ |
| ស្តាហ្វីឡូកូគូស អូរេអ៊ុស *(Staphylococcus aureus)* ក្នុង ១ក្រាម (ចំពោះសូកូឡា បន្ទះ ឬជាម្សៅស្ងួត) | ៥ | ២ | ១០០ | ១,០០០ |
| ផ្សិតនានា *(Mould)* ក្នុង ១ក្រាម | ៥ | ២ | ១០០ | ១០,០០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៧. រុក្ខជាតិក្រៀម** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ ៣០ °C ក្នុង ១ ក្រាម | ៥ | ២ | ១,០០០,០០០ | ១០,០០០,០០០ |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | ៣ | ១០០ |
| ស្ព័រ នៃអតិសុខុមកាយដែលរស់ដោយគ្មានខ្យល់ ស៊ុលហ្វីត រេដុករ *(Sulfite Reducing Anaeroble spores)* នៅកំរិត សីតុណ្ហភាព ៤៦ °C ក្នុង ១ក្រាម | ៥ | ២ | ១០ | ១,០០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |
| **៨. ផ្សិតដំបែ** *(Yeast)* | | | | |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១ក្រាម | ៥ | ២ | តិចជាង ៣ | ១០០ |
| សាល់ម៉ូណែលឡា *(Salmonella)* ក្នុង ២៥ក្រាម | ៥ | ០ | ០ | |

**តារាងទី ៦ : ទឹក និងភេសជ្ជៈនានា**

| **រាយមុខផលិតផល** | n | c | m | M |
|---|---|---|---|---|
| **១. ទឹកបរិភោគតាមបណ្តាញចែកចាយ និង ទឹកច្រកដប** | | | | |

| | | | | |
|---|---|---|---|---|
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ នៅកំរិត ៣៧ °C ក្នុង ១ ម.ល | ១ | | ២០ | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ នៅកំរិត ២០ °C ក្នុង ១ ម.ល | ១ | | ១០០ | |
| កូលីហ្វម *(Coliforms)* នៅកំរិត ៣៧ °C ក្នុង ១០០ ម.ល | ១ | | <១០ | |
| កូលីហ្វមប្រភពពីលាមក *(Faecal coliforms)* ក្នុង ១០០ ម.ល | ១ | | 0 | |
| ស្ត្រិបតូកូគប្រភពពីលាមក *(Faecal streptococci)* ក្នុង ៥០ ម.ល | ១ | | 0 | |
| ស្ព័រ នៃក្លូទ្រីឌីយ៉ូម ស៊ុលហ្វីត រេដុករ *(Sulfite reducing clostridium spores)* ក្នុង ២០ ម.ល | ១ | | 0 | |
| **២_ទឹករ៉ែដាក់ដបជាលក្ខណៈធម្មតា ឬ មាន បញ្ចូលឧស្ម័នកាបូនិក** | | | | |
| អតិសុខុមកាយដែលរស់ដោយត្រូវការខ្យល់ នៅកំរិត ៤២ °C ក្នុង ១ ម.ល | ៥ | 0 | <១០០ | |
| កូលីហ្វម *(Coliforms)* នៅកំរិត ៣៧ °C ក្នុង ១ ម.ល | ៥ | 0 | 0 | |
| ស្ត្រិបតូកូគប្រភពពីលាមក *(Faecal streptococci)* ក្នុង ១ ម.ល | ៥ | 0 | 0 | |
| ស្ព័រ នៃក្លូសទ្រីឌីយ៉ូម ស៊ុលហ្វីត រេដុករ *Sulfite reducing clostridium spores)* នៅ ៤៦ °C ក្នុង ១ ម.ល | ៥ | 0 | 0 | |
| **៣_សំបកវេចខ្ចប់សំរាប់ច្រកទឹក និងច្រកភេសជ្ជៈ ( ដែលត្រូវច្រកដប )** | | | | |
| អតិសុខុមកាយសរុបក្នុងប្រដាប់ច្រកមួយ | ៥ | ២ | ១០ | ១០០ |
| **៤_ ទឹកផ្លែឈើ ឬទឹកបន្លែនានា** | | | | |
| ផ្សិតដំបែរដែលបង្កអោយឡើងមេ ក្នុង ១ ម.ល | ៥ | ២ | 0 | ១,000 |
| សរសៃឆ្មារនៃផ្សិតនានាក្នុងវង្វង់អតិសុខុមទស្សន៍តាមការរែកធាតុលើកញ្ចក់ *( Mould mycelium )* | ៥ | ១ | វត្ថុមានក្នុង ២០%យ៉ាង ច្រើន | |

| | | | | |
|---|---|---|---|---|
| ឡឺកូណូស្តុកស៊ីត្រូវ៉ូរូម*(leuconostoc citrovorum)* ក្នុង ១ ម.ល ចំពោះផ្លែក្រូច នានា | ៥ | ០ | ០ | វត្តមាន |
| **៥. ភេសជ្ជៈមានបញ្ចូលឧស្ម័នកាបូនិក** | | | | |
| ផ្សិតដំបែ *(Yeast)* | ៥ | ២ | ពុំមានវត្តមានផ្សិតដែលបង្កអោយឡើងមេ | ១,០០០ |
| សរសៃឆ្មារនៃផ្សិតនានាក្នុងវង្វង់នៃអតិសុខុមទស្សន៍តាមការ រើកធាតុលើកញ្ចក់ *(Mould mycelium)* | ៥ | ១ | វត្តមានក្នុង ២០%យ៉ាងច្រើន | |

## <u>**តារាងទី ៧**</u> **: អាហារដាក់ប្រអប់បិទជិត** *(Canned Foods)*

ទោះមានប្រភេទសំបកវេចខ្ចប់បែបណាក៏ដោយ អាហារដាក់ប្រអប់បិទជិត ត្រូវបំពេញបាននូវវិធីសាកល្បងត្រួតពិនិត្យនានា ដែលអាចបញ្ជាក់បាននូវស្ថេរភាពរបស់វា ។

ពុំត្រូវអោយមានការត្រួតពិនិត្យបែបនេះទេ ចំពោះអាហារដាក់ប្រអប់លោហធាតុឬកែវបំពង់មានគំរបអាចខូចទ្រង់ទ្រាយ ដែលបង្ហាញអោយឃើញនូវភាពមិនគ្រប់លក្ខណៈធំដុំ ដូចជាស្នាមប៉ោងទូទៅ ប៉ោងដោយដុំ ឬស្នាមធ្លាយលេច ។ អាហារដាក់ក្នុងសំបកវេចខ្ចប់អំពីប្លាស្ទិក ឬប្លាស្ទិកស្រោបលោហធាតុ ដែលបង្ហាញអោយឃើញនូវការប្រែរាងឃើញស្ដែងនៃសំបកវេចខ្ចប់ ក៏ពុំត្រូវទទួលការត្រួតពិនិត្យបែបនេះដែរ ។

ដើម្បីសំរេចបាននូវការពិនិត្យសាកល្បងនេះ គេត្រូវការចាំបាច់អោយមានកំប៉ុង មានរាងល្អប្រក្រតីចំនួន៥ មានលេខ សំគាល់ផលិតកម្មដូចគ្នា ។

វិធីសាកល្បងត្រួតពិនិត្យមានសកម្មភាពដូចតទៅនេះ :-

- អាហារប្រអប់ជាសាច់សត្វ ឬ មានប្រភពពីសាច់សត្វ:
  - រក្សាគំរូ ពីរ ប្រអប់ ក្នុងទូកំដៅ នៅ ៣៧ °C ± ១ °C ក្នុងរយៈ ពេល ១៥ថ្ងៃ ។
  - រក្សាគំរូ ពីរ ប្រអប់ ក្នុងទូកំដៅនៅ ៥៥ °C ± ២ °C ក្នុងរយៈ ៧ថ្ងៃ ។
  - ប្រអប់ជាគោលមួយទៀតទុកក្នុងសីតុណ្ហភាពនៃធាតុអាកាសជុំវិញធម្មតា ( ចន្លោះ២០ °C ទៅ ២៥ °C ) ។
- អាហារពីជារុក្ខជាតិដាក់ប្រអប់បិទជិត:
  - រក្សាគំរូពីរប្រអប់ក្នុងទូកំដៅ នៅ ៣០ °C ± ២ °C ក្នុងរយៈ ២១ថ្ងៃ ។
  - រក្សាគំរូ ពីរ ប្រអប់ ក្នុងទូកំដៅនៅ ៥៥ °C ± ២ °C ក្នុងរយៈ ៧ថ្ងៃ ។ ការរក្សាទុកក្នុងទូកំដៅ នេះមិនត្រូវអនុវត្តចំពោះអាហារប្រអប់មានលក្ខណៈអាស៊ីត (pH<4.5) ឡើយ ។

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគថវិកា ចូលរួមចំណែកក្នុងការកសាង ព្រះវិហារ នៅវត្តខ្សាងត្បូង និង ជួយកសាងសមិទ្ធផលផ្សេងៗទៀត នៅក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមនេះ :-

| | | | | |
|---|---|---|---|---|
| ១-ឧបាសក | **ស្រី** | **ឌឹម** | ថវិកា ចំនួន | ១១.៥០០ ដុល្លារ |
| ២-ឧបាសិកា | **សូរ** | **គឹមឃួត** | ថវិកា ចំនួន | ១១.០០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹតត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការតម្លើងអធិការដ្ឋាន របស់ក្រសួងបរិស្ថាន ទៅជាអគ្គាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សំរេច

**មាត្រា ១ៈ** តែងតាំង

១- លោក **អ៊ឹង សេង** បច្ចុប្បន្នអធិការ ជាអគ្គាធិការរងនៃអគ្គាធិការដ្ឋានក្រសួងបរិស្ថាន

២- លោក **ម៉េង សារុធ** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ជាអធិការនៃអគ្គាធិការដ្ឋាន ក្រសួងបរិស្ថាន

៣- លោក **ឈុន ប៊ុនលី** បច្ចុប្បន្នជាអនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ជាអធិការ នៃអគ្គាធិការដ្ឋានក្រសួងបរិស្ថាន

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយបានសំរេចចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣*

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ស ម្រេ ច**

**មាត្រា ១** : ត្រូវបានតែងតាំងជាអគ្គលេខាធិការរង និង ប្រធាននាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា នូវមន្ត្រីដែលមានរាយនាម ដូចខាងក្រោម :

| | | |
|---|---|---|
| ១. លោក | **ជេត ជាលី** | ជាអគ្គលេខាធិការរង មានឋានៈស្មើ អគ្គនាយករង |
| ២. លោក | **ស៊ូ សុផាន** | ជាអគ្គលេខាធិការរង មានឋានៈស្មើ អគ្គនាយករង |
| ៣. លោក | **ម៉ៅ ប៊ុននិន** | ជាប្រធាននាយកដ្ឋាន កិច្ចការទូទៅ |
| ៤. លោក | **ម៉ក់ ឧយ** | ជាប្រធាននាយកដ្ឋាន ស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំ |
| ៥. លោក | **សាបូ អូហ្សាណ្ណ** | ជាប្រធាននាយកដ្ឋាន សហប្រតិបត្តិការ និង ពតិមាន |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយ ស្ថិរវឌ្ឍនា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ NS / KRT-34 ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង

## ស ម្រេ ច

<u>**មាត្រា១**</u> : ត្រូវបានបំពាក់ **មេដាយមាស ស្ថិរវឌ្ឍនា** ជូនថ្នាក់ដឹកនាំ នៃក្រសួងព្រះបរមរាជវាំង ចំនួន ០៥ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចក្នុងឆ្នាំ ២០០២ ដូចមានរាយនាមខាងក្រោមនេះ :

១- ឯកឧត្តម **គុយ សុផល**

២- ឯកឧត្តម **មាឃ សំភួន**

៣- ឯកឧត្តម **អន សំរម**

៤- ឯកឧត្តម **ឈា ហន**

៥- ឯកឧត្តម **អ៊ុំ ឯម**

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី , រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៣២ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៤រូប ដែលបានបរិច្ចាគធនធាន ជួយកសាងផ្លូវលំជនបទ និង វត្តអារាម នៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិ :**

១-ឯកឧត្តម **ឈាង ចុន** ថវិកា ចំនួន ១០.០០០ USD

២-ឧកញ៉ា **ឡុង ហ៊ុំង** ថវិកា ចំនួន ១០.០០០ USD

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **ប៊ុន ឡើង** អ្នកស្រី **សួស ឆវី** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.៣៣៨ USD

**គ_មេដាយសំរិទ្ធស្ថាបនាជាតិ :**

-លោក **សៅ ឆា** អ្នកស្រី **ជុំន អេង** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ២.១១៥ USD

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៣៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកវរសេនីយ៍ឯក **ហេង ពៅ** ដែលបានបរិច្ចាគថវិកា ជួយចាក់សាបទីធ្លាមហាវិទ្យាល័យ នីតិសាស្ត្រ និង វិទ្យាសាស្ត្រ សេដ្ឋកិច្ច ទំហំ ៤.០៥១,៣២ ម$^{២}$ និង ជួយកែលំអ សោភណភាព មហាវិទ្យាល័យ ចំណាយអស់ទឹកប្រាក់ សរុបចំនួន ៣១.០៦៩ , ២៣ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៣៤ អនក្រ-តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

### ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូន លោកវរសេនីយ៍ឯក **LAM MANH HUNG** នាយទាហាន នៃកងទ័ពប្រជាជនវៀតណាម ដែលបានមកបំពេញភារកិច្ចអន្តរជាតិ ជួយបណ្តុះបណ្តាល កង-យោធពលខេមរភូមិន្ទ នៅព្រះរាជាណាចក្រកម្ពុជា អស់រយៈពេល ០៣ ឆ្នាំ ០៧ ខែ ទទួលបានលទ្ធផលល្អប្រសើរ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៣៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូន នាយទាហាន និង នាយទាហានរង នៃសាធារណរដ្ឋបារាំង ចំនួន ០៧រូប ដែលមានស្នាដៃល្អ ក្នុងការមកបំពេញភារកិច្ច ជួយកសាង កងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-វរសេនីយ៍ទោ | **អាឡាំង អាបាឌី** | (Lieutenant-colonel Alain ABADIE) |
| ២-វរសេនីយ៍ទោ | **អង់រី ស៊ឺម៉ាំង** | (Lieutenant-colonel Henri CHEMIN) |
| ៣-វរសេនីយ៍ត្រី | **វែរសាំងហ្សេតូរីក ហ្សូណូ** | (Chef d'escadron Vercingétorix JONOT) |
| ៤-អនុសេនីយ៍ឯក | **ប៉ាស្កាល ប៉ាំងហ្សេ** | (Capitain Pascal PINGET) |
| ៥-អនុសេនីយ៍ឯក | **ស៊ីរីល ស៊ីវ៉ោរសេត** | (Capitain Cyril CHEVAUCHET) |
| ៦-ព្រិន្ទបាលឯក | **គ្រីស្ទង់ ម៉ាទីណេស** | (Adjudant-chef Christian MARTINEZ) |
| ៧-ពលបាលឯក | **ហ្សូអែល ប៊ីយ៉ាំង** | (Sergent-chef Joel BILLIN) |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

145

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៧៦ អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ១៣រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវិស័យអប់រំ សង្គមកិច្ច ព្រះពុទ្ធសាសនា និង គមនាគមន៍ នៅស្រុកតំបែរ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | **ឡៅ** | **អំ** | អភិបាលខេត្តកំពង់ចាម | ថវិកា ចំនួន | ១៣.១៥០ USD |
| ២-ឯកឧត្តម | **ម៉ៅ** | **តិរុណា** | អភិបាលរងទី២ ខេត្តកំពង់ចាម | ថវិកា ចំនួន | ១៣.១៨៥ USD |
| ៣-ឯកឧត្តម | **ញឹក** | **ហួន** | អគ្គបញ្ជាការដ្ឋានកងយោធពល ខេមរភូមិន្ទ | ថវិកា ចំនួន | ១៧.៥៧០ USD |
| ៤-ឯកឧត្តម | **ឡឹង** | **សុវណ្ណឌា** | មេបញ្ជាការយោធភូមិភាគទី២ | ថវិកា ចំនួន | ១៦.១១០ USD |
| ៥-ឯកឧត្តម | **សំ** | **សារិត** | អនុរដ្ឋលេខាធិការ ក្រសួងធនធានទឹក និង ឧតុនិយម | ថវិកា ចំនួន | ១១.៥០០ USD |
| ៦-ឯកឧត្តម | **វេង** | **សាខុន** | អនុរដ្ឋលេខាធិការ ក្រសួងធនធានទឹក និង ឧតុនិយម | ថវិកា ចំនួន | ១៦.៣៥០ USD |
| ៧-ឯកឧត្តម | **ចាយ** | **បូរិន** | ទីប្រឹក្សាសម្តេច ហេង សំរិន | ថវិកា ចំនួន | ១៣.១៣០ USD |
| ៨-ឯកឧត្តម | **ម៉ែន** | **ហាន** | អនុរដ្ឋលេខាធិការក្រសួងផែនការ | ថវិកា ចំនួន | ១២.១៥០ USD |
| ៩-លោក | **មាស** | **សឿន** | ប្រធានមន្ទីរសាធារណការខេត្តកណ្តាល | ថវិកា ចំនួន | ១៣.៥៧៥ USD |
| ១០-លោក | **នឹម** | **ពិសិដ្ឋ** | អភិបាលរងស្រុកតំបែរ | ថវិកា ចំនួន | ១០.៩៨០ USD |
| ១១-លោក | **ណឹម** | **គួច** | សប្បុរសជនក្រុងភ្នំពេញ | ថវិកា ចំនួន | ២៥.៩៣០ USD |

១២-លោក **នាដ្ឋ វ៉ាទុធ** អភិបាលរងស្រុកតំបែរ ថវិកា ចំនួន ១០.៥២០ USD

១៣-លោក **សយ សុផាត** អភិបាលរងស្រុកតំបែរ ថវិកា ចំនួន ១០.៧៥០ USD

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៥៣៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

### ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោក **ខ៊ិម ខែម** ទីប្រឹក្សា ឯកឧត្តម រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលកន្លងមក បានលះបង់កំលាំងកាយចិត្ត ខិតខំបំពេញ ភារកិច្ចយ៉ាងខ្លាំងក្លា លើការងារធម្មការ និង សាសនា ប្រកបដោយមោទនភាពខ្ពស់ ហើយបានទទួលមរណភាព កាលពីយប់ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣ ដោយរោគាពាធ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ០៩រូប ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមចំណែកក្នុងការកសាងព្រះវិហារ នៅវត្តសិលាមណី ហៅ វត្តគ្រួស ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **អ៊ុច ទឹម** | ព្រះចៅអធិការវត្តសិលាមណី | បច្ច័យ | ១២.០០០ ដុល្លារ |
| ២-លោក | **អ៊ុក ជីន** | និង លោកស្រី នៅសហរដ្ឋអាមេរិក | ថវិកា | ១២.៦០០ ដុល្លារ |
| ៣-លោក | **ទិន សាវី** | នៅសហរដ្ឋអាមេរិក | ថវិកា | ១១.៥០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ឧបាសិកា | **ចាន់ទ្យូ ធីន** | នៅសហរដ្ឋអាមេរិក | ថវិកា | ៧.៨០០ ដុល្លារ |
| ២-លោក | **យិន យ៉ាន** | និង លោកស្រី នៅសហរដ្ឋអាមេរិក | ថវិកា | ៥.៣០០ ដុល្លារ |
| ៣-ឯកឧត្តម | **តឹក សំអ៊ុក** | និង លោកជំទាវ នៅរាជធានីភ្នំពេញ | ថវិកា | ៥.១០០ ដុល្លារ |
| ៤-លោក | **ជ័យ ឫទ្ធី** | និង លោកស្រី នៅសហរដ្ឋអាមេរិក | ថវិកា | ៥.០០០ ដុល្លារ |
| ៥-លោក | **លី យុខសារី** | និង លោកស្រី នៅប្រទេសបារាំង | ថវិកា | ៥.០០០ ដុល្លារ |
| ៦-លោក | **កាន់ ខាន់** | និង លោកស្រី គណៈកម្មការទ្រទ្រង់វត្ត | ថវិកា | ៥.២០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៣៩ អនក្រ-កត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

**សំរេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៧ គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមចំណែកក្នុងការកសាងព្រះវិហារ និង សមិទ្ធផលផ្សេងៗទៀត នៅក្នុងវត្តចំប៉ី ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ប៊ុន សោម** | បច្ច័យ | ១០.០៥០ | ដុល្លារ |
| ២-ឧបាសិកា | **កុយ សំ** | ថវិកា | ១៣.០០០ | ដុល្លារ |
| ៣-ឯកឧត្តម | **សោម ចំនួរឹម** | ថវិកា | ១២.០០០ | ដុល្លារ |
| ៤-លោកជំទាវ | **និត្យ សុផាត** ភរិយា ឯកឧត្តម **សោម ចំនួរឹម** | ថវិកា | ១២.០០០ | ដុល្លារ |
| ៥-ឯកឧត្តម | **ញាណ ឡេង** | ថវិកា | ១២.០០០ | ដុល្លារ |
| ៦-លោកជំទាវ | **និត្យ មាលា** ភរិយា ឯកឧត្តម **ញាណ ឡេង** | ថវិកា | ១២.០០០ | ដុល្លារ |
| ៧-លោក | **អៀន ឈឿរ** | ថវិកា | ១០.០៥០ | ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

**ស ម្រ េ ច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយប្រាក់ស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនលោក **ម៉ៅ គឿន** និង លោកស្រី **លឹម យ៉ុន** ដែលបានបរិច្ចាគថវិកា ចូលរួមចំណែកក្នុងការកសាង ព្រះវិហារ នៅក្នុងវត្ត គីរីវង្គត់ ហៅ វត្តភ្នំ-រាប់បាត្រ ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំណាយអស់ទឹកប្រាក់ ចំនួន ៧.៨៨៥ ដុល្លារអាមេរិក។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៤១ អនក្រ.បក-១៩

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **មាស ស៊ុន** ព្រះចៅអធិការវត្តទួលប្រាសាទប្រាំ ដែលបានខិតខំ អំពាវនាវ ពុទ្ធបរិស័ទ ពីគ្រប់មជ្ឈដ្ឋាន ក្នុង និង ក្រៅប្រទេស ព្រមទាំងបច្ច័យផ្ទាល់ព្រះអង្គ យកទៅកសាង សាលាឆាន់ ០១ខ្នង មានបណ្តោយ ប្រវែង ៣៤ម៉ែត្រ ទទឹង ២៦ម៉ែត្រ នៅក្នុងវត្តទួលប្រាសាទប្រាំ ភូមិព្រៃកគានប់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ចំណាយអស់បច្ច័យ សរុបចំនួន ១០៨.៣២៤ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សិយយស

## សំរេច

**មាត្រា ១ :** ត្រូវបានចំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារឥស្លាម នៅភូមិ ៤ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង អស់ថវិកាចំនួន ៣៥.០០០ USD ដូចមានរាយនាមខាងក្រោម ÷

១-លោក **អ៊ីសា ពិន ណាស៊ែរ** ( EISA BIN NASSER ) ពាណិជ្ជករនៅទីក្រុងឌុយបៃ

២-លោកវេជ្ជបណ្ឌិត **ម៉ះម៉ូត កាស៊ីម** ( MAHMOOD KAZIM ) ប្រធានមន្ទីរពេទ្យ គុយវ៉ែត នៅទីក្រុងឌុយបៃ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤៣ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## ស ំ រេ ច

**មាត្រា ១ៈ** ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូនលោក **ឡុង សុះ** សមាជិកសមាគមឥស្លាមកម្ពុជា និង ជាអ៊ីមាំខេត្តកោះកុង ដែលបានចលនាសប្បុរសជនជួយកសាងព្រះវិហារឥស្លាម នៅភូមិ ៤ ឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង រហូតដល់បានបញ្ចប់ការងារជាស្ថាពរ ។

**មាត្រា ២ ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **ឈាន លាង** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ក្រសួងពត៌មាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ_កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សំរេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ និង កងរាជអាវុធហត្ថ ចំនួន ០៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **លឹម ហោ** ប្រធាននាយកដ្ឋានសុរិយោដី នៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

២-លោកវរសេនីយ៍ឯក **សុខ គ្រីន** មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តព្រៃវែង

៣-លោក **អៀង ម៉េងស៊ុន** អគ្គនាយករង កំពង់ផែភ្នំពេញ

៤-លោក **អុខ មង្គល** អនុប្រធាននាយកដ្ឋានរដ្ឋបាល នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

៥-លោក **ជា ស្រួយ** អភិបាលស្រុកព្រះស្តេច ខេត្តព្រៃវែង

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**......៥៤៦......អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន លោក **ម៉ែន សុរិទ្ធី** ដែលបានបរិច្ចាគថវិកា ចូលរួមក្នុងការកសាងព្រះវិហារ វត្តព្រៃពោន ឧបដ្ឋានសាលា វត្តសិរីសាគរ និង អណ្តូងទឹក ចំនួន ២៥អណ្តូង ជូនប្រជាជន នៅក្នុងឃុំកំពង់ត្របែក ឃុំអន្លោង ឃុំប្រធាតុ និង ឃុំថ្កូវ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ចំណាយអស់ទឹកប្រាក់សរុបចំនួន ១១.៣២០ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...៤៦...សសរ...**

**សេចក្តីសំរេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់រៀបចំការអភិវឌ្ឍតំបន់តាថាវ និងប្រាសាទព្រះវិហារ នៃខេត្តព្រះវិហារ**

~~~~~~~

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត /១១៩៨/៧១ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត /០៣០៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- តាមស្មារតីនៃអង្គប្រជុំគណៈរដ្ឋមន្ត្រីចំរុះកម្ពុជា-ថៃ នៅខេត្តសៀមរាប និងខេត្តឧប៊ុនរាជធានី កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៣
- តាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**សំរេច**

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ សំរាប់រៀបចំការអភិវឌ្ឍ តំបន់តាថាវ និងប្រាសាទព្រះវិហារ នៃខេត្តព្រះវិហារ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២-ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៣-ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
~~~~~~~

៤-ឯកឧត្តម **ឆាន់ សារ៉ាន់** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

៥-ឯកឧត្តម **ឌី យ៉ាវ** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៦-ឯកឧត្តម **វ៉ា គឹមហុង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន សមាជិក

៧-ឯកឧត្តម **ឡុង វិសាលោ** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨-ឯកឧត្តម **ឃឹម សារិទ្ធ** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៩-ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០- ឯកឧត្តម **នីយ រឿន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល សមាជិក

១១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈុំ សុជាតិ** នាយរងសេនាធិការចំរុះ និងជានាយកទីចាត់ការព្រំដែន នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

១២- ឯកឧត្តម **គ្រាប តាន់** អភិបាលខេត្តព្រះវិហារ សមាជិក

១៣- លោកឧត្តមសេនីយ៍ទោ **ជុំ ហាក់** នាយរងសេនាធិការ និងជាប្រធានការិយាល័យទី២ នៃកងទ័ពជើងគោក នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

១៤- លោកឧត្តមសេនីយ៍ត្រី **មៀច សុផាណា** ប្រធាននាយកដ្ឋានជនបរទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១៥- លោក **សួស យ៉ារ៉ា** នៅអាជ្ញាធរទេសចរណ៍កម្ពុជា សមាជិក

**ប្រការ២ :** គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ច :

- សិក្សាស្រាវជ្រាវ រៀបចំចងក្រង និងកសាងប្លង់មេ សំរាប់អភិវឌ្ឍន៍តំបន់តាថាវ និងប្រាសាទព្រះវិហារ ជាអាទិ៍ការកំណត់តំបន់នានាមាន ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ អគ្គិសនី ទឹកស្អាត តំបន់ដីលំនៅដ្ឋាន ទីផ្សារលក់ដូរ ប្រព័ន្ធលូទឹក ការការពារបរិស្ថាន សាលារៀន មណ្ឌលសុខភាព មន្ទីរពេទ្យ ដីបំរុងអភិវឌ្ឍន៍សេដ្ឋកិច្ច ដីកសិកម្ម និងដីត្រៀមបំរុងសំរាប់សាងសង់សណ្ឋាគារ ផ្ទះសំណាក់ កន្លែងកំសាន្តនានា រួចសុំការសំរេចពីរាជរដ្ឋាភិបាល
- សហប្រតិបត្តិការជាមួយភាគីថៃ ដើម្បីពិភាក្សាឯកភាពលើគំរោងប្លង់មេ សំរាប់អភិវឌ្ឍន៍តំបន់តាថាវ និងប្រាសាទព្រះវិហារ ជាតំបន់ទេសចរណ៍ វប្បធម៌ និងធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយវិនិយោគិនក្នុង និងក្រៅប្រទេស ដើម្បីធ្វើការវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនានា នៅតំបន់តាថាវ និងប្រាសាទព្រះវិហារ ឱ្យបានស្របតាមគំរោងប្លង់មេ ដែលប្រមុខរាជរដ្ឋាភិបាលបានសំរេច

Ru

4r

- កសាងផែនការសកម្មភាពសំរាប់វិនិយោគសាធារណៈ និងទាក់ទាញវិនិយោគឯកជន ដើម្បីជំរុញល្បឿន នៃការអភិវឌ្ឍតំបន់តាថាវ និងប្រាសាទព្រះវិហារ
- សហការជាមួយសហគមន៍អន្តរជាតិ ដើម្បីកៀរគរសុំជំនួយហិរញ្ញប្បទាន ក្នុងការវិនិយោគសាធារណៈសំខាន់ៗ នៅតំបន់តាថាវ និងប្រាសាទព្រះវិហារ
- អនុវត្តការងារឱ្យបានស្របតាមកិច្ចព្រមព្រៀងអន្តរជាតិដែលនៅជាធរមាន អនុស្សារណៈទ្វេភាគី កម្ពុជា- ថៃ និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារតាមជំហានៗ ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសំរេច ។

**ប្រការ៣ :** - រាល់ការអនុវត្តភារកិច្ចក្នុងប្រការ២ខាងលើនេះ ពុំមានផលប៉ះពាល់ដល់ការកំណត់ខ្សែព្រំដែន និងខ័ណ្ឌសីមា រវាងកម្ពុជា និងថៃ នៅតំបន់នោះទេ ។

**ប្រការ៤ :** - សមាជិកគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំ និងទទួលភារកិច្ចតាមការកំណត់របស់ប្រធាន

- ប្រធានគណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមកចូលរួមប្រជុំតាមការចាំបាច់ ។

**ប្រការ៥ :** - គណៈកម្មការអន្តរក្រសួងនេះ មានលេខាធិការដ្ឋានមួយសំរាប់ជំនួយការ ដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងមានសិទ្ធិប្រើប្រាស់ត្រា និងថវិកា របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តព្រះវិហារ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៧ សសរ

# សេចក្តីសំរេច

## ស្តីពី

## រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រង

## ស្រុកសៀមរាប នៃខេត្តសៀមរាប និង ស្រុកបាត់ដំបង នៃខេត្តបាត់ដំបង

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

**សំ រេ ច**

**ប្រការ ១.-**

សេចក្តីសំរេចនេះ កំណត់រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាបនៃខេត្តសៀមរាប និង ស្រុកបាត់ដំបងនៃខេត្តបាត់ដំបង ដើម្បីសាកល្បងក្នុងការបង្កើតជាមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចអោយមានតុល្យភាព និង ចូលរួមកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ២.-**

រចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងបច្ចុប្បន្ន នៃស្រុកសៀមរាប និង ស្រុកបាត់ដំបង ត្រូវធ្វើការពិនិត្យវាយតំលៃសាកល្បងរៀបចំជាជំហានៗ ឱ្យបានសមស្របតាមសភាពការណ៍ជាក់ស្តែង និង ស្របតាមស្មារតីនៃសេចក្តីសំរេចនេះ ។

**ប្រការ ៣._**

ក្នុងការអនុវត្តន៍សាកល្បង ស្រុកទាំងពីរត្រូវបំពេញតួនាទី និង មុខងារដូចខាងក្រោមនេះ ÷

**តួនាទី :**

- រដ្ឋបាលស្រុកទាំងពីរ មានតួនាទីជំរុញ និង គាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធានដែលស្រុកមាន ប្រកបដោយនិរន្តរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់ស្រុក សំដៅបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋផង និង គោរពផលប្រយោជន៍របស់ជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ ។

- ជាមណ្ឌលសាកល្បងរបស់ខេត្តក្នុងការបំរើសេចក្តីត្រូវការ និង ការផ្តល់សេវាកម្មសាធារណៈផ្សេងៗដល់ប្រជាពលរដ្ឋ ។

**មុខងារ :**

- ផ្តល់សេវាកម្មរដ្ឋបាលសាធារណៈ ដែលប្រជាពលរដ្ឋ សហគ្រាស ឬ ក្រុមហ៊ុន អាជីវករនានាត្រូវការជាចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃ និង ក្នុងធុរកិច្ច តាមរបៀបដែលមានប្រសិទ្ធភាព មានតម្លាភាព និងចំណាយធនធានតិច ដើម្បីបង្កើតបានជាគំរូអភិបាលកិច្ចល្អ ។

- រៀបចំផែនការអភិវឌ្ឍន៍ស្រុក ដោយមានការចូលរួមរបស់ប្រជាពលរដ្ឋ ដែលមានលក្ខណៈសមស្របទៅនឹងផែនការអភិវឌ្ឍន៍ខេត្ត និង ផែនការសេដ្ឋកិច្ច សង្គមកិច្ចរបស់រដ្ឋ ដោយមានការសំរបសំរួលជាមួយផែនការអភិវឌ្ឍន៍ឃុំ ព្រមទាំងកំណត់ធនធានចាំបាច់សំរាប់អនុវត្តផែនការរបស់ខ្លួន។

- សំរបសំរួល និង គាំទ្រដល់ក្រុមប្រឹក្សាឃុំនានា នៃស្រុករបស់ខ្លួន តាមការណែនាំរបស់អភិបាលខេត្តសាមី ដើម្បីឱ្យក្រុមប្រឹក្សាឃុំអនុវត្តបានពេញលេញនូវអំណាច តួនាទី និង ភារកិច្ចដែលបានប្រគល់ឱ្យដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង លិខិតបទដ្ឋានជាធរមានផ្សេងៗ ទៀត ។

- បង្កើនប្រសិទ្ធភាព ក្នុងការអនុវត្តន៍គោលនយោបាយជាតិ និង កម្មវិធីរបស់ក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាល ក្រោមការសម្របសម្រួលពីអភិបាលខេត្តសាមី ដោយមានកិច្ចសហប្រតិបត្តិការ ជាមួយប្រជាពលរដ្ឋ ។

**ប្រការ ៤._**

ក្នុងការអនុវត្តន៍គំរោងសាកល្បងនេះ ស្រុកទាំងពីរត្រូវបានទទួលប្រតិភូកម្មអំណាច ក្នុងនោះមានការដឹកនាំ និង/ឬ សំរបសំរួល និង/ឬ ជំរុញ និង/ឬ ត្រួតពិនិត្យក្នុងការរៀបចំប្លង់គោល ផែនការប្រើប្រាស់ ដីធ្លី

ការសាងសង់ សំណង់នានាតាមការកំណត់ ការកសាង ជួសជុល ថែទាំផ្លូវថ្នល់ ការធ្វើចរាចរ ការចុះបញ្ជី យានយន្ត អាជ្ញាប័ណ្ណ និង លិខិតអនុញ្ញាតដល់ក្រុមហ៊ុនពាណិជ្ជកម្ម សេវាកម្ម សិប្បកម្មខ្នាតតូច និង មធ្យម ការសិក្សាអប់រំ សង្គមកិច្ច វប្បធម៌ សុខាភិបាល និង ការធ្វើនីត្យានុកូលកម្ម ឬ បញ្ជាក់លើឯកសារ ព្រមទាំងឯកសារថតចម្លងផ្លូវការនានា ។

**ប្រការ ៥.-**

ការអនុវត្តនីតួនាទី មុខងារ និង អំណាច ដូចមានចែងក្នុងមាត្រា ៣ និង មាត្រា ៤ នៃ សេចក្តីសំរេចនេះ ត្រូវផ្អែកតាមការណែនាំរបស់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ និង ធ្វើឡើងជាជំហានៗ ស្របតាមសមត្ថភាព និង ធនធានដែលមាន ។

ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ត្រូវធ្វើការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដើម្បីសំរបសំរួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធអំពីការធ្វើប្រតិភូកម្មអំណាច និង ការអនុវត្តនូវ តួនាទី មុខងារ អំណាចរបស់ស្រុកទាំងពីរឱ្យបានសមស្រប ។

**ប្រការ ៦.-**

ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មអំណាច និង ភារកិច្ចដល់ស្រុកទាំងពីរអោយបានសមស្រប ក្រោមការសំរបសំរួលពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង អភិបាលខេត្តសាមី ។

**ប្រការ ៧.-**

ការធ្វើប្រតិភូកម្មអំណាច ដែលធ្វើឡើងដោយក្រសួងស្ថាប័ននីមួយៗ ត្រូវភ្ជាប់ជាមួយនូវការបណ្តុះបណ្តាលការកសាងសមត្ថភាព និង ការផ្តត់ផ្គង់មធ្យោបាយ សំភារៈ ថវិកាសមស្របសំរាប់ស្រុកទាំងពីរ ។

**ប្រការ ៨.-**

ស្រុកនីមួយៗត្រូវដឹកនាំដោយអភិបាលស្រុក ០១ រូប អមដោយអភិបាលរងស្រុកមួយចំនួន ជាជំនួយការ ។

ការកំណត់ចំនួនអភិបាលរងស្រុក និង ការបែងចែកភារកិច្ច របៀបរបបធ្វើការងាររបស់អភិបាល អភិបាលរងស្រុកត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**ប្រការ ៩.-**

សាលាស្រុក ជាទីចាត់ការរដ្ឋបាលរបស់ស្រុក និង ត្រូវគ្រប់គ្រងដោយផ្ទាល់ពីអភិបាលស្រុក មានជំនួយពីប្រធានមន្ទីរស្រុក ។

ប្រធានមន្ទីរស្រុក មានអនុប្រធានមន្ទីរ ០១ រូប ជាជំនួយការ ។

សាលាស្រុក មានការិយាល័យ មួយចំនួន ជាជំនួយការ ។

ការរៀបចំ និង ការប្រព្រឹត្តិទៅនៃសាលាស្រុក ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**ប្រការ ១០.-**

ស្រុកនីមួយៗត្រូវបង្កើតឱ្យមានក្រុមប្រឹក្សាស្រុក ។

ក្រុមប្រឹក្សាស្រុក មានអភិបាលស្រុកជាប្រធាន និងមានអភិបាលរងស្រុក ប្រធានមន្ទីរស្រុក ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី ១ ជំទប់ទី ២ គ្រប់ឃុំចំណុះស្រុក ជាសមាជិក ។

ក្រុមប្រឹក្សាស្រុក ជាអង្គការដែលអភិបាលស្រុក ត្រូវពិគ្រោះយោបល់លើបញ្ហាដែលទាក់ទងនឹង ÷

- ផែនការអភិវឌ្ឍន៍ស្រុក
- គំរោងមេ ផែនការប្រើប្រាស់ដីធ្លី
- គំរោងចំណាយថវិកា
- ការងារផ្សេងទៀត ដែលអភិបាលស្រុកយល់ឃើញថាចាំបាច់ ។

ការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាស្រុក និង ទំនាក់ទំនងរវាងអភិបាលស្រុក និង ក្រុមប្រឹក្សាស្រុក ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**ប្រការ ១១.-**

ត្រូវបង្កើតអោយមាន ការិយាល័យ " **ច្រកចេញចូលតែមួយ** " ចំណុះសាលាស្រុកនីមួយៗ ។ ការិយាល័យ "ច្រកចេញចូលតែមួយ" មានសមត្ថកិច្ចផ្តល់ជូនប្រជាពលរដ្ឋ និងសហគ្រាស នូវសេវាកម្មរដ្ឋបាល ដែលប្រជាពលរដ្ឋត្រូវការជាប្រចាំ អោយបានទាន់ពេលវេលា មានតម្លាភាព និង តាមនីតិវិធីសាមញ្ញ ។

ការិយាល័យនេះត្រូវរៀបចំប្រមូលផ្តុំសេវាកម្ម និង នីតិវិធីរដ្ឋបាលមួយចំនួននៅកន្លែងតែមួយ ។

ការិយាល័យនេះ ជាកន្លែងអតិថិជនត្រូវបានទទួលទម្រង់បែបបទ និង ទទួលពត៌មានគ្រប់គ្រាន់ច្បាស់លាស់ ស្តីពីការផ្តល់សេវាកម្មសាធារណៈផ្សេងៗ នឹងត្រូវបង់កម្រៃសេវាកម្ម ឬ អាករផ្សេងៗ និង ជាកន្លែងផ្តល់នូវលទ្ធផលសំរេចជាផ្លូវការលើសេចក្តីស្នើសុំដល់អតិថិជនវិញ ។

ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យ " ច្រកចេញចូលតែមួយ " ត្រូវកំណត់ដោយប្រកាស

របស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និង មានកិច្ចសហការពីក្រសួងស្ថាប័នដែលពាក់ពន្ធ័ ។

**ប្រការ ១២.-**

ដើម្បីលើកកំពស់អភិបាលកិច្ចល្អ នៅស្រុកនីមួយៗត្រូវបង្កើតអោយមានការិយាល័យ " ប្រជាពលរដ្ឋ " ដែលមានសមត្ថកិច្ចទទួលពាក្យបណ្តឹង និង ផ្តល់ពត៌មានជូនប្រជាពលរដ្ឋ ក្រុមហ៊ុន សហគ្រាស និង អង្គការសង្គមស៊ីវិល ក្នុងករណីមានភាពមិនប្រក្រតី ឬកំហុសឆ្គងរបស់បុគ្គលិកដែលបំរើការងារក្នុងរដ្ឋបាលស្រុក ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃការិយាល័យ " ប្រជាពលរដ្ឋ " ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**ប្រការ ១៣.-**

ក្រសួងស្ថាប័នពាក់ពន្ធ័នានា ត្រូវចាត់មន្ត្រីមានសមត្ថភាពឱ្យទៅបំរើការងារនៅក្នុងការិយាល័យនានារបស់ស្រុក ដើម្បីជួយអភិបាលស្រុក ក្នុងការអនុវត្តន៍កិច្ចការតាមជំនាញរបស់ខ្លួន។

**ប្រការ ១៤.-**

បុគ្គលិក នៃការិយាល័យនានារបស់ស្រុក ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និង ដឹកនាំរបស់អភិបាលស្រុក ។

មន្ត្រីរាជការរបស់ក្រសួងស្ថាប័ន ដែលបំរើការងារនៅស្រុកទាំងពីរនេះ ត្រូវស្ថិតនៅជាមន្ត្រីរាជការរបស់ក្រសួងស្ថាប័នដើមដដែល ប៉ុន្តែការដាក់ពិន្ទុ តំឡើងថ្នាក់ និង ការតែងតាំងក្នុងមុខតំណែង ត្រូវតែមានការយល់ព្រមពីអភិបាលស្រុក ។

រាល់សេចក្តីណែនាំលើការងារជំនាញពីក្រសួងស្ថាប័នសាមី ត្រូវធ្វើតាមរយមន្ទីររបស់ខ្លួននៅថ្នាក់ខេត្ត និង ត្រូវឆ្លងកាត់អភិបាលស្រុក ដែលទទួលខុសត្រូវរៀបចំការអនុវត្តន៍ និង រាយការណ៍ជូនសាលាខេត្ត និង មន្ទីរជំនាញរបស់ក្រសួងស្ថាប័ននោះ ។

**ប្រការ ១៥.-**

ក្នុងរយៈពេលដំបូងនៃការអនុវត្តន៍សាកល្បង អភិបាលស្រុកត្រូវរៀបចំគំរោងចំណាយថវិកាតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ១៦.-**

ក្រសួងមហាផ្ទៃ គឺជាស្ថាប័ននៅថ្នាក់ជាតិ ក្នុងការសំរបសំរួលអនុវត្តគំរោងសាកល្បងនេះ ។

ក្នុងការអនុវត្តនីតិរោងសាកល្បងនេះ ក្រសួងមហាផ្ទៃត្រូវធ្វើការពិគ្រោះ ពិភាក្សាជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងក្រសួងស្ថាប័នពាក់ព័ន្ធនានា ។

ក្នុងការអនុវត្តនីតិរោងសាកល្បងនេះ ក្រសួងមហាផ្ទៃអាចទទួលជំនួយគាំទ្រ ខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអ្នកផ្ដល់ជំនួយក្នុង និង ក្រៅប្រទេស ។

**ប្រការ ១៧.–**

ថ្នាក់ខេត្តត្រូវបង្កើតអោយមាន គណៈកម្មការសំរបសំរួលមួយ ដែលមានសមាសភាព ÷

- អភិបាលខេត្ត ឬ អភិបាលខេត្តរង ១ រូប ដែលតែងតាំងដោយអភិបាលខេត្ត ជាប្រធាន
- តំណាង ១ រូប មកពីក្រសួងមហាផ្ទៃ ជាសមាជិក
- តំណាង ១ រូប មកពីគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ជាសមាជិក
- តំណាង ១ រូប មកពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាសមាជិក
- តំណាង ១ រូប មកពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក
- តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគំរោងនេះ ជាសមាជិក
- តំណាងមកពីមន្ទីរជំនាញដែលពាក់ពន្ធ័នឹងគំរោងនេះ ជាសមាជិក

គណៈកម្មការសំរបសំរួល ត្រូវមានការិយាល័យរបស់ខ្លួនក្នុងសាលាខេត្តបាត់ដំបង និង សាលាខេត្តសៀមរាប ព្រមទាំងមានបុគ្គលិកចាំបាច់សំរាប់ការិយាល័យនេះ ។ ក្នុងការអនុវត្តការងារ សមាជិកគណៈកម្មការត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានគណៈកម្មការ ។ ប្រធានគណៈកម្មការត្រូវធ្វើការពិភាក្សាជាមួយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីកំណត់នូវតំណាងក្រសួងស្ថាប័ន និង មន្ទីរជំនាញពាក់ព័ន្ធ ដែលត្រូវចូលរួមក្នុងគណៈកម្មការនេះ ។ មុនចាប់ផ្ដើមបំពេញការងារគណៈកម្មការត្រូវរៀបចំរបៀបរបបធ្វើការងារ របបប្រជុំ និង របបរាយការណ៍ ឱ្យបានសមស្រប ។

**ប្រការ ១៨.–**

គណៈកម្មការសំរបសំរួលថ្នាក់ខេត្ត មានភារកិច្ចគាំទ្រ និង ត្រួតពិនិត្យការអនុវត្តនីតិរោងសាកល្បងនេះ ដោយអនុលោមតាមស្មារតីនៃសេចក្ដីសំរេចនេះ ច្បាប់ និង លិខិតបទដ្ឋាននានាជាធរមាន ។

**ប្រការ ១៩.–**

ក្រសួងមហាផ្ទៃមានភារកិច្ចធ្វើសេចក្ដីរាយការណ៍រៀងរាល់ ៣ ខែម្ដង ជូនគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល អំពីដំណើរការ អនុវត្តគំរោងនេះ និង

B Bang & Sreao Pilot Decision S.R. 1 5/29/2003

សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើសេចក្តីរាយការណ៍ជូនគណៈរដ្ឋមន្ត្រី អំពី អនុសាសន៍ បទពិសោធន៍ នៃការអនុវត្តន៍គំរោងនេះ ដើម្បីពង្រីកការរៀបចំគ្រប់គ្រងស្រុក នៅទីប្រជុំជនខេត្ត ដទៃទៀត ។

**ប្រការ ២០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ អភិបាលខេត្តបាត់ដំបង និងអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុក អនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***ចម្លងជូន :***

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- សាលាខេត្តសៀមរាប
- សាលាខេត្តបាត់ដំបង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៩. សារាចរ

# សារាចរណែនាំ

## ស្តីពី

## ការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្ម សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ ក្នុងព្រះជន្មគំរប់ ៦៧ យាងចូល ៦៨ ព្រះវស្សា

ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ក្នុងព្រះជន្មគំរប់ ៦៧ យាងចូល ៦៨ព្រះវស្សា នឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃ ពុធ ទី១៨ ខែមិថុនា ឆ្នាំ២០០៣ ខាងមុខនេះ ។

- ដើម្បីសំដែងនូវភក្តីភាពប្រកបដោយកតញ្ញុតាធម៌ តបស្នងសងព្រះមហាករុណាទិគុណដ៏ធំធេងក្នុងមនោសញ្ចេតនាគោរពដឹងព្រះគុណដ៏ជ្រាលជ្រៅ ចំពោះសម្តេចម៉ែ ដែលព្រះអង្គបានលះបង់ព្រះកាយពល ក្នុងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម ដើម្បីបុព្វហេតុជាតិមាតុភូមិអង្គរជាទីស្នេហា និងប្រជារាស្ត្រ ជាកូនចៅ ចៅទួតរបស់ព្រះអង្គ ពិសេសលើវិស័យមនុស្សធម៌ សង្គមកិច្ច សុខមាលភាពទូទៅ ។ល។

- ដើម្បីចូលរួមអបអរសាទរ ថ្វាយព្រះពរសព្ទសាធុការ បវរមហាប្រសើរ ចំពោះសម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ក្នុងឱកាសព្រះរាជពិធីបុណ្យចំរើនព្រះជន្មរបស់ព្រះអង្គ ក្នុងព្រះជន្មគំរប់ ៦៧ យាងចូល ៦៨ ព្រះវស្សា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំ ដូចតទៅនេះ :

១-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ សាលាខេត្ត-ក្រុង សាលារៀន រោងចក្រ សហគ្រាស និងគ្រឹះស្ថាន ក្រុមហ៊ុនឯកជននានា ត្រូវរៀបចំតុបតែង បដា ពាក្យស្លោក តាំងព្រះឆាយាលក្ខណ៍សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** មានតាំងភ្លើងពណ៌ និងមានពាក្យស្លោក ថ្វាយព្រះពរ ។

២-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង ត្រូវធ្វើលិខិតថ្វាយព្រះពរសម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ឱ្យបានមុនថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣ និងផ្ញើជូនបណ្តាញសារពត៌មាន វិទ្យុ និងទូរទស្សន៍ កាសែត ដើម្បីផ្សព្វផ្សាយ ឱ្យបានទូលំទូលាយ ។

៣-ក្រសួងព្រះបរមរាជវាំង និង គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ឱ្យបានសមស្របទៅនឹងប្រពៃណីសាសនា និងប្រពៃណីជាតិ តាមការសព្វព្រះរាជហឫទ័យរបស់សម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ។

៤-ក្រសួងពត៌មាន ត្រូវចាត់តាំងរៀបចំកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ជាតិ-ឯកជន អំពីព្រះរាជជីវប្រវត្តិ ព្រះរាជសកម្មភាព និងស្នាព្រះហស្តរបស់សម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ចំពោះប្រទេសជាតិ និងចំពោះ ប្រជារាស្ត្រ ឱ្យបានទូលំទូលាយ ។

៥-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់បណ្តាមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត-ក្រុង ចាត់តាំងសំដែងសិល្បៈ ជូនមហាជនទស្សនាកំសាន្តសប្បាយទៅតាមទីធ្លាសាធារណៈ នៅថ្ងៃ ពុធ ទី ១៨ ខែ មិថុនា ឆ្នាំ ២០០៣ តាមខ្លឹមសារ និងពេលវេលាសមស្រប ។

៦-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំជាក់ស្តែងដល់អង្គភាព ក្រោមឱវាទខេត្ត-ក្រុង បង្កើនកិច្ចការពារ រក្សាសណ្តាប់ធ្នាប់សង្គម សុវត្ថិភាព សន្តិសុខ បង្កលក្ខណៈ ជូនប្រជាពលរដ្ឋកំសាន្តសប្បាយ អបអរសាទរក្នុងព្រះរាជពិធីបុណ្យនេះ ឱ្យបានឧឡារិកអធិកអធម ស័ក្តិសមទៅនឹងព្រះកិត្តិនាម និងព្រះគុណូបការៈដ៏ធំធេងនៃសម្តេចម៉ែ ជាទីសក្ការៈ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញនិងគ្រប់ខេត្ត-ក្រុងត្រូវចាត់ តាំងអនុវត្តឱ្យទទួលបានលទ្ធផលល្អប្រសើរ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង
- ឯកសារ- កាលប្បវត្តិ

# ពាក្យស្លោក

---

- សូមថ្វាយព្រះពរសម្តេចម៉ែ ជាទីគោរពសក្ការៈ ក្នុងព្រះជន្មគំរប់ ៦៧ យាងចូល ៦៨ព្រះវស្សា សូមព្រះអង្គមានព្រះជន្មាយុយឺនយូរ
- សូមថ្វាយព្រះពរបវរមហាប្រសើរ សម្តេចឪ សម្តេចម៉ែ មានព្រះសុខភាពល្អ បរិបូរណ៍ និងព្រះជន្មាយុយឺនយូរ
- ជយោ ! ព្រះរាជាណាចក្រកម្ពុជា
- ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍
- ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ
- ជាតិ សាសនា ព្រះមហាក្សត្រ ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៨-០៣-០៥៤ ប្រក

# ប្រកាស

## ស្តីពី

## រចនាសម្ព័ន្ធនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់
## និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ: នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ: នស/រកត/០២០២/០៣៩ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមប្រកាសលេខ: ធ៨៩៨-៣៨៥ប្រក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ:ធ៨០២-១៤៩ ប្រក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២ ស្តីពីរចនាសម្ព័ន្ធរបស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និង មុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ
- យោងតាមការអនុមតិរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០៣

## សំរេច

**ប្រការ ១.-** រៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និង កំណត់មុខងារ-ភារកិច្ចរបស់ការិយាល័យនិងផ្នែកនៅក្រោមឱវាទ នៅក្នុងប្រការបន្តបន្ទាប់ខាងក្រោម ។

**ប្រការ ២.-** នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ស្ថិតនៅក្រោមចំណុះអគ្គនាយកដ្ឋាន ហើយមានមុខងារភារកិច្ចចំបង១ គឺ÷

- ធ្វើទំនាក់ទំនងជាមួយធនាគារកណ្តាលបរទេស ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារបរទេស ដើម្បីពិនិត្យពិចារណាបើកគណនីជារូបិយប័ណ្ណនៅស្ថាប័នទាំងនោះ
- គ្រប់គ្រងគណនីដែលបានបើកជាមួយធនាគារកណ្តាលបរទេស ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារបរទេស
- គ្រប់គ្រងនិងវិនិយោគដោយប្រុងប្រយ័ត្ននូវទុនបំរុងជារូបិយប័ណ្ណទៅលើផលិតផលហិរញ្ញវត្ថុដែលអាចនាំមកនូវសុវត្ថិភាពខ្ពស់ សាច់ប្រាក់ងាយស្រួល និងលទ្ធផលល្អ
- តាមដាននិងវិភាគលើការវិវត្តន៍នៃអត្រាការប្រាក់ អត្រាប្តូរប្រាក់ និងតំលៃមូលប័ត្រនៅលើទីផ្សារអន្តរជាតិ ដើម្បីជាមូលដ្ឋានសំរាប់ធ្វើការសំរេចក្នុងការវិនិយោគទុនបំរុងជារូបិយប័ណ្ណ
- គ្រប់គ្រងអាជីវកម្មប្តូរប្រាក់ ផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម និងផ្តល់លិខិតអនុញ្ញាតឱ្យនាំចេញ-នាំចូលរូបិយប័ណ្ណ លោហធាតុនិងត្បូងថ្មមានតម្លៃ ។

នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានពីររូប មួយរូបទទួលបន្ទុកការិយាល័យជួរមុខ មួយរូបទៀតទទួលបន្ទុកការិយាល័យជួរក្រោយ។ នៅពេលប្រធានអវត្តមាន ការិយាល័យទាំងពីរនេះត្រូវបានទទួលបន្ទុកផ្ទាល់ដោយអគ្គនាយក។

**ប្រការ ៣.-** រចនាសម្ព័ន្ធរបស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ត្រូវបានរៀបចំឱ្យមានការិយាល័យចំនួន៣នៅក្រោមឱវាទ ដូចមានអង្គការលេខភ្ជាប់ជាឧបសម្ព័ន្ធ គឺ ÷

១- ការិយាល័យជួរមុខ (Front Office Division) គ្រប់គ្រងផ្ទាល់នូវៈ
- ផ្នែកជួញដូរ (Dealing Section)
- ផ្នែកយុទ្ធសាស្ត្រវិនិយោគ (Strategic Investment Section)
- ផ្នែកទំនាក់ទំនងអន្តរជាតិ (International Correspondent Section)

២- ការិយាល័យជួរក្រោយ (Back Office Division) គ្រប់គ្រងផ្ទាល់នូវៈ
- ផ្នែកទូទាត់ (Settlement Section)
- ផ្នែកដំណើរការ SWIFT (SWIFT Section)
- ផ្នែកប្រៀបធៀបបញ្ជីគណនេយ្យ (Accounting Reconciliation Section)

៣- ការិយាល័យគ្រប់គ្រងអាជីវកម្មប្តូរប្រាក់(Foreign Exchange Division)គ្រប់គ្រងផ្ទាល់នូវៈ
- ផ្នែកលិខិតអនុញ្ញាតអាជីវកម្ម (Licensing Section)
- ផ្នែករដ្ឋបាលនិងប្រតិវេទន៍ (Administration and Declaration Section)

ការិយាល័យនីមួយៗ ក៏ដូចផ្នែកនីមួយៗដែលនៅក្រោមចំណុះ គឺត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយឬច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

**ប្រការ ៤.-** ការិយាល័យជួរមុខ (Front Office Division) មានមុខងារ-ភារកិច្ចធ្វើការជួញដូរ និងវិនិយោគរូបិយប័ណ្ណជាទុនបំរុង និងធ្វើការសិក្សាវាយតម្លៃទៅលើហានិភ័យដែលពាក់ព័ន្ធ រួមមានភារកិច្ចតាមផ្នែកដូចតទៅ ÷

១- ផ្នែកជួញដូរ (Dealing Section):

- អនុវត្តការណែនាំវិនិយោគ
- ប្រែក្លាយបញ្ហាគោលនយោបាយទៅជាបញ្ហាផ្លូវការ
- ធ្វើប្រតិបត្តិការជួញដូរជាមួយសមភាគីដែលមានកិត្តិស័ព្ទល្អ កំណត់កាលវសាន្តគំរូនៃការវិនិយោគ ដើម្បីនាំមកនូវលទ្ធផលខ្ពស់សមស្រប ធានាបានសុវត្ថិភាព សាច់ប្រាក់ងាយស្រួល នៃទុនបំរុងរបស់ជាតិ
- អនុវត្តដោយគោរពតាមក៏រិតកំណត់ដែលបានណែនាំ
- យល់ព្រមទៅលើតម្លៃ
- បញ្ចូលការជួញដូរទៅក្នុងប្រព័ន្ធជួញដូរ (ជាធម្មតា គឺជាប្រព័ន្ធជួញដូរ Reuters)
- ផ្ទៀងផ្ទាត់ការជួញដូរលើប្រព័ន្ធជួញដូរ ។

២- ផ្នែកយុទ្ធសាស្ត្រវិនិយោគ (Strategic Investment Section):

- សិក្សានិងវាយតម្លៃរាល់ហានិភ័យដែលពាក់ព័ន្ធដល់ការវិនិយោគ
- បង្កើតយុទ្ធសាស្ត្រដើម្បីដាក់ស្នើជូនគណៈកម្មការវិនិយោគទុនបំរុង
- តាមដានការប្រែប្រួលតម្លៃប្រាក់រូបិយប័ណ្ណបរទេស ដើម្បីធ្វើការវិនិយោគទុនបំរុងអន្តរជាតិឱ្យបានលទ្ធផលខ្ពស់ និងមានហានិភ័យទាបបំផុត
- ផ្តល់ការវិភាគលើឱកាសយុទ្ធសាស្ត្រវិនិយោគថ្មីៗទៀតជូនដល់គណៈកម្មការវិនិយោគទុនបំរុង
- ធ្វើរបាយការណ៍ឯករាជ្យជូនដល់ថ្នាក់ដឹកនាំ ។

៣- ផ្នែកទំនាក់ទំនងអន្តរជាតិ (International Correspondent Section) :

- ធ្វើទំនាក់ទំនងជាមួយធនាគារបរទេសដែលមានរេតទីង (Rating) ខ្ពស់ រួមមានធនាគារកណ្តាល ធនាគារពាណិជ្ជ ដើម្បីបើកគណនីទំនាក់ទំនង
- ទំនាក់ទំនងជាមួយធនាគារទាំងនោះ ដើម្បីទទួលបានជាប្រចាំនូវអត្រាការប្រាក់ដែលធនាគារទាំងនោះផ្តល់សំរាប់ផលិតផលវិនិយោគ
- ទំនាក់ទំនងជាប្រចាំតាមទូរស័ព្ទ អ៊ីម៉េល ហ្វាក់ ដើម្បីដឹងអំពីនិន្នាការវិវត្តន៍នៃសភាព-ការណ៍អត្រាប្តូរប្រាក់ អត្រាការប្រាក់នៅលើសកលលោក ដើម្បីមានមូលដ្ឋានសំរេចចិត្តទិញ-លក់រូបិយប័ណ្ណ ឬវិនិយោគ

- ប្រមូលផ្ដុំពត៌មានខាងផ្នែកហិរញ្ញវត្ថុ និង ប្ដូរប្រាក់ពីស្ថាប័នពត៌មានអន្តរជាតិ ដូចជាពី Reuters Bloomberg ។ល។ ដើម្បីទទួលបាននូវការវិភាគនៃការវិវត្តន៍នៃអត្រាការប្រាក់ អត្រាប្ដូរប្រាក់ និងតំលៃមូលប័ត្រ នៅលើសកលលោក
- ផ្អែកលើពត៌មានដែលបានទទួលខាងលើ ធ្វើការសរុបនឹងផ្ដល់យោបល់ជូនថ្នាក់ដឹកនាំដើម្បីសុំសេចក្ដីសំរេចចិត្តវិនិយោគ ។

**ប្រការ ៥.-** ការិយាល័យជួរក្រោយ (Back Office Division) មានមុខងារភារកិច្ចអនុវត្តការងារដែលទាក់ទិនទៅនឹងការទូទាត់ប្រតិបត្តិការជាក់ស្ដែងនៃការជួញដូររូបិយប័ណ្ណ និងការគ្រប់គ្រងទុនបំរុងដោយធ្វើការបញ្ជាក់ជាមួយសមភាគី ដើម្បីធ្វើឱ្យមានសុពលភាពនូវប្រតិបត្តិការជួញដូរ ឬវិនិយោគ ដែលអនុវត្តដោយការិយាល័យជួរមុខ ធ្វើការប្រៀបធៀបគណនីនិងគ្រប់គ្រងនូវសារលិខិតដែលបញ្ជូនចេញនិងចូល រួមមានភារកិច្ចតាមផ្នែកដូចតទៅ ÷

១- ផ្នែកទូទាត់ (Settlement Section) :

- ទទួលខុសត្រូវការបញ្ជាក់ដែលទទួលបាននិងបញ្ជូនទៅសមភាគី ដើម្បីធ្វើឱ្យមានសុពលភាពនូវរបាយការណ៍ហិរញ្ញវត្ថុលំអិតនៃការជួញដូរដែលអនុវត្តដោយការិយាល័យជួរមុខ និងដោះស្រាយនូវភាពលំអៀងគ្នា (mismatch)
- ទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើការគោរពតាមកំរិតកំណត់ដែលបានណែនាំដោយការិយាល័យជួរមុខ
- ទទួលបន្ទុកវាយតំលៃស្ថានភាពនៃការវិនិយោគតាមថ្លៃទីផ្សារនៅពេលចាំបាច់
- ដំណើរការទូទាត់សងប្រាក់ ត្រួតពិនិត្យលំអិត និងរៀបចំបញ្ជាទូទាត់ បញ្ជូនទៅឱ្យផ្នែក SWIFT ដើម្បីផ្ញើចេញ
- អនុវត្តបញ្ជាទូទាត់ចេញនិងទទួលបញ្ជាទូទាត់ចូលឱ្យត្រឹមត្រូវតាមអត្ថន័យដែលមានចែងនៅក្នុងបញ្ជាទាំងនោះ
- ដំណើរការចុះបញ្ជិកាគណនេយ្យនូវរាល់ប្រតិបត្តិការដែលបានអនុវត្ត ។

២- ផ្នែកដំណើរការ SWIFT (SWIFT Section)

- អនុវត្តដោយត្រឹមត្រូវនូវរាល់បទដ្ឋាន SWIFT
- រក្សាទុកដោយមានសុវត្ថិភាព លេខសម្ងាត់ លេខកូដរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដែលមានទំនាក់ទំនង
- ត្រួតពិនិត្យឱ្យបានត្រឹមត្រូវនូវលេខសម្ងាត់ លេខកូដ នៅលើសារដែលបានទទួល និងគិតលេខសម្ងាត់ លេខកូដ សំរាប់សារដែលត្រូវផ្ញើចេញ
- បញ្ជូនសារដែលមានការអនុញ្ញាតចេញទៅក្រៅប្រទេស

- ទទួលសារពីក្រៅប្រទេស និងបញ្ជូនទៅការិយាល័យជួរក្រោយ

៣- ផ្នែកប្រៀបធៀបបញ្ជីគណនេយ្យ (Accounting Reconciliation Section) :

- ប្រៀបធៀបជាប្រចាំនូវភាពត្រឹមត្រូវនូវប័ណ្ណជួញដូរ ចំនួនប្រាក់និងទិសដៅនៃបញ្ជាទូទាត់
- អនុវត្តការប្រៀបធៀបគណនីដោយទៀងទាត់និងទាន់ពេល
- ប្រៀបធៀបប្រកាសទូទាត់ជាមួយនឹងបញ្ជាទូទាត់
- ប្រៀបធៀបរបាយការណ៍គណនីឬរបាយការណ៍មូលប័ត្រជាមួយសមតុល្យគណនី NOSTRO ។

**ប្រការ ៦.-** ការិយាល័យជួរមុខ និង ការិយាល័យជួរក្រោយត្រូវមានទីតាំងដាច់ដោយឡែកពីគ្នាដាច់ខាត ហើយថ្នាក់ដឹកនាំការិយាល័យទាំងពីរនេះមិនអាចធ្វើការងារជំនួសឱ្យគ្នាទៅវិញទៅមកបានឡើយ ។

**ប្រការ ៧.-** ការិយាល័យគ្រប់គ្រងអាជីវកម្មប្តូរប្រាក់ (Foreign Exchange Office) មានមុខងារ-ភារកិច្ចអនុវត្តការងារដែលទាក់ទិនទៅនឹងការគ្រប់គ្រងអាជីវកម្មប្តូរប្រាក់ លោហធាតុនិងត្បូងថ្មមានតម្លៃ រួមមានភារកិច្ចតាមផ្នែកដូចតទៅ ÷

១- ផ្នែកលិខិតអនុញ្ញាតអាជីវកម្ម (Licensing Section) :

- ពិនិត្យសំណើសុំប្រកបអាជីវកម្មប្តូរប្រាក់ លោហធាតុនិងត្បូងថ្មមានតម្លៃ និងរៀបចំសំណុំបែបបទចេញលិខិតអនុញ្ញាតអាជីវកម្ម
- ពិនិត្យបន្តឡើងវិញ ឬក្នុងករណីមានកំហុសឆ្គង ព្យួរ ឬដកហូតលិខិតអាជីវកម្ម
- ផ្សព្វផ្សាយប្រកាស បទបញ្ជា សារាចរណែនាំ លិខិតជូនដំណឹង ។ល។ ដល់ប្រតិបត្តិករអាជីវករ
- ធ្វើស្ថិតិអាជីវកម្មប្តូរប្រាក់ អាជីវកម្មលោហធាតុនិងត្បូងថ្មមានតម្លៃ
- តាក់តែងលិខិតបទដ្ឋាននានាដែលទាក់ទិនទៅនឹងរបបនិងអាជីវកម្មប្តូរប្រាក់
- ត្រួតពិនិត្យ តាមដានការអនុវត្តន៍ និង ការគោរពតាមបទបញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងអាជីវកម្មប្តូរប្រាក់ លោហធាតុនិង ត្បូងថ្មមានតម្លៃ ដែលធនាគារជាតិនៃកម្ពុជាបានកំណត់ ។

២- ផ្នែករដ្ឋបាលនិងប្រតិវេទន៍ (Administration and Declaration Section) :

- តាមដានសាច់ប្រាក់រូបិយប័ណ្ណ ដើម្បីក្តាប់បានពីស្ថានភាពខ្វះឬលើសសាច់ប្រាក់រូបិយប័ណ្ណនៅបេឡាធនាគារជាតិនៃកម្ពុជា ដើម្បីលើកសំណើនាំចេញឬនាំចូលរូបិយប័ណ្ណ តាមការជាក់ស្តែង

- ពិនិត្យសំណើសុំនាំចេញឬនាំចូលសាច់ប្រាក់រូបិយប័ណ្ណរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញ-វត្ថុ ព្រមទាំងផ្តល់ទិដ្ឋាការតាមការជាក់ស្តែង
- ពិនិត្យសំណើនាំចេញ-នាំចូលលោហធាតុមានតំលៃរបស់ធនាគារ និង ក្រុមហ៊ុនអាជីវកម្មមាស ព្រមទាំងផ្តល់ទិដ្ឋាការតាមការជាក់ស្តែង
- ធ្វើនូវរាល់ការងារដែលទាក់ទងនឹងការងាររដ្ឋបាលសំរាប់នាយកដ្ឋាន ។

**ប្រការ ៨.-** ក្រៅពីភារកិច្ចដែលមានចែងនូវរាល់ប្រការខាងលើនេះ ថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងផ្នែកនីមួយៗត្រូវអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់លើប្រគល់ជូន ។

**ប្រការ ៩.-** ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីបុគ្គលិកនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ត្រូវរក្សាដាច់ខាតនូវការសម្ងាត់វិជ្ជាជីវៈ អនុលោមតាមមាត្រា១៦និងមាត្រា៧១នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១០.-** រាល់ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១.-** អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងនាយកដ្ឋានសាមីត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១២.-** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ២០០៣

**ទេសាភិបាល**

ជា ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ១១
" ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

------------------------------

**ចំលងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គការលេខ
ស្តីពី
រចនាសម្ព័ន្ធរបស់នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់
( ឧបសម្ព័ន្ធនៃប្រកាសលេខ ធ៨-០៣-០៩៤ ប្រក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ )

------------



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣ ❖ ៨៨

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៤៨១ អយក.ប្រក

**ប្រកាស**

ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធ **វត្តត្រស់**

មកជាសាលាបឋមសិក្សាពេញលក្ខណៈ

---

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកាឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជា នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិត របស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា **វត្តត្រស់** ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០២ ដោយមានចំណារ ឯកភាព របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង** ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

**ស ម្រេ ច**

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ **វត្តត្រស់** ពីសាលាបឋមសិក្សា **វត្តត្រពាំងបន្ទាយ** ដែលមានទីតាំងស្ថិតនៅឃុំ **ត្រស់** ស្រុក **រមាសហែក** ខេត្ត **ស្វាយរៀង** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **វត្តត្រស់** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **រមាសហែក** នាយកសាលាបឋមសិក្សា **វត្តត្រស់** នាយកសាលាបឋមសិក្សា **វត្តត្រពាំងបន្ទាយ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី១០ ខែ មិថុនាឆ្នាំ ២០០៣

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

**អ៊ឹម-សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត ស្វាយរៀង

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៥

-កាលប្បវត្តិ-ឯកសារ នា .បស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៤៩២ អយក.ប្រក

**ប្រកាស**

ស្តីពី ការបើកសាលាបឋមសិក្សា **កំពង់ព្លៅ**

ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ស្វាយចេក**

---

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យ លេខ នស .រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតរបស់តំណាងប្រជាពលរដ្ឋភូមិកំពង់ព្លៅ ឃុំកោះខ្មែរ ស្រុក សំបូរ ខេត្តក្រចេះ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០២ដោយមានចំណារឯកភាពរបស់ មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ក្រចេះ** ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

**សំ រេ ច**

**ប្រការ១** : បើកសាលាបឋមសិក្សា **កំពង់ព្លៅ** ដែលមានទីតាំងស្ថិតនៅ ភូមិ **កំពង់ព្លៅ** ឃុំ **កោះខ្មែរ** ស្រុក **សំបូរ** ខេត្ត **ក្រចេះ** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ស្វាយចេក** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **កំពង់ព្លៅ** ត្រូវដឹកនាំដោយ ប្រធានក្រុមមួយរូប ទទួលខុសត្រូវរួមជាមួយនាយកសាលាបឋមសិក្សា **ស្វាយចេក** ។

**ប្រការ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ក្រចេះ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **សំបូរ** នាយកសាលាបឋមសិក្សា **ស្វាយចេក** ប្រធានក្រុមសាលាបឋមសិក្សា **កំពង់ព្លៅ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **ក្រចេះ**

" **<u>ដើម្បីជូនជ្រាបជាពត៌មាន</u>** "

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា .បស

ភ្នំពេញ , ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

**ខ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

រដ្ឋលេខាធិការ

**អ៊ឹម_សិទ្ធី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៙៚ ❖ ៙៚

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ : ៤៥៣ អយក.ប្រក**

# ប្រកាស

## ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធ **វត្តដូង** មកជាសាលាបឋមសិក្សាពេញលក្ខណៈ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកាឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជា នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិត លេខ ៥៩៩ អយក .បម ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០២ របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង**

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## សំ រេ ច

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ **វត្តដូង** ពីសាលាបឋមសិក្សា **ដូង** ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណវត្ត **ដូង** ឃុំ **ដូង** ស្រុក **រមាសហែក** ខេត្ត **ស្វាយរៀង** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **វត្តដូង** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **រមាសហែក** នាយកសាលាបឋមសិក្សា **វត្តដូង** នាយកសាលាបឋមសិក្សា **ដូង** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **ស្វាយរៀង**

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៥

-កាលប្បវត្តិ-ឯកសារ នា .បស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ : ៤៩៤ អយក.ប្រក**

# ប្រកាស

## ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធ ត្រពាំងរុន មកជាសាលាបឋមសិក្សាពេញលក្ខណៈ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកាឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជា នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិត របស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា **ត្រពាំងរុន** ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០២ ដោយមានចំណារ ឯកភាព របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង** ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## សំរេច

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ**ត្រពាំងរុន** ពីសាលាបឋមសិក្សា **ចន្ទ្រី** ដែលមានទីតាំងស្ថិតនៅឃុំ **ចន្ទ្រី** ស្រុក **រមាសហែក** ខេត្ត **ស្វាយរៀង** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **ត្រពាំងរុន** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ស្វាយរៀង** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **រមាសហែក** នាយកសាលាបឋមសិក្សា **ត្រពាំងរុន** នាយកសាលាបឋមសិក្សា **ចន្ទ្រី** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី១០ ខែ មិថុនាឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម-សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត ស្វាយរៀង

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៥

-កាលប្បវត្តិ-ឯកសារ នា.បស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៤៥៤ អយក.ប្រក

**ប្រកាស**

ស្តីពី ការបើកសាលាបឋមសិក្សា **ប្រទាំញ**

ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **២ធ្នូ**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យ លេខ នស .រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតរបស់ប្រធានកំរង **២ធ្នូ** ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០២ ដោយមានចំណារឯកភាពរបស់ មន្ទីរអប់រំយុវជន និង កីឡា ខេត្ត **ក្រចេះ** ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

**ស ំ រេ ច**

**ប្រការ១** : បើកសាលាបឋមសិក្សា **ប្រទាំញ** ដែលមានទីតាំងស្ថិតនៅ ភូមិ **ប្រទាំញ** ឃុំ **២ធ្នូ** ស្រុក **ស្នួល** ខេត្ត **ក្រចេះ** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **២ធ្នូ** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **ប្រទាំញ** ត្រូវដឹកនាំដោយ ប្រធានក្រុមមួយរូប ទទួលខុសត្រូវរួមជាមួយនាយកសាលាបឋមសិក្សា **២ធ្នូ** ។

**ប្រការ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ក្រចេះ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ស្នួល** នាយកសាលាបឋមសិក្សា **២ធ្នូ** ប្រធានក្រុមសាលាបឋមសិក្សា **ប្រទាំញ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **ក្រចេះ**

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា .បស

ភ្នំពេញ , ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈរដ្ឋមន្ត្រី**

ក្រសួងបរិស្ថាន

លេខៈ ១៤៨ (ចែក) ប.ស្ត

រាជធានីភ្នំពេញ. ថ្ងៃទី ១១ ខែ មិនា ឆ្នាំ២០០៣

# ប្រកាស

## ស្តីពី ការបង្កើតក្រុមប្រឹក្សាភិបាលអន្តរក្រសួងទទួលបន្ទុកសំរបសំរួលការអនុវត្តន៍ អនុសញ្ញាបាសែល អនុសញ្ញារ៉ូតឺដាំ និងអនុសញ្ញាស្តុកខូម

======================

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងលិខិតលេខ ៤៤២២ កបទ-សអ/ច្បកគ ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០២ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងលិខិតលេខ ៣៧០៩ កសក ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០០២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងលិខិតលេខ ១២៨៩ ឧរថបឧ.លស ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០២ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងលិខិតលេខ ០៧៣ អបស ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០០២ របស់ក្រសួងសុខាភិបាល

- យោងលិខិតលេខ ១៧០៧ សក ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០០២ របស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- យោងលិខិតលេខ ២៦៦៨ MoC / M2002 ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០២ របស់ក្រសួងពាណិជ្ជកម្ម
- យោងលិខិតលេខ ១៧៩ សជណ.ខុទ ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០០២ របស់ក្រសួងទេសចរណ៍
- យោងលិខិតលេខ ២៤៥០ / ០២ ក.អ.ក ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ ៦៩២ គរ ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងលិខិតលេខ ២២៦៧ លស ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០០២ របស់សាលាក្រុងភ្នំពេញ
- យោងលិខិតលេខ ១៣៩ សជណ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០២ របស់ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ
- យោងលិខិតលេខ ១៥៦ លទ ០២ អអក ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០០២ របស់អាជ្ញាធរអគ្គិសនីកម្ពុជា
- យោងលិខិតចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០២ របស់អង្គការមូលបែតង
- ពិនិត្យលើភាពចាំបាច់នៃការងាររបស់ក្រសួងបរិស្ថាន ។

## សំ រេ ច

**ប្រការ ១ :** បង្កើតក្រុមប្រឹក្សាភិបាលអន្តរក្រសួងទទួលបន្ទុកសំរបសំរួលការអនុវត្តន៍អនុសញ្ញាបាសែល អនុសញ្ញារ៉ូតែរដាំ និងអនុសញ្ញាស្តុកខុម ដើម្បីធានានូវការសំរបសំរួលរាល់សកម្មភាពនៃបណ្តាស្ថាប័នជាតិ ដែលពាក់ព័ន្ធទៅនឹងអនុសញ្ញាអន្តរជាតិទាំងបី សំដៅទប់ស្កាត់គ្រោះថ្នាក់ទៅលើសុខភាពសាធារណៈ និងបរិស្ថាន ពោលគឺការធានាបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

**ប្រការ ២ :** សមាសភាពនៃក្រុមប្រឹក្សាភិបាលនេះរួមមាន :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ឆាន់ សាផាន | រដ្ឋលេខាធិការក្រសួងបរិស្ថាន | ប្រធាន |
| ២- | ឯកឧត្តម ខៀវ មុត | អគ្គនាយកបច្ចេកទេស | អនុប្រធាន |
| ៣- | លោក ឆាយ សុខន | តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៤- | លោក ស៊្រុន សុខុម | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥- | លោក ប៊ី ពិទូរ្យ | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៦- | លោកស្រី ប្រាក់ ពិសិដ្ឋរង្សី | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៧- | លោក ប៊ុន ងួន | តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៨- | លោក ស្រី សិរីវឌ្ឍន៍ | តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៩- | លោក ឃ្លោក ជួន | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |

| | | |
|---|---|---|
| ១០- លោក ជា ច័ន្ទដារី | តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១១- លោក សេង សុចិន្តា | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១២- លោក ជា ហាក់ | តំណាងទីចាត់ការគយនិងរដ្ឋាករ | សមាជិក |
| ១៣- លោក ហេង ឡៃអ៊ិន | តំណាងសាលាក្រុងភ្នំពេញ | សមាជិក |
| ១៤- លោក វ៉ាន់ ណារី | តំណាងក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៥- លោក ហ៊ុល គុណវុឌ្ឍ | តំណាងអាជ្ញាធរអគ្គិសនីកម្ពុជា | សមាជិក |
| ១៦- បណ្ឌិត ព្រាប វិសារទោ | តំណាងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ១៧- លោក វ៉ា មឿន | តំណាងអង្គការម្ហូបបៃតង | សមាជិក |

**ប្រការ ៣** : ក្រុមប្រឹក្សាភិបាលនេះមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ដែលមានទីតាំងនៅក្នុងទីស្តីការក្រសួងបរិស្ថាន ហើយដែលត្រូវទទួលខុសត្រូវក្នុងការសំរួលរាល់កិច្ចការរបស់ក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ដើម្បីសំរួលការងារ ។

**ប្រការ ៤** : ក្រុមប្រឹក្សាភិបាលនេះមានតួនាទី និងភារៈកិច្ចដូចខាងក្រោម :

- រៀបចំសំណើគោលនយោបាយ ច្បាប់ និងផែនការជាតិ ដែលទាក់ទងទៅនឹងការជំរុញការអនុវត្តន៍អនុសញ្ញាបាសែល អនុសញ្ញារ៉ូតែរដាម និងអនុសញ្ញាស្តុកខូម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសំរេច ។
- សំរបសំរួលក្នុងការជំរុញការអនុវត្តន៍អនុសញ្ញាទាំងបី ព្រមទាំងគោលនយោបាយ ច្បាប់ និងផែនការជាតិដែលពាក់ព័ន្ធនឹងអនុសញ្ញាទាំងនោះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។
- ពិនិត្យ វាយតំលៃ និងធានាថា គោលនយោបាយនិងផែនការជាតិ ដែលទាក់ទងនឹងការជំរុញការអនុវត្តន៍អនុសញ្ញាទាំងបី ឆ្លើយតបទៅនឹងបណ្តាអាទិភាព និងគោលដៅអភិវឌ្ឍន៍របស់ជាតិ ។
- សំរបសំរួល និងជំរុញឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីភាគីពាក់ព័ន្ធទាំងអស់ ក្នុងការរៀបចំគោលនយោបាយ ច្បាប់ និងផែនការជាតិដែលពាក់ព័ន្ធនឹងអនុសញ្ញាទាំងនោះ ។
- កំណត់នូវគោលការណ៍ និងយុទ្ធសាស្ត្រ សំរាប់ដាក់ជូនរាជរដ្ឋាភិបាលធ្វើការចរចានៅក្នុងកិច្ចប្រជុំអន្តរជាតិនានា ដែលពាក់ព័ន្ធនឹងអនុសញ្ញាទាំងនោះ ។
- គៀងគរនូវធនធានដែលចាំបាច់ សំរាប់ជំរុញការអនុវត្តន៍ផែនការជាតិ ដែលពាក់ព័ន្ធនឹងកាតព្វកិច្ចនៃភាគីសមាជិករបស់អនុសញ្ញាទាំងបី ។ ៚



- លើកកំពស់យល់ដឹង និងផ្សព្វផ្សាយពត៌មានជូនដល់អ្នកនយោបាយជាន់ខ្ពស់ ក៏ដូចជាសាធារណៈជនទូទៅ ស្តីពីគោលការណ៍ និងកត្តាព្វកិច្ចដែលត្រូវបំពេញនៅក្រោមអនុសញ្ញាទាំងបី ។
- ចូលរួមក្នុងកិច្ចប្រជុំ និងសិក្ខាសាលាថ្នាក់ជាតិ តំបន់ និងអន្តរជាតិ លើបញ្ហាដែលពាក់ព័ន្ធនឹងអនុសញ្ញាទាំងបី ។
- ណែនាំ និងសំរបសំរួលបណ្តាគំរោង កម្មវិធី និងសកម្មភាពស្រាវជ្រាវនានា ដែលពាក់ព័ន្ធបញ្ហានៃអនុសញ្ញាទាំងបី ។
- ត្រួតពិនិត្យ និងអនុម័តលើផែនការ និងរបាយការណ៍លទ្ធផលការងារគំរោង ឬកម្មវិធី ដែលបានបំពេញនៅក្រោមប្រធានបទនៃអនុសញ្ញាទាំងបី ។

**ប្រការ ៥** : សមាសភាពនៃក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច និងភារៈកិច្ច ដូចមានចែងក្នុងប្រការ ៤ ខាងលើ និងត្រូវចូលរួមប្រជុំឱ្យបានទៀងទាត់តាមការកោះអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាល ត្រូវធ្វើរបាយការណ៍នៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងរបាយការណ៍លទ្ធផលការងារនានាពាក់ព័ន្ធនឹងគំរោង ឬកម្មវិធី ដែលស្ថិតនៅក្រោមក្របខ័ណ្ឌនៃអនុសញ្ញាទាំងបី ទៅរាល់សមាជិកនៃក្រុមប្រឹក្សាភិបាល និងទៅបណ្តាក្រសួងនិងស្ថាប័នពាក់ព័ន្ធ ។

**ប្រការ ៦** : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ នាយកនៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន និងសាម៉ីខ្លួនត្រូវអនុវត្តប្រកាសនេះ ។/.

រដ្ឋមន្ត្រី

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវិទ្យា

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ដូចក្នុងប្រការ ៦
- ឯកសារ-កាលប្បវត្តិ